សង្ឃទានមានផលច្រើន

រៀបរៀងដោយ

មេត្តាបាលោ **ឆឹម សៀត**

បោះពុម្ពលើកទី១ ចំនួន ៤.000 ច្បាប់

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥៤៥ គ.ស. ២00១

បានការអនុញ្ញាតអំពី ព្រះតេជព្រះគុណ មេគ្គាបាលោ ទឹម សៀត
ដើម្បីស្កេនឡើងវិញ និងចែកចាយជាធម្មទាន ។
ស្កេនដោយ គេហទំព័រ៥០០០ឆ្នាំ
www.5000-years.org

សប្បុធានមានផលប្រើន

ភីធានធ្វើបំពោះសប្បមានព្រះពុទ្ធជាប្រធាន

រៀបរៀងដោយ

មេត្តាបាលោ **ធីម សៀត**

បោះពុម្ពលើកទី១ ចំនួន ៤.000 ច្បាប់

ភ្នំពេញ

ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

ព.ស ២៥៤៥ គ.ស ២000១

សេចក្តីបញ្ជាក់
ចំពោះការបោះពុម្ព

ក្នុងឆ្នាំកន្លងទៅនេះ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ និងសាសនា បានស្រាវជ្រាវ រើសរកក្បួនខ្នាតទាក់ទងនឹងអក្សរសាស្ត្រសាសនា ប្រពៃណី ទំនៀមទម្លាប់ មកបោះពុម្ពឡើងវិញ ដើម្បីរក្សាស្នាដៃរបស់បុព្វបុរសខ្មែរយើង ។ ទន្ទឹមនឹងនេះដែរ វិទ្យាស្ថានក៏បានបោះពុម្ពស្បៀវភៅដែលជាចំណារដៃថ្មីៗរបស់បញ្ញវន្តជំនាន់ក្រោយ ដើម្បីជំរុញអោយអ្នកនិពន្ធរីកដុះដាលបន្តវេន ។

ស្បៀវភៅ «**សង្ឃឱវាទមានផលច្រើន**» ដែលរៀបរៀងដោយព្រះតេជគុណមេត្តាបាលោ **ឱម សៀត** នឹងមានគុណប្រយោជន៍ដល់ពុទ្ធបរិស័ទ និងអ្នកស្រាវជ្រាវទូទៅបានសិក្សាជាក់ជាខាន ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអរព្រះគុណចំពោះព្រះតេជគុណមេត្តាបាលោ **ឱម សៀត** ដែលបានផ្តល់នូវស្នាព្រះហស្តនេះសំរាប់ជាឯកសារសិក្សា និងជាការបន្តថែរក្សាមរតកវប្បធម៌ អក្សរសាស្ត្រអោយគង់វង្ស ។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនាក្នុងការបោះពុម្ពនេះ ។

ភ្នំពេញ.ខែកញ្ញា ឆ្នាំ ២០០១

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

នាមអ្នកជួយពិនិត្យ

១- ព្រះតេជគុណ យឿង យាត់ មេគណខេត្តកណ្តាល

២- ព្រះតេជគុណ យឺ ទិត វិន័យធរស្រុកកៀនស្វាយ

៣- ភិក្ខុ សាន សប្បាយ

៤- ភិក្ខុ ស៊ុន សាមឿន

៥- ភិក្ខុ ហោ គីមសាន

៦- ភិក្ខុ ហេង ប៊ុនជា

៧- ភិក្ខុ ឈឿន ភិរម្យ

៨- ភិក្ខុ គូ សុភាព

៩- សាមណេរ សួង សឿ

១០- សាមណេរ អ៊ឹម សំអឿន

១១- សាមណេរ សេម កី

១២- លោកនាយក វិទ្យាស្ថានសាសនបណ្ឌិត្យ

១៣- អ្នកឧកញ៉ាធិបតី ឆូ វ៉ាន់ បរមរាជវាំង

១៤- លោកឧបាសក សំរ៉ែង វ៉ាន់

១៥- លោកឧបាសក ដាំ កុយ

១៦- លោកឧបាសក ព្រឿង

១៧- លោកឧបាសក ប៉ែន សុផេង

១៨- លោកឧបាសក សួន ឱសថ

១៩- ឧបាសិកា ប៊ុត កាន់ឌី



អារម្ភកថា

សៀវភៅនេះ អាត្មាភាពរៀបរៀងជាលើកទី១បង្អស់ ដោយយល់ឃើញថា : ក្នុងបញ្ហាបំពេញបុណ្យកុសល ពុទ្ធបរិស័ទដោយច្រើនតែងសួរថា ធ្វើបុណ្យអ្វីទើបបានបុណ្យច្រើន ? ដើម្បីជាការឆ្លើយតបនូវបញ្ហានេះ អាត្មាក៏ព្យាយាមសរសេរសៀវភៅឈ្មោះសង្ឃទាននេះ ដើម្បីបំភ្លឺ និងកម្ចាត់សេចក្តីសង្ស័យខ្លះៗ ក្នុងកិច្ចការបំពេញបុណ្យកុសលទាំងឡាយផ្សេងៗ ពិសេស ក្នុងរឿងបុណ្យសង្ឃទាន (ទានដែលធ្វើចំពោះសង្ឃ) ដែលតែងជជែកគ្នាថា អាចឡើងជាសង្ឃទានបាន លុះត្រាតែមានភិក្ខុ៤អង្គឡើងទៅជាអ្នកមកទទួលទាន បើខ្វះតែមួយអង្គវេរសង្ឃទានមិនបាន ឬបើជាសាមណេរ ធ្វើសង្ឃទានមិនបានដែរ ម៉្យាងទៀតក្នុងវិន័យរបស់សង្ឃដែលទាក់ទងក្នុងការធ្វើទាន តែងមានការយល់មិនស្របគ្នាដោយច្រើន ដូចជារឿងលក្ខណៈប្រគេនចង្ហាន់ព្រះសង្ឃឱ្យត្រឹមត្រូវតាមព្រះវិន័យ ឬចាប់ពាល់ត្រូវចង្ហាន់ដែលបានប្រគេនរួចហើយជាដើម

ព្រោះហេតុដូច្នេះ នៅខាងចុងនៃការអធិប្បាយរឿងសង្ឃទាននេះ អត្ថាភាពបាន សរសេរបកិណ្ណកៈវិន័យខ្លះៗទុកសម្រាប់ការយល់ដឹងដ៏ល្មមសមគួរ ដល់ទាយកទាយិកា ដើម្បីងាយស្រួលក្នុងការទំនុកបំរុងព្រះភិក្ខុសង្ឃ អ្នកមានសីលជាទិស្រឡាញ់ ។

តែទោះជាយ៉ាងណា ក៏នៅមិនគ្រប់គ្រាន់ និងជៀសវាងការខុសឆ្គាំឆ្គងមិនបាន អាស្រ័យហេតុនេះ សូមលោកអ្នកអានទាំង-ឡាយ ជួយកែតម្រូវដោយកុសលចេតនាផងចុះ ។

កុសលធម្មទានដ៏ប្រសើរនេះ សូមលើកជូនលោកអគ្គបណ្ឌិត ប៊ុត សាវង្ស ដែលបានផ្តល់នូវការចេះដឹងឱ្យអាត្ថាភាព និងសូមប្រគេនជូន ដល់លោកអ្នកធ្លាប់មានឧបការគុណទាំងអស់ផង ព្រម-ទាំងលោកអ្នកជួយខ្នះខ្នែងឧបត្ថម្ភផង លោកអ្នកជួយគាំទ្រផង និង លោកអ្នកអានគ្រប់ៗគ្នាផង ។

ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន

(អាស្រមមិគ្រោធវន)

ថ្ងៃ ៦រោច ខែភទ្របទ ព.ស ២៥៤៥

មេត្តាចារ្យ ឆឹម សៀត

មាតិកា **ទំព័រ**

សេចក្តីផ្តើម ១

- សង្ឃទានគឺជាអ្វី ? ១
- សង្ឃមានន័យ ២ យ៉ាង ៣
- សង្ឃទានមានប៉ុន្មានប្រភេទ ៤
- ព្រះបំណងដែលទ្រង់សម្តែងនូវសង្ឃទាន ៧
- លក្ខណៈយ៉ាងណាទើបជាសង្ឃទានពិត ៩
- ដាក់បាត្រជាសង្ឃទានឬទេ ? ១៣
- ពាក្យវេរសង្ឃទាន ១៤
- សង្ឃទានក្នុងព្រះវិន័យ ១៨
- អានិសង្សនៃសង្ឃទាន ១៩
- កុសលដែលមានផលក្រៃលែងជាងសង្ឃទាន ២១

ព្រះវិន័យដែលទាក់ទងក្នុងការធ្វើទាន ๒๘

- ការបដិបត្តិក្នុងវត្ថុពុទ្ធបូជា ๒๙
- វត្ថុគួរនិងមិនគួរប្រគេន ๓๐
- អង្គនៃការប្រគេន ๕ យ៉ាង ๓๒
- តើស្ត្រីអាចប្រគេនបានឬទេ ? ๓๔
- ហេតុនាំឱ្យដាច់ប្រគេន ๗ យ៉ាង ๓๖
- វត្ថុត្រូវធ្វើជាកប្បិយៈសិន ទើបឆាន់បាន ๓๗
- វិធីធ្វើវិនយកិច្ច ๓๘
- សាច់ ๑๐ យ៉ាងទ្រង់ហាមមិនឱ្យបព្វជិតឆាន់ ๔๐
- រឿងមាសប្រាក់ ๔๓
- ពាក្យបវារណាបច្ច័យ ๔ ដល់ភិក្ខុ ๔๔
- វិធីបដិបត្តិក្នុងមាសប្រាក់សម្រាប់ចូលកសាង ๔๖
- សម្បត្តិសង្ឃជាគរុភណ្ឌ ๒๕ យ៉ាង ๔๘
- អនាមាសវត្ថុ (វត្ថុដែលភិក្ខុមិនគួរពាល់ត្រូវ) ๕๐

- ពោលអំពីស្បែកជើង ៥៤
- កាលិកសំសគ្គ (ការលាយឡំគ្នានៃកាលិក) ៥៧
- គិលានភេសជ្ជៈរបស់សង្ឃ ៥៩
- ភេសជ្ជៈគួរឆាន់ និងមិនគួរឆាន់ ៦0
- ការប្រគេនចីវរ ៦២
- ខ្នាតនៃចីវរ ៦៥
- សេនាសនៈរបស់សង្ឃ ៧២
- សេចក្តីផ្សេងគ្នារបស់វិនយកិច្ច និងសង្ឃកម្ម ៧៤
- វិន័យមានសារៈសំខាន់ដល់ព្រះពុទ្ធសាសនាយ៉ាងណាខ្លះ ? ៧៦
- ទ្រង់បញ្ញត្តនូវព្រះវិន័យ ព្រោះឃើញប្រយោជន៍១0យ៉ាង ៧៨
- ព្រះពុទ្ធសាសនាគឺធម៌វិន័យ ៨0
- ហេតុចម្រើននិងសាបសូន្យនៃព្រះពុទ្ធសាសនា ៨0

ឥរិយាបថដ៏សមរម្យរបស់ពុទ្ធបរិស័ទ ៨១

- សេចក្តីគោរពក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ៨២

- ការគោរពព្រះរតនត្រៃ គឺការថ្វាយបង្គំ ៨៣
- ការបដិបត្តិចំពោះព្រះសង្ឃ ៨៧
- ការងើបឡើងទទួលព្រះសង្ឃ ៨៨
- ការតាមជូនដំណើរព្រះភិក្ខុសង្ឃត្រឡប់ ៨៩
- ការឱ្យអាសនៈ (ទីអង្គុយ) ដល់ព្រះភិក្ខុសង្ឃ ៩០
- វិធីប្រគេនទេយ្យធម៌ចំពោះភិក្ខុសង្ឃ ៩១
- ការបដិបត្តិនៅពេលប្រាស័យសន្ទនាជាមួយព្រះសង្ឃ ៩៣

បុណ្យទក្ខិណានុប្បទាន ៩៦

- ពាក្យថាទក្ខិណានុប្បទាន. ៩៧
- ព្រះពុទ្ធជាម្ចាស់ទ្រង់ណែនាំឱ្យធ្វើទក្ខិណានុប្បទាន ៩៧
- ហេតុដូចម្តេចចាំបាច់មានព្រះសង្ឃមកទទួលនូវទាន ១០១
- ផលនៃទក្ខិណាទានសម្រេចដល់ប្រេតជាញាតិនោះតើដូចម្តេច ? ១០៣
- ប្រវត្តិប្រេតធ្លាប់ជាញាតិរបស់ព្រះបាទពិម្ពិសារ ១០៤
- តិរោកុឌ្ឌសូត្រ ១១៦

- រសចក្តីពន្យល់ក្នុងតិរោកុឌ្ឋសូត្រ ๑๒๐
- ពុទ្ធភាសិតសរសើរនូវបុញ្ញឫទ្ធិ ๑๔๖

ពាក្យសម្រាប់ខ្ចប់ខ្ចិសផល

- យ៉ាកិញ្ចិ បាលី ๑๕๑
- យ៉ាកិញ្ចិ ប្រែ ๑๕๑
- យ៉ាកិញ្ចិ ប្រែពាក្យកាព្យ ๑๕๔
- យាទេវតា បាលី ๑๕๖
- យាទេវតា ប្រែ ๑๕๘
- យាទេវតា ប្រែពាក្យកាព្យ ๑๖๑
- ប្រពៃណីសូមអាហារដែលសេសសល់អំពីព្រះសង្ឃ ๑๖๒

វិធីវេរកត្តនិងបច្ច័យផ្សេងៗ ๑๖๔

- វិធីវេរកត្តដល់ព្រះភិក្ខុសង្ឃ ๑๖๔
- វិធីវេរសង្ឃទាន ๑๖๖
- វិធីវេរចតុប្បច្ច័យជាសង្ឃទាន ๑๖๗

- វិធីវែរសាលា ១៦៩
- វិធីវែរកុដិ ១៧០
- វិធីវែរកឋិនទាន ១៧១

សង្ឃទាន

ក្នុងបច្ចុប្បន្ននេះ ឧបាសក ឧបាសិកា និយមធ្វើសង្ឃទាន ដោយច្រើន ដោយយល់ឃើញផ្សេងៗគ្នា ដូចជាយល់ថា នឹងបានអានិសង្សច្រើន យល់ថានឹងជាការរំដោះគ្រោះ យល់ថាផលបុណ្យនឹងបានដល់ញាតិដែលធ្វើមរណកាលទៅ នឹងយល់ថា ជាការរួចផុតចាកកម្មព្យៀរ ជាសះស្បើយចាករោគា ព្យាធិផ្សេងៗ ។

ដើម្បីការយល់យ៉ាងត្រឹមត្រូវ គួរពិចារណាដល់ព្យញ្ជនៈ អត្ថ ហេតុនិងផលថា សង្ឃទានគឺអ្វី សង្ឃទានមានប៉ុន្មានប្រភេទ ព្រះពុទ្ធជាម្ចាស់ទ្រង់បំណងសម្តែងសង្ឃទានដើម្បីអ្វី ? លក្ខណៈយ៉ាងណាទើបជាសង្ឃទានពិត ហើយអ្វីជាអានិសង្សរបស់សង្ឃទាន ? ។

សង្ឃទានគឺជាអ្វី?

ពាក្យថា "**សង្ឃទាន**" ជាពាក្យរួមភាសាបាលី ២ ពាក្យគឺ **សង្ឃ + ទាន** ។

ទានមាន៣យ៉ាង

១- **ចាគចេតនា** គឺការតាំងចិត្តលះវត្ថុដើម្បីអនុគ្រោះ ឬបូជាដល់អ្នកទទួល (បដិគ្គាហកៈ) ។

២- **ទេយ្យធម៌** គឺវត្ថុដែលគប្បីឱ្យ ដូចទានវត្ថុ១០ បានដល់ បាយ ទឹក យាន សំពត់ ផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីស្នាក់អាស្រ័យ គ្រឿងប្រទីប (វត្ថុដែលជាប្រយោជន៍ដល់អ្នកទទួល ក៏សង្គ្រោះថា ទានវត្ថុទាំងអស់) ។

៣- **សមាទានវិរតិ** គឺការតាំងចិត្តវៀរទុច្ចរិតផ្លូវកាយ វាចា (សីល៥) ដែលជាអភ័យទាន ។

"**ទាន**" ក្នុងទីនេះ សំដៅយក ចាគចេតនា និងទេយ្យធម៌ (**ស្រង់ចាក អដ្ឋកថា កថាវត្ថុ ទានកថា អភិធម្មបិដក មង្គលទីបនី ទានកថា**) ។

សង្ឃមានន័យ២យ៉ាង

ន័យទី១ សង្ឃក្នុងព្រះធម៌ (សង្ឃរតនៈ) សំដៅយក អរិយបុគ្គលៗពួក ដែលបានសម្រេចនូវ

សោតាបត្តិមគ្គ ១	**សោតាបត្តិផល ១**
សកទាគាមិមគ្គ ១	**សកទាគាមិផល ១**
អនាគាមិមគ្គ ១	**អនាគាមិផល ១**
អរហត្តមគ្គ ១	**អរហត្តផល ១**

ដែលជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ អ្នកបដិបត្តិល្អ អ្នកបដិបត្តិត្រង់ អ្នកបដិបត្តិប្រពៃ បដិបត្តិដើម្បីដឹងច្បាស់អរិយ សច្ចធម៌ បដិបត្តិដើម្បីគួរដល់ការថ្វាយបង្គំ ការបូជាជាដើម ។

(ស្រង់ចាកអដ្ឋកថាសុមង្គលវិលាសិនី សាមញ្ញផលសុត្រ) ។

ន័យទី២ សង្ឃក្នុងព្រះវិន័យ សំដៅយកពួកនៃបព្វជិតគឺ ភិក្ខុសាមណេរក្នុងព្រះពុទ្ធសាសនា បើសង្ឃក្នុងសង្ឃកម្មសំដៅយក ភិក្ខុតាំងអំពី៤រូបឡើងទៅ ។

សង្ឃក្នុងពាក្យថា "**សង្ឃទាននេះ**" គួរប្រើបានទាំង២នัយ។

ដូច្នេះ ពាក្យថា "**សង្ឃទាន**" គឺទានដើម្បីសង្ឃ ឬវត្ថុទានដែលបុគ្គលប្រគេនចំពោះសង្ឃ ។

ក្នុងអដ្ឋកថា ខុទ្ទកនិកាយ វិមានវត្ថុ ទុតិយវិមាន ពន្យល់ពាក្យ "**សង្ឃទាន**"ថា "សង្ឃទានមកអំពីភាសាបាលី "**សង្ឃគ្គ ឧក្ខិណា**" (ទានដែលដល់ហើយក្នុងសង្ឃ) "**សង្ឃេ ទានំ ឧស្សាម**" (ឱ្យទានក្នុងសង្ឃ) "**សង្ឃេ ទានានិ ឧក្ខាន**" (ឱ្យទានហើយក្នុងសង្ឃ) "**សង្ឃស្មឹ បតិដ្ឋារេសិ ឧក្ខិណំ**" (រំមែងឱ្យប្រតិស្ឋានទានទុកក្នុងសង្ឃ)".....។

សង្ឃទានមានប៉ុន្មានប្រភេទ ?

ក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ទក្ខិណាវិភង្គសូត្រ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងទានដែលដល់ហើយក្នុងសង្ឃ មាន៧ប្រភេទ គឺ :-

១- ឱ្យទានក្នុងសង្ឃទាំងពីរផ្នែក មានព្រះពុទ្ធជាប្រមុខ

២- ឱ្យទានក្នុងសង្ឃទាំងពីរផ្នែក កាលតថាគតបរិនិព្វានហើយ ។

៣- ឱ្យទានក្នុងព្រះភិក្ខុសង្ឃទាំងអស់

៤- ឱ្យទានក្នុងព្រះភិក្ខុនីសង្ឃទាំងអស់

៥- និមន្តកំណត់ចំនួនភិក្ខុ ឬភិក្ខុនីឡើងអំពីសង្ឃ ហើយឱ្យទាន ។

៦- និមន្តកំណត់ចំនួន ភិក្ខុឡើងអំពីសង្ឃ ហើយឱ្យទាន

៧- និមន្តកំណត់ចំនួន ភិក្ខុនីឡើងអំពីសង្ឃហើយឱ្យទាន

សង្ឃទាន ៧ ប្រភេទនេះ ចំពោះ ៤ ប្រភេទខាងដើម ទ្រង់សំដែងតាមអធ្យាស្រ័យរបស់ទាយក អ្នកដល់ព្រមដោយសទ្ធា និងភោគទ្រព្យ នឹងធ្វើទានដល់សង្ឃទាំងពីរផ្នែក ដោយមិនកំណត់ចំនួនក៏បាន ចំណែកពាក្យខាងចុង ទ្រង់សម្តែងតាមអធ្យាស្រ័យរបស់ទាយកអ្នកមានសទ្ធា តែមិនដល់ព្រមដោយភោគទ្រព្យ នឹងកំណត់ចំនួនភិក្ខុតាមដែលត្រូវការអំពីសង្ឃ ហើយឱ្យទានក៏បាន ។

តាមពុទ្ធវចនៈនេះ ក្នុងបច្ចុប្បន្ន ទាយកអាចធ្វើទានចំពោះសង្ឃបានត្រឹមតែ២ប្រភេទ គឺ ប្រភេទទី៣និងប្រភេទទី៦ ។

ក្នុងព្រះវិន័យ ចុល្លវគ្គ សេនាសនក្ខន្ធកៈ សម្តែងថា សម័យដំបូង ប្រជាជននិយមធ្វើសង្ឃភត្ត (ភត្តដែលធ្វើដល់សង្ឃ) តែសម័យក្រោយមក កើតទុរភិក្សក្នុងក្រុងរាជគ្រឹះ រកបាយបានដោយលំបាក ប្រជាជនមិនអាចធ្វើសង្ឃភត្តបាន ទើបប្រាថ្នាធ្វើឧទ្ទេសភត្ត (ភត្តដែលប្រគេនដល់ភិក្ខុដែលសូមនិមន្ត ចោះចំពោះមកអំពីសង្ឃ) និងភត្តមានឈ្មោះដទៃៗទៀត ភិក្ខុទាំងឡាយទើបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ព្រះអង្គក៏ទ្រង់អនុញ្ញាតទាំងសង្ឃភត្ត ឧទ្ទេសភត្ត និមន្តនភត្ត (ភត្តដែលនិមន្តភិក្ខុបុគ្គល) សលាកភត្ត (ភត្តដែលប្រគេនតាមសលាក) បក្ខិកភត្ត (ភត្តដែលគេប្រគេនតែមួយថ្ងៃ ក្នុងបក្សខាងខ្នើតឬខាងរនោច) ឧបោសថិកភត្ត (ភត្តដែលប្រគេនក្នុងថ្ងៃឧបោសថ) បាដិបទិកភត្ត (ភត្តដែលប្រគេនក្នុងថ្ងៃបាដិបទគឺថ្ងៃ១រោច.១កើត) រួមទាំងភត្តដែលមហា-

ឧបាសិកាវិសាខាសូមពរចំពោះ ព្រះដ៏មានព្រះភាគផង គឺ អាគន្តុកភត្ត (ភត្តដែលប្រគេន ដល់ភិក្ខុទើបមកដល់ថ្មី) គមិកភត្ត (ភត្តដើម្បីភិក្ខុអ្នកធ្វើដំណើរ) គិលានភត្ត (ភត្តដើម្បីភិក្ខុឈឺ) គិលានុប្បដ្ឋាកភត្ត (ភត្តដើម្បីភិក្ខុ អ្នករក្សាភិក្ខុឈឺ) ។

ព្រះបំណងដែលទ្រង់សម្តែងសច្ចអាន

ក្នុងទក្ខិណាវិភង្គសូត្រ មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ព្រះមានព្រះភាគទ្រង់សម្តែងថា "តថាគតមិនមែនពោលនូវទាន ដែលឱ្យដល់បុគ្គលថាមានផលច្រើន ជាងទានដែលឱ្យដល់សង្ឃ ដោយបរិយាយណាមួយឡើយ" ។

ដើមហេតុដែលនាំឱ្យព្រះមានព្រះភាគទ្រង់សម្តែងនូវទក្ខិណាវិភង្គសូត្រនេះ ព្រោះព្រះនាងមហាបជាបតិគោតមីជាមាតុច្ឆា ទ្រង់ប្រាថ្នានឹងថ្វាយសំពត់ថ្មី១គូរ ដែលទ្រង់ត្បាញដោយព្រះអង្គឯងផ្ទាល់ ជាមួយជាងតម្បាញ តែព្រះមានព្រះភាគទ្រង់បញ្ជាឱ្យប្រគេនដល់សង្ឃ សូម្បីព្រះនាងមហាបជាបតិគោតមី និងព្រះអានន្ទ

ក្រាបទូលអង្វរសូមឱ្យទទួលច្រើនគ្រា ព្រះអង្គក៏មិនទ្រង់ ទទួល រហូតដល់ព្រះនាងមហាបជាបតិគោតមីទ្រង់ខូចព្រះទ័យ ព្រះមាន ព្រះភាគទើបទ្រង់សម្តែង បាដិបុគ្គលិកទាន ១៤ យ៉ាង តាំងអំពីឱ្យ ទានដល់សត្វតិរច្ឆានបានផល១០០អត្តភាព រហូតឱ្យទានដល់ ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ដែលមានផលប្រមាណមិនបាន ហើយទ្រង់សម្តែងសង្ឃទាន (**សង្ឃគតា ឧក្ខិណា**) ៧យ៉ាងថា មានអានិសង្សច្រើនជាង ។

ពុទ្ធវចនៈនេះ ក្នុងអដ្ឋកថា ទក្ខិណាវិភង្គសូត្រ ពន្យល់ថា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានព្រះបំណងអនុគ្រោះ ដល់ព្រះនាង មហាបជាបតិគោតមី និងពួកសង្ឃ ដោយទ្រង់មានព្រះតម្រិះ ២ យ៉ាងថា :-

១- ព្រះនាងមហាបជាបតិគោតមី នាងជាអរិយសាវិកាថ្នាក់ សោតាបន្ន រមែងស្គាល់គុណរបស់ពួកភិក្ខុសង្ឃតាមសេចក្តីពិត ទាំង សម័យនោះ ភិក្ខុសង្ឃសុទ្ធតែជាអរិយសាវកដោយច្រើន កាលដែល

ព្រះនាងថ្វាយសំពត់ថ្មី ១ គូនេះ ដល់ព្រះពុទ្ធជាម្ចាស់ ក៏ជាកុសលចេតនាបានតាំងទុកបរិបូណ៌ហើយ តែបើព្រះនាងបានតាំងចេតនាថ្វាយចំពោះពួកសង្ឃម្តងទៀត កាលធ្វើយ៉ាងនេះ ការថ្វាយទានរបស់ព្រះនាង ទើបជាកុសលមានផលមានអានិសង្សច្រើន ព្រោះចេតនាបាន ប្រារព្ធទាំងព្រះពុទ្ធជាម្ចាស់ផង ព្រះសង្ឃផង ។

២- អ្នកមានបញ្ញារមែងដឹងថា ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ជាអគ្គទក្ខិណេយ្យបុគ្គល រកអ្នកឯណាប្រៀបផ្ទឹមមិនបាន អ្នកណាៗ ក៏រមែងប្រាថ្នាថ្វាយទានដល់ព្រះពុទ្ធជាម្ចាស់ តែកាលព្រះតថាគតបរិនិព្វានហើយ សង្ឃនឹងមិនមានអ្នកគោរព មិនមានអ្នកទំនុកបម្រុងបច្ច័យ៤ សង្ឃនឹងលំបាក ហើយសាសនារបស់យើងតាំងនៅក្នុងព្រះសង្ឃ ព្រោះហេតុដូច្នេះ ទើបទ្រង់លើកតម្កើងពួកសង្ឃ ។

លក្ខណៈយ៉ាងណាហៅបានសង្ឃទាន ?

អ្នកដែលធ្លាប់ស្តាប់ព្រះពុទ្ធដីកាថា :- ធ្វើទានក្នុងសង្ឃមានផលច្រើន កាលមិនយល់ព្រះបំណងក្នុងសង្ឃទាន ទើបប្រាថ្នាផល

នៃសង្ឃទានផ្សេងៗ ដូចជា ចង់បានកើតជាមនុស្ស ឬជាទេវតាជាដើម ឬត្រូវទៅស្វែងរកបព្វជិតជាភិក្ខុឱ្យបាន៤រូប ដើម្បីគ្រប់ជាសង្ឃ ហើយក៏ផ្តើមធ្វើសង្ឃទាន មិនបានតិតតម្រង់កុសលចេតនាឱ្យបោះឆ្ពោះទៅក្នុងសង្ឃ ។

ក្នុងអដ្ឋកថា ទក្ខិណាវិភង្គសូត្រ សម្តែងនូវលក្ខណៈរបស់សង្ឃទាន ថា :- កាលបុគ្គលត្រៀមនូវទេយ្យធម៌ ហើយទៅវិហារសូមនិមន្តព្រះថេរៈ ១ រូបអំពីសង្ឃ តែត្រឡប់បានសាមណេរមកអំពីសង្ឃ ក៏កើតទោមនស្ស ទានរបស់បុគ្គលនោះសូម្បីឱ្យហើយក៏មិនដល់សង្ឃ កាលបានព្រះមហាថេរៈមកអំពីសង្ឃ ក៏កើតសោមនស្សរីករាយ ទានដែលឱ្យហើយក៏មិនដល់សង្ឃ ព្រោះមានចិត្តប្រែប្រួលដោយអកុសល តែបើអាចធ្វើសេចក្តីគោរពកោតក្រែងក្នុងភិក្ខុនោះដោយតាំងចិត្តថា "យើងប្រគេនចំពោះសង្ឃ" ទាននោះទើបឈ្មោះថា ដល់សង្ឃ ជាសង្ឃទាន ។

មានតំណាលថា ឧបាសកម្នាក់គាត់តាំងចិត្តនឹងធ្វើសង្ឃទាន

ទើបដើរទៅកាន់វិហារសូមនិមន្តភិក្ខុមួយរូបអំពីសង្ឃ តែត្រឡប់បានភិក្ខុទ្រុស្តសីលមក ឧបាសកនោះ ក៏នាំភិក្ខុនោះទៅកាន់ផ្ទះ ហើយធ្វើកិច្ចលាងជើងនិងលាបដោយប្រេង និមន្តឱ្យអង្គុយលើអាសនៈដែលក្រាលទុកយ៉ាងល្អ ចាត់ចែងចងពិតានខាងលើ បូជាដោយរបស់ក្រអូប ធូប និងផ្កាឈើ បានប្រគេនទេយ្យធម៌ដោយសេចក្តីកោតក្រែងក្នុងសង្ឃ ដូចធ្វើសេចក្តីកោតក្រែងក្នុងព្រះពុទ្ធជាម្ចាស់។ ក្រោយពេលដែលភិក្ខុនោះឆាន់ហើយ បាននិមន្តត្រឡប់ទៅវិហារវិញ ហើយក៏និមន្តមកកាន់ផ្ទះឧបាសកទៀត ពោលថា :- "សូមឧបាសកឱ្យចបដើម្បីប្រយោជន៍ដល់ការបដិបត្តិវត្តក្នុងពេលក្រោយភត្ត" ឧបាសកនោះអង្គុយត្បៀតចបដោយជើង ពោលថា "ចូរទទួលយកចុះទាន!" ។ ពេលនោះ មានអ្នកស្រុកឃើញការធ្វើរបស់ឧបាសកនោះតាំងអំពីព្រឹក ទើបពោលនឹងឧបាសកនោះថា កាលពីព្រឹកមុញ លោកធ្វើសក្ការៈដោយសេចក្តីគោរពដល់ភិក្ខុនេះចុះឥឡូវនេះព្រោះហេតុអ្វី សូម្បីត្រឹមតែមាយាទបន្តិចបន្តួចក៏មិន

មានដែរ ឧបាសកនោះតបថា សេចក្តីគោរពកោតក្រែងគឺខ្ញុំធ្វើចំពោះសង្ឃ មិនមែនធ្វើចំពោះភិក្ខុរូបនេះទេ (ឧបាសកអ្នកឆ្លាតរមែងដឹងថា ភិក្ខុជីកដីតែងខុសក្នុងព្រះវិន័យគឺត្រូវអាបត្តិបាចិត្តិយ) ។

រឿងនេះសម្តែងឱ្យឃើញថា ការឱ្យទានដោយការកោតក្រែងក្នុងសង្ឃ គឺមិនចោះចំពោះភិក្ខុរូបណាមួយទេ ។ ការឱ្យទានក្នុងសង្ឃ រមែងមានផលច្រើនជាងការឱ្យចោះចំពោះភិក្ខុបុគ្គល មែនព្រោះផលរបស់ចិត្តដែលមិនសៅហ្មង ដោយការចោះចំពោះបុគ្គល រមែងប្រណិតជាងចិត្តដែលចោះចំពោះបុគ្គល ។

សេចក្តីក្នុងអដ្ឋកថា ឧទ្ទិស្សទិទាន សម្តែងទុកថា :- បុគ្គលណាធ្វើទានក្នុងសម្មតិសង្ឃ ដោយហោចទៅសូម្បីគោត្រភូសង្ឃ មានចិត្តដៅត្រង់ចំពោះព្រះអរិយសង្ឃ បុគ្គលនោះឈ្មោះថាឱ្យល្អហើយ គោរពបូជាល្អហើយ ជាគ្រឿងបូជាដ៏ធំ ព្រោះទក្ខិណាទាននោះ ចាត់ជាសង្ឃទានដែលមានផលច្រើន ។

(គាត្រភូសង្ឃ សំដៅដល់ភិក្ខុដែលបានទទួលចូលរួមធ្វើ

សង្ឃកម្មតាមព្រះវិន័យ តែមានការប្រព្រឹត្តិ និងមានចិត្តគំនិតដូចជាគ្រហស្ថ មិនសិក្សា មិនបដិបត្តិតាមព្រះធមិ ព្រះវិន័យ សល់ត្រឹមតែចម្រៀកសំពត់ល្បឹងបន្តិចពាក់ទុកត្រង់ត្រចៀក ឬចងកដៃ ទុកជាគ្រឿងសម្គាល់ថា នៅកាន់ភេទជាភិក្ខុ ។ គោត្រភូភិក្ខុ គឺអ្នកដែលឆ្លងគោត្រអំពីគោតភិក្ខុមកជាគ្រហស្ថ មានការរស់នៅដូចជាគ្រហស្ថ តែនៅសម្គាល់ខ្លួនថាជាភិក្ខុ) ។

ជាក់ចាត្រជាសឡឌានឬទេ ?

សូម្បីទាយក នឹងធ្វើទានដល់ភិក្ខុទូទៅទាំងអស់ក្នុងវត្ត ឬនិមន្តចំនួនដែលត្រូវការមកអំពីសង្ឃដើម្បីថ្វាយទាន តែបើមានចិត្តប្រែប្រួល ឬដល់សេចក្តីលំអៀងដោយអគតិទាំង ៤ ឈ្មោះថាមិនគោរពកោតក្រែងចំពោះសង្ឃ ទានដែលធ្វើនោះ ទើបមិនដល់សង្ឃ មិនជាសង្ឃទាន ។

តែសូម្បីទាយកមិនបាននិមន្តភិក្ខុមកអំពីសង្ឃ ជួបភិក្ខុតាមផ្លូវ ឬភិក្ខុត្រាច់និមន្តបិណ្ឌបាតឆ្លងកាត់មុខផ្ទះ ប្រគេនទេយ្យធមិ

ដោយ តាំងចិត្តឧទ្ទិសចំពោះអរិយសង្ឃ មានសេចក្តីគោរពកោត ក្រែងចំពោះភិក្ខុរូបនោះ ដូចនៅចំពោះមុខអរិយសង្ឃ ឬដូចភិក្ខុរូប នោះជាព្រះអរិយសង្ឃ ទាននោះក៏ជាសង្ឃទាន ។

ដូច្នេះសង្ឃទាន សំដៅយកចេតនានៃអ្នកឱ្យជាវត្ថុសំខាន់ បំផុត កាលមានចេតនាបាញ់ត្រង់ឆ្ពោះអរិយសង្ឃ ហើយកំណត់នូវ គុណរបស់អរិយសង្ឃបានពិត។ ហើយប្រគេននូវទេយ្យវត្ថុដល់ បដិគ្គាហកៈ ជាបព្វជិតសូម្បីជាសាមណេរ អ្នកបូសហើយក្នុងថ្ងៃ នោះ ដោយចិត្តគោរពកោតក្រែងចំពោះអរិយសង្ឃ ចេតនារបស់ ទាយកនោះ រមែងដល់អរិយសង្ឃផង ដល់សម្មតិសង្ឃផង ។

ពាក្យវេរសឲ្យទាន

ប្រពៃណីដែលពោលពាក្យវេរសង្ឃទានថា ឃយំ ភន្តេ ឥមានិ ខាទនិយភោជនិយាទីនិ សង្ឋេត្វា ភិក្ខុសឲ្យស្ស ទេម សាធុ នោ ភន្តេ សឲ្យោ ឥមានិ ខាទនិយភោជ និយាទីនិ បដិគ្គណ្ហតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ

សុខាយ ។ ឧតិយម្បិ... ។ តតិយម្បិ... ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្ការបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយក នូវវត្ថុទាំងឡាយ មានបង្អែមនិងចម្ការបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជា ប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។ .....អស់វារៈពីរដងផង ។ .....អស់វារៈបីដងផង ។

ពាក្យវេរសង្ឃទាននេះ មិនមានក្នុងព្រះតៃបិដកនិងអដ្ឋកថា តែលោកអ្នកចេះភាសាបាលីតែងឡើងក្នុងកាលខាងក្រោយ ដើម្បីឱ្យកើតសេចក្តីព្រមព្រៀងគ្នា ក្នុងខណៈដែលទាយកជាម្ចាស់ទានច្រើនគ្នា ប្រគេនទានចំពោះសង្ឃ ។



ទានប្រកបដោយអង្គ៦ទើបមានផលច្រើន

ចេតនារបស់អ្នកឱ្យប្រកបដោយអង្គ៣ គឺ

១- **បុព្វចេតនា** មានចេតនាជាកុសល មុនធឺងឱ្យ

២- **មុញ្ចនចេតនា** មានចេតនាជាកុសល ខណៈកំពុងឱ្យ

៣- **អបរចេតនា** មានចេតនាជាកុសល ក្រោយពីឱ្យហើយ

បដិគ្គាហកៈ(អ្នកទទួល)ប្រកបដោយអង្គ៣

១- ជាអ្នកប្រាសចាករាគៈ ឬជាអ្នកបដិបត្តិដើម្បីប្រាសចាករាគៈ ។

២- ជាអ្នកប្រាសចាកទោស ឬជាអ្នកបដិបត្តិដើម្បីប្រាសចាកទោសៈ ។

៣- ជាអ្នកប្រាសចាកមោហៈ ឬជាអ្នកបដិបត្តិដើម្បីប្រាសចាកមោហៈ ។ (ភិក្ខុឬសាមណេរ អ្នកដល់ព្រមដោយសីល និងវត្ត ឈ្មោះថា ជាអ្នកបដិបត្តិដើម្បីប្រាសចាករាគៈ ទោសៈ មោហៈ) ។

ការធ្វើទានដែលប្រកបដោយអង្គ៦នេះ រមែងឱ្យផលបរិបូណ៌តែកាលជ្រើសចោះចំពោះបុគ្គលហើយឱ្យ ក៏ជាបាដិបុគ្គលិកទាន ចិត្តរមែងមិនស្មើក្នុងពួកភិក្ខុសង្ឃ ព្រោះហេតុដូច្នោះ សង្ឃទានទើបឱ្យផលបរិបូណ៌ក្រៃលែងជាង ព្រោះមិនជ្រើសបុគ្គល មានចិត្តកោតក្រែងចំពោះសង្ឃ និងបង្អោនរលីកដល់គុណព្រះអរិយសង្ឃ។ ហេតុដូច្នោះ សាធុជនជាទាយកទាយិកា គួរបង្អោនចិត្តរលីកកោតក្រែងចំពោះភិក្ខុសង្ឃ ក្នុងខណៈដែលឱ្យទាន ខណៈនោះឈ្មោះថា ជាសង្ឃទាន ដោយមិនបាច់ពោលពាក្យវែកបាន ។

ក្នុងអដ្ឋកថា ខុទ្ទកនិកាយ កុម្មាសបិណ្ឌជាតក សម្តែងថា ទក្ខិណាទានដែលទាយក បានកំណត់គុណរបស់សមណព្រាហ្មណ៍ទាំងឡាយ អ្នកមានគុណ ហើយញុំាងចិត្តឱ្យជ្រះថ្លា ញុំាងចេតនាទាំងពាឱ្យផូរផង់ សង្ឃឹមការកើតឡើងនៃផល ហើយទើបឱ្យទានរមែងមានផលមិនតិច គឺរមែងបានសម្រេចនូវមហាសម្បត្តិ (រាជសម្បត្តិ) ក្នុងទីដែលកើតហើយ ។

សង្ឃទានក្នុងព្រះវិន័យ

ព្រះមានព្រះភាគជាម្ចាស់ទ្រង់បំពាក់ឱ្យសង្ឃទូទៅមានសិទ្ធិក្នុងការប្រើប្រាស់បច្ច័យ៤ ទើបទ្រង់អនុញ្ញាតឱ្យសង្ឃប្រជុំគ្នាចែកបច្ច័យណា ដែលទាយកបន្ធឹវាចាប្រគេនចំពោះសង្ឃ រឿរតែវត្ថុជាគរុភណ្ឌ អាចចែកស្មើទូទៅដល់ភិក្ខុទាំងពួង គឺភិក្ខុទាំងឡាយមានសិទ្ធិជាធំ ឬជាម្ចាស់លើបច្ច័យទាំងនោះ ។ ប្រសិនបើបច្ច័យណាដែលទាយកបញ្ចេញវាចាប្រគេនចំពោះភិក្ខុបុគ្គលរូបណាមួយ ភិក្ខុរូបនោះប៉ុណ្ណោះ មានសិទ្ធិជាម្ចាស់ឬជាធំក្នុងបច្ច័យនោះ ។

បើទាយកប្រគេនបច្ច័យ៤ទៅខាងក្រៅវត្តដល់ភិក្ខុរូបណាមួយ ដោយពោលពាក្យឧទ្ទិសចំពោះសង្ឃ បច្ច័យនោះរមែងធ្លាក់ជារបស់សង្ឃ ឬសម្បត្តិសង្ឃ បើមិនមានភិក្ខុដទៃនៅក្នុងវត្ត ភិក្ខុគប្បីធ្វើនយកម្មកាន់យកវត្ថុនោះឱ្យជារបស់បុគ្គលសិនចុះ ដើម្បីត្រឹមត្រូវនឹងផ្តតចាកទោសក្នុងព្រះវិន័យ ។

សរុបសេចក្តីមក ការឡើងកាសង្ឃអានបាន អាស្រ័យលើ

ទាយកជាម្ចាស់ទាន បានតាំងចិត្តឧទ្ទិសដល់ព្រះអរិយសង្ឃ ហើយ
ឱ្យក្នុងសម្មតិសង្ឃ សូម្បីថ្នាក់គោត្រភូសង្ឃក៏ដោយ ក៏ឈ្មោះថា
ជាសង្ឃទានមានផលច្រើន ព្រោះទាននោះ យើងមិនបានឧទ្ទិស
ចំពោះបុគ្គលអ្នកទទួលនោះទេ បុគ្គលអ្នកទទួលនោះគ្រាន់តែ
តំណាងឱ្យព្រះអរិយសង្ឃប៉ុណ្ណោះ ។

អានិសង្សនៃសង្ឃទាន

ក្នុងខុទ្ទកនិកាយ វិមានវត្ថុ ទុតិយវិមាន មានរឿងបងប្អូនស្រីពីរ
នាក់ ក្នុងត្រកូលឧបដ្ឋាករបស់ព្រះរេវតត្ថេរៈ ក្នុងនាលកគ្រាម ។
បងឈ្មោះ **តង្កា** ប្អូនឈ្មោះ **សុតង្កា** កាលក្រោយមក នាងជាបង
បានទៅកាន់ត្រកូលស្វាមីមុន នាងជាស្ត្រីឆ្លាតមានសទ្ធាជ្រះថ្លាក្នុង
ព្រះរតនត្រៃ តែនាងជាស្ត្រីគ្មានបុត្ត នាងគិតថា វង្សត្រកូលរបស់
ស្វាមីអ្នកមិនមានបុត្ត រមែងសាបសូន្យ ។ កាលពន្យល់ណែនាំស្វាមី
ឱ្យយល់ព្រមហើយ ក៏ទៅនាំនាងសុភទ្ទាប្អូនមកធ្វើជាភរិយាផង ។

កាលបងប្អូនបានមកនៅរួមត្រកូលស្វាមីជាមួយគ្នា នាងភទ្ទា

តែងពន្យល់ណែនាំឱ្យនាងសុភទ្ទាវីកភាយត្រេកអរក្នុងការឱ្យទាននិង
មិនប្រមាទក្នុងការប្រព្រឹត្តិធម៌ ថែមទាំងប្រាប់អានិសង្សផងថា :-
បើបដិបត្តិបានយ៉ាងនេះ ក៏និងបាននូវសេចក្តីសុខក្នុងលោកទាំងពីរ ។
នាងសុភទ្ទាជាអ្នកប្រដៅងាយ តាំងនៅក្នុងឱវាទរបស់បងស្រីដោយ
គោរព បដិបត្តិតាមរឿយៗ ។

ថ្ងៃមួយនាងសុភទ្ទា បាននិមន្តភិក្ខុ៨រូប មានព្រះរេវតត្ថេរៈ
ជាប្រធាន ដើម្បីប្រគេនភត្តាហារ ។ ព្រះថេរៈមានបំណងអនុគ្រោះ
នាងសុភទ្ទា ទើបណែនាំឱ្យនាងសុភទ្ទាឱ្យទានក្នុងសង្ឃ នាងក៏ធ្វើ
តាមឱវាទនោះ ព្រះថេរៈទើបនាំភិក្ខុ៧រូបអំពីសង្ឃទៅកាន់ផ្ទះនាង
សុភទ្ទា នាងសុភទ្ទាមានចិត្តជ្រះថ្លាអង្គាសព្រះរេវតៈ និងភិក្ខុទាំង
នោះដោយខាទនីយនិងភោជនីយាហារ ដោយដៃរបស់ខ្លួនឯង ព្រះ
ថេរៈឆាន់ស្រេចហើយ ក៏និមន្តត្រឡប់ជាមួយភិក្ខុទាំងឡាយ
នោះ ។

កាលខាងក្រោយមក នាងសុភទ្ទាអស់ជីវិតទៅ ក៏ទៅកើត

ជាទេវធីតាក្នុងស្ថានសួគ៌ជាន់និម្មានរតី (ជាន់ទី៥) ចំណែកនាងភទ្ទា ជាបង បានឱ្យទានក្នុងបុគ្គល កាលអស់ជីវិត ក៏ទៅកើតជាបរិវារ របស់សក្កទេវរាជ ជាស្តេចធំលើទេវតាស្ថានតាវតឹង្ស (ជាន់ទី២) ។

ស្ថានសួគ៌ ទាំងអស់មាន៦ គឺ :- ១ **ចាតុម្មហារាជិកា** ២ **តាវតឹង្ស** ៣ **យាមា** ៤ **តុសិត** ៥ **និម្មានរតី** ៦ **បរនិម្មិតវសវត្តី** សេចក្តីសុខប្រណិតរបស់អារម្មណ៍ដែលជាទិព្វ ផ្សេងគ្នាតាមលំដាប់ ។

រឿងនេះសម្តែងឱ្យឃើញថា ការឱ្យទានធ្វើសេចក្តីគោរពក្នុងសង្ឃ មិនចោះចំពោះភិក្ខុបុគ្គលណាមួយ តឹឱ្យទានក្នុងសង្ឃពិតៗ រមែងមានផលច្រើនជាង ។

សេចក្តីសង្ខេបក្នុង អង្គុត្តរនិកាយ នវកនិបាត វេលាមសូត្រ មានរឿងរ៉ាវថា លោកអនាថបិណ្ឌិកគហបតី ជាឯតទគ្គលើសឧបាសកទាំងឡាយអ្នកឱ្យទាន ជាអ្នកឧបដ្ឋាកទំនុកបម្រុងព្រះពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃដោយបច្ច័យ៤ កសាងវត្តជេតពនអស់

ទ្រព្យ៥៤កោដិ ដោយទិញដីអស់១៨កោដិ តម្លៃកសាងអស់ ១៨កោដិ ពេលសម្ភោធឆ្លងវិហារអស់១៨កោដិ លោកអនាថ បិណ្ឌិកសេដ្ឋីពេញចិត្តត្រេកអរក្នុងការឱ្យទាន ដោយប្រាសចាក សេចក្តីកំណាញ់ ព្រោះជាអរិយសាវក ថ្នាក់សោតាបន្ន រហូតអស់ ទ្រព្យព្រមជាមួយអកុសលកម្មក្នុងអតីតឱ្យផល ធ្វើឱ្យរណ្តៅទ្រព្យ ដែលកប់ទុកវិនាសអស់ទៅ និងត្រូវពួកអ្នកជំនួញបោកប្រាស់ ហាន: របស់លោកត្រូវធ្លាក់ទាបចុះ ប៉ុន្តែគាត់នៅ តែឱ្យទានរឿយៗ ជានិច្ច មិនដាច់ ដោយការជឿកម្ម និងផលរបស់ កម្មយ៉ាងមាំមួន ។

ថ្ងៃមួយ ព្រះមានព្រះភាគត្រាស់សួរ លោកអនាថបិណ្ឌិក គហបតីថា ម្នាលគហបតី ទានក្នុងត្រកូលរបស់អ្នកនៅតែឱ្យដែរឬ ? លោកអនាថបិណ្ឌិកតបថា បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូល របស់ខ្ញុំព្រះអង្គនៅតែឱ្យដែរ តែទាននោះឯងសៅហ្មង គឺបាយចុង អង្ករនិងទឹកជ្រក់ជាគម្រប់ពីរ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី បុគ្គលឱ្យទាន

សៅហ្មងក្តី ឱ្យទានថ្លៃថ្លាក្តី តែឱ្យទាននោះមិនគោរព មិនធ្វើសេចក្តីកោតក្រែងហើយឱ្យ មិនឱ្យដោយខ្លួនឯងគឺបោះឱ្យ យល់ថាមិនមានផលហើយឱ្យ វិបាករបស់ទាននោះ។ កើតក្នុងត្រកូលណា។ មិនមានចិត្តបង្អោនទៅដើម្បីបរិភោគភោជនាហារដ៏ថ្លៃថ្លាមិនបង្អោនទៅ ដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា មិនបង្អោនទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា មិនបង្អោនទៅដើម្បីប្រើប្រាស់កាមគុណដ៏ថ្លៃថ្លា ម្យ៉ាងទៀត ពួកជនណា ជាកូនក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ រមែងមិនផ្ចង់ត្រចៀកស្តាប់ តែងបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ ។ ដំណើរនោះព្រោះ ហេតុអ្វី ? ម្នាលគហបតី ព្រោះវិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើដោយសេចក្តីមិនគោរព រមែងមានយ៉ាងនេះ ។

ម្នាលគហបតី បុគ្គលឱ្យទានសៅហ្មងក្តី ថ្លៃថ្លាក្តី តែឱ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឱ្យ ឱ្យដោយដៃខ្លួនឯងគឺមិនបោះឱ្យ យល់ថាមានផលហើយទើបឱ្យ វិបាកនៃទាននោះ។

កើតក្នុងត្រកូលណា។ ចិត្តក៏រមែងបង្ហោនទៅដើម្បីបរិភោគភោជនី យាហារដ៏ថ្លៃថ្លា បង្ហោនទៅដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា បង្ហោន ទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា បង្ហោនទៅដើម្បីប្រើប្រាស់ កាមគុណ ៥ ដ៏ថ្លៃថ្លា ម្យ៉ាងទៀត ពួកជនណា ជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះ រមែង ផ្ទង់ត្រចៀកស្តាប់ មិនបញ្ចូនចិត្តទៅកាន់អារម្មណ៍ដទៃឡើយ ។ ដំណើរនោះព្រោះហេតុអ្វី ? ម្នាលគហបតី ព្រោះថាវិបាករបស់ កម្មទាំងឡាយដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។

កុសលដែលមានផលក្រៃលែងជាងសឡឋាន

ព្រះមានព្រះភាគទ្រង់សម្តែងបន្ត ដោយទ្រង់នាំរឿងក្នុង អតីតជាតិ ដែលព្រះអង្គទ្រង់សោយព្រះជាតិជាវេលាមព្រាហ្មណ៍ បានពិចារណាឃើញដោយបញ្ញាថា ទ្រព្យសម្បត្តិទាំងនេះ មិនមាន សារៈ មិនអាចជាប់តាមខ្លួនទៅបរលោកបានឡើយ កាលអស់ជីវិត ហើយ ដូចបុព្វជនដែលលោកទៅខ្លួនទទេ កាលប្រាថ្នានឹងកាន់យក

សារៈ អំពីវត្ថុដែលថ្លានសារៈ ទើបធ្វើមហាទាន ។

ក្នុងមហាទាននោះ វត្ថុណាមួយដែលជនទាំងឡាយត្រូវការ ឈ្មោះថាខ្វះខាតរមែងមិនមាន ដូចជា មាស ប្រាក់ ដីរ សេះ គោ ស្រីក្រមុំ កែវមណី កុណ្ឌល បល្ល័ង្ក សំពត់ ខាទនីយភោជនីយាហារ ។ល។ មួយមុខៗ ៨៤០០ វត្ថុ ។

វេលាមព្រាហ្មណ៍ធ្វើមហាទានដូចទឹកហូរក្នុងស្ទឹង អស់រយៈពេល៧ឆ្នាំ៧ខែ តែទាននោះមិនមានទក្ខិណេយ្យបុគ្គលដែលបរិសុទ្ធសូម្បីត្រឹមតែម្នាក់ បដិគ្គាហកៈសុទ្ធតែជាលោកិយមហាជនទាំងអស់ ។ ទើបព្រះមានព្រះភាគទ្រង់សម្តែងផលនៃកុសលក្រៃលែងឡើងតាមលំដាប់ថា ទានដែលបុគ្គលធ្វើចំពោះអរិយបុគ្គល ថ្នាក់សោតាបន្តត្រឹមតែម្នាក់មានផលច្រើន ជាងវេលាមព្រាហ្មណ៍ឱ្យហើយអស់ ៧ ឆ្នាំ ៧ ខែនោះ។ ទានដែលបុគ្គលធ្វើហើយចំពោះ សកទាគាមីម្នាក់មានផលច្រើនជាងធ្វើហើយដល់សោតាបន្ត១០០នាក់ ទានដែលបុគ្គលថ្វាយហើយចំពោះអនាគាមីម្នាក់.....អរហន្តមួយរូប .....ព្រះបច្ចេកពុទ្ធមួយអង្គ..... ទានដែលបុគ្គលថ្វាយហើយដល់

ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ មានផលច្រើនជាងទានថ្វាយចំពោះព្រះបច្ចេកពុទ្ធ១000អង្គ ទានដែលបុគ្គលថ្វាយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រមុខ មានផលច្រើនជាងទានដែលបុគ្គលថ្វាយចំពោះព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ។ ការដែលបុគ្គលកសាងវិហារប្រគេនសង្ឃមកអំពីទិសទាំង៤ មានផលច្រើនជាងទាន (និច្ចភត្ត) ដែលថ្វាយសង្ឃមានព្រះពុទ្ធជាប្រមុខ ការដែលបុគ្គលមានចិត្តជ្រះថ្លានូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ មានផលច្រើនជាងទានដែលបុគ្គលកសាងវិហារប្រគេនព្រះសង្ឃមកអំពីទិសទាំង៤ ការដែលបុគ្គលមានចិត្តជ្រះថ្លាចំពោះព្រះរតនត្រៃ ហើយសមាទានសិក្ខាបទទាំង៥ (សីល៥) មានផលច្រើនជាងការដល់ព្រះរតនត្រៃជាសរណៈ ការដែលបុគ្គលចម្រើនឆ្លូវមេត្តាចិត្ត (សមថភាវនា) ដោយហោចសូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ មានផលច្រើនជាងការដែលបុគ្គលមាន ចិត្តជ្រះថ្លាក្នុងព្រះរតនត្រៃ ហើយសមាទានសិក្ខាបទទាំង៥ ។ ទីបំផុតព្រះអង្គទ្រង់សម្តែងថា :- ការដែលបុគ្គលចម្រើនឆ្លូវវិបស្សនាមានផលច្រើនជាងការ

ដែលបុគ្គលចម្រើនមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះ
គោនោះទៀត ។ ដូច្នេះ ការអប់រំចម្រើនវិបស្សនាជាកុសលដែល
មិនមានកុសលដទៃណាប្រៀបផ្ទឹមបាន ព្រោះជាការចម្រើនបញ្ញាឱ្យ
ឃើញច្បាស់នូវព្រះនិញ្ចាន ដែលជាធមិរលត់ទុក្ខទាំងពួង ។ ដូច្នេះ
ផល ឬអានិសង្សខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា ទើបមិនមែនជាការ
បាននូវបញ្ចកាមគុណ ឬឥដ្ឋារម្មណ៍ ជារបស់ទិញ្ចទេ ។ តែដែលពិត
ដើម្បីអស់ទៅនៃកិលេសដោយសមុច្ឆេទប៉ុណ្ណោះ ។

ការចម្រើនកុសលដែលមានអានិសង្សច្រើន គឺជាកុសល
ដែល ប្រព្រឹត្តទៅដើម្បីដុះខាត់កិលេស បើលះកិលេសបានច្រើន
ប៉ុណ្ណា ផលក៏ប្រណិតឡើងតាមលំដាប់នោះ តែបើនៅមានសេចក្តី
យល់ខុសថា ធ្វើកុសលដើម្បីត្រូវការផល ក៏មិនមានផលឬអានិសង្ស
ច្រើនប៉ុនគ្នានឹងកុសលដើម្បីដុះខាត់កិលេសដែរ ព្រោះជាកុសលនៅ
លាយឡំដោយសេចក្តីសៅហ្មង មានលោភ:និងសេចក្តីវង្វេងជាដើម។

សេចក្តីសំខាន់ គឺមិនមែនធ្វើសង្ឃទានដើម្បីសង្ឃឹមផល ឬ
អានិសង្សច្រើននោះទេ តែដែលសំខាន់បំផុត ត្រូវស្តាប់ព្រះធមិ

ពិសេសព្រះវិន័យរបស់ព្រះសង្ឃឱ្យយល់ចូលចិត្ត ហើយធ្វើសេចក្តីគោរពកោតក្រែងក្នុងព្រះសង្ឃ កាលបើដូច្នោះ ទានដែលឱ្យដល់សង្ឃ រមែងជាសង្ឃទាន សូម្បីមិនបាច់បញ្ចេញវាចាប្រតេន ។

ព្រះវិន័យដែលទាក់ទងក្នុងការធ្វើទាន

ដើម្បីសេចក្តីឆ្លាតវាងវៃក្នុងការធ្វើទាន ឬចំនុកបម្រុងដល់ព្រះភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ជៀសវាងការខុសឆ្គាំឆ្គងក្នុងព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ឱ្យសមថា យើងជាអ្នកកាន់ព្រះពុទ្ធសាសនា គឺកាន់ធម៌កាន់វិន័យរបស់ព្រះពុទ្ធ ។ ម្យ៉ាងទៀត ដើម្បីអនុគ្រោះដល់ព្រះភិក្ខុអ្នកមានសីលជាទីស្រឡាញ់ផង ខ្ញុំព្រះករុណាអាត្មាភាព នឹងសូមនាំយកបកិណ្ណកៈវិន័យខ្លះៗមកសរសេរបន្តទៅទៀត ដើម្បីប្រយោជន៍ដល់ការចេះដឹងរបស់ពុទ្ធបរិស័ទដូចតទៅ :-

ការបដិបត្តិក្នុងវត្ថុពុទ្ធបូជា[1]

សម័យពុទ្ធកាល ទាយកតែងថ្វាយទានដល់សង្ឃទាំង ២ផ្នែក មានព្រះពុទ្ធជាប្រធាន គឺព្រះមានព្រះភាគទ្រង់គង់នៅត្រង់កណ្តាល ភិក្ខុសង្ឃអង្គុយខាងស្តាំ ភិក្ខុនីសង្ឃអង្គុយខាងឆ្វេង ព្រះពុទ្ធជាម្ចាស់ជាប្រធាននៃសង្ឃទាំង២ផ្នែក ទ្រង់បរិភោគបច្ច័យដោយព្រះអង្គឯងខ្លះ ទ្រង់ឱ្យដល់ភិក្ខុទាំងឡាយខ្លះ ដោយឡែកបច្ចុប្បន្ននេះ មានតែភិក្ខុសង្ឃប៉ុណ្ណោះ បើមានទាយកអ្នកឆ្លាត បានតម្កល់ព្រះពុទ្ធរូប ឬចេតិយបញ្ចុះព្រះសារីរិកធាតុ ហើយថ្វាយទានដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រមុខ ដោយពោលថា "សូមថ្វាយវត្ថុនេះដល់ព្រះពុទ្ធជាម្ចាស់" ដូច្នេះ វត្ថុទាំងនោះ បើជាសំពត់ ឬផ្កាឈើ គ្រឿងក្រអូប គ្រឿងប្រទីបជាដើម គប្បីបូជាព្រះពុទ្ធរូប ឬព្រះចេតិយ ចំណែកអាហារបិណ្ឌបាត ឬភេសជ្ជៈ គប្បីប្រគេនដល់បព្វជិត ឬគ្រហស្ថណាមួយ អ្នកមើលថែរក្សា បើមិនមាន គប្បីធ្វើវត្ត (មានបោសសម្អាតជាដើម) មុនសិន ហើយសឹមបរិភោគចុះ ។ តែបើ

(១) ស្រង់ចាកអដ្ឋកថា សមន្តប្បាសាទិកា ចីវរក្ខន្ធក:

ក្បែកពេលហើយ (អ្នករក្សាវិកាលសិក្ខាបទ) បរិភោគហើយ ធ្វើវត្ត
ពេលក្រោយក៏បាន ។

វត្ថុគួរ និង មិនគួរប្រគេន

ភិក្ខុសង្ឃក្នុងធម្មវិន័យ នឹងទទួលប្រគេនតែអាហារដែល
សម្រេចហើយ អាចឆាន់បានក្នុងថ្ងៃនោះប៉ុណ្ណោះ ព្រោះទ្រង់បញ្ញត្ត
វិន័យមិនឱ្យភិក្ខុចម្អិនអាហារឆៅ មិនឱ្យភិក្ខុសន្សំអាហារទុកវត្ថុ
ទាំងនេះសុទ្ធតែ មានទោសចំពោះភិក្ខុទាំងអស់ ។

តែទ្រង់អនុញ្ញតឱ្យមានកប្បិយកុដិ (កុដិសមគួរ) សម្រាប់
ទុកដាក់អាហារវត្ថុ ដូចជាអង្ករ ឬអាហារក្រៀមជាដើមបាន មិនជា
សន្និធិ (ការសន្សំ) ទើបមិនខុសក្នុងវិន័យ ព្រោះការសន្សំអាហារ ។
តាមប្រក្រតីតែងមានភិក្ខុបានទទួលសម្មតិឱ្យជាអ្នករក្សាឃ្លាំង
(ភណ្ឌាគារកៈ) និងមានវេយ្យាវច្ចករឬសាមណេរ ចាត់ចែងដាំស្លួ ។

វត្តដែលមិនមានកប្បិយកុដិ បើទាយកបំណងប្រគេនអង្ករ
ឬអាហារក្រៀម ដើម្បីទុកឆាន់ក្នុងពេកព្រឹកឡើង គួរប្រគល់ឱ្យ

វេយ្យាវច្ចករឬសាមណេរ មិនគួរប្រគេនភិក្ខុឱ្យលោកទុកដាក់ឡើយ បើលោកទទួលទុកដាក់ដើម្បីឆាន់ថ្ងៃក្រោយ ភិក្ខុគ្រប់រូបដែលឆាន់អាហារនោះ ទីងត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់អាហារដែលសន្សំទុក បើទុកអាហារនោះក្នុងកន្លែងនៅ (សំដៅដល់កុដិដែលសឹងមិនមែនកប្បិយកុដិ) កាលឆាន់អាហារនោះជាអាបត្តិទុក្កដទ្បើត ផងព្រោះឆាន់អាហារដែលទុកដាក់ក្នុងកន្លែងនៅ (អន្តោវុត្ថ) បើអាហារនោះជារបស់ដៅ សាមណេរឬវេយ្យាវច្ចករ យកមកធ្វើការចម្អិនក្នុងកន្លែងនៅរបស់ភិក្ខុ កាលភិក្ខុឆាន់អាហារនោះ ជាអាបត្តិទុក្កដទ្បើត ព្រោះឆាន់អាហារដែលចម្អិនក្នុងកន្លែងនៅ (អន្តោបក្ខៈ) បើភិក្ខុជាអ្នកចម្អិនដោយខ្លួនឯង កាលឆាន់អាហារនោះជាអាបត្តិទុក្កដទ្បើត ព្រោះឆាន់អាហារដែលចម្អិនដោយខ្លួនឯង (សាមបក្ខៈ) ។

នៅមានវិន័យក្រៅអំពីនេះទ្បើត គឺ :-

ភិក្ខុនីងឆាន់អាហារ ឬ វត្ថុដែលគប្បីលេបកន្លងបំពង់កចូលទៅ ដូចជាអាហារឬថ្នាំផ្សេងៗបាន លុះត្រាតែបានទទួលប្រគេន

អំពីអនុបសម្បន្ន (គ្រហស្ថឬសាមណេរ) ត្រឹមត្រូវតាមអង្គប្រតេន ក្នុងព្រះវិន័យ ។

អង្គនៃការប្រគេន៥យ៉ាងគឺ

១- វត្ថុនោះជារបស់ដែលបុរសមានកម្លាំងកណ្តាល លើកឡើងបាន (ចំពោះអាហារដែលភិក្ខុគប្បីឆាន់តាមផ្លូវមាត់ប៉ុណ្ណោះ ដែលត្រូវប្រគេន ទេយ្យវត្ថុដទៃដូចជា សំពត់ ក្រដាសជូត កែវ ចាន ស្លាបព្រា ជារបស់ប្រើប្រាស់ខាងក្រៅ មិនចាំបាច់ប្រគេនក៏បាន) ។

២- ទាយកស្ថិតនៅក្នុងហត្ថបាស (ហត្ថបាស ប្រែថា អន្លាក់ដៃ គឺស្មើ ២ហត្ថ១ចំអាម អំពីខាងក្រោយបំផុតរបស់ភិក្ខុ ដល់ខាងមុខរបស់ទាយក មិនរាប់យកដៃទាយកដែលលាតចេញប្រគេន) ។

៣- ទាយកធ្វើអាការៈបង្ហោនប្រគេនដោយសេចក្តីគោរព។

៤- ជាអនុបសម្បន្នណាមួយ ទោះជាទេវតា ឬមនុស្សមិនថាជាបុរស ឬស្ត្រី ដោយហោចសូម្បីសត្វតិរច្ឆានជាអ្នកប្រគេន ។

៥- ភិក្ខុទទួលប្រគេនដោយកាយ ឬវត្ថុដែលជាប់ដោយ កាយ ដូចជា សំពត់ ឬស្លឹកឈើ ជាដើម ។

បើការប្រគេនមិនគ្រប់អង្គ ៥ ចាត់ថារបស់នោះមិនបានទទួលប្រគេន ភិក្ខុឆាន់របស់នោះឱ្យកន្លងបំពង់កចូលទៅ ត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់អាហារដែលមិនបានទទួលប្រគេន ។

ការប្រគេនចង្ហាន់ចំពោះភិក្ខុសង្ឃ

តើស្ត្រីអាចប្រគេនបានឬទេ ?

តាមអង្គរបស់ការប្រគេនទី ១ ទី ៤ និង ទី ៥ ស្ត្រីក៏អាចប្រគេនវត្ថុដល់ព្រះភិក្ខុបាន ទាំងភិក្ខុក៏អាចទទួលប្រគេនដោយដៃទទេបាន ។ បើភិក្ខុទទួលដោយមានតម្រេក (ចិត្តមានរាគៈចង់ប៉ះពាល់កាយ) ត្រូវអាបត្តិថុល្លច្ច័យ ព្រោះចាប់ត្រូវវត្ថុដែលជាប់កាយស្ត្រី បើពាល់ត្រូវ ឬចាប់ត្រូវកាយស្ត្រីដោយចិត្តតម្រេក ត្រូវអាបត្តិសង្ឃាទិសេស (អាបត្តិរងអំពីអាបត្តិបារាជិក) សូម្បីប្រើសំពត់ទទួលប្រគេនអំពីស្ត្រី បើមានចិត្តតម្រេក ក៏ត្រូវអាបត្តិទុក្កដ ព្រោះចាប់ត្រូវវត្ថុដែលជាប់ដោយកាយស្ត្រី ដោយវត្ថុជាប់ដោយកាយខ្លួន បើចាប់ត្រូវកាយស្ត្រីដោយមិនមានតម្រេក តែដឹងថាជាស្ត្រី ដូចចាប់ត្រូវមាតា ឬញាតិបងប្អូនស្រី ត្រូវអាបត្តិទុក្កដ ព្រោះចាប់ត្រូវវត្ថុអនាមាស (វត្ថុដែលមិនគួរចាប់ប៉ះ) ។ ភិក្ខុចាប់កាយស្ត្រីដោយចៃដន្យមិនមានចេតនានឹងចាប់ត្រូវ មិនមានអាបត្តិ ។ ស្ត្រីចាប់ត្រូវកាយភិក្ខុ សូម្បីភិក្ខុមានតម្រេក តែមិនមានសេចក្តី

ព្យាយាមទទួលសម្ផស្ស គឺមិនកម្រើកកាយ ក៏នៅមិនត្រូវអាបត្តិ តែបើមានការកម្រើកកាយដើម្បីទទួលដឹងសម្ផស្សកាលណា ត្រូវអាបត្តិ សង្ឃាទិសេសកាលនោះ ។

ភិក្ខុអាចឱ្យស្ត្រីចាក់ថ្នាំព្យាបាលជម្ងឺបាន តែត្រូវសង្រួមប្រយ័ត្នចិត្ត ដើម្បីការពារកិលេសដែលនឹងមានបច្ច័យឱ្យកើតបាន ។ ដូច្នេះ យកល្អគួរឱ្យពេទ្យប្រុសចាក់ថ្នាំឱ្យវិញ ។

អាហារដែលភិក្ខុនៅមិនបានទទួលប្រគេនអំពីអនុបសម្បន្ន ភិក្ខុនឹងចាប់ពាល់មុនមិនបាន បើចាប់ពាល់ហើយ សូម្បីអនុបសម្បន្ននាំមកប្រគេនខ្លួនឯងក្នុងកាលក្រោយ ភិក្ខុឆាន់អាហារនោះត្រូវអាបត្តិទុក្កដ ព្រោះឆាន់អាហារដែលចាប់ពាល់មុនទទួលប្រគេន (ទុរុបចិណ្ណៈ) តែបើនាំទៅប្រគេនភិក្ខុដទៃ ភិក្ខុដទៃឆាន់បាន តែអាហារ ដែលមិនទាន់ទទួលប្រគេន ភិក្ខុចាប់លើកឱ្យផុតចាកទីទុក សូម្បីគេនាំយកទៅប្រគេនភិក្ខុដទៃ ភិក្ខុដទៃក៏មិនអាចឆាន់អាហារនោះបានដែរ ព្រោះជាអាហារដែលភិក្ខុចាប់លើកមុនទទួលប្រគេន

(ឧត្តហិតៈ[1]) ។

ចំណែកឯអាហារដែលភិក្ខុទទួលប្រគេនត្រឹមត្រូវគ្រប់អង្គ ហើយ ទាយកក៏អាចចាប់ពាល់ត្រូវអាហារនោះបាន មិនចាំបាច់លើកប្រគេនសាជាថ្មីទេ ព្រោះមិនជាហេតុនាំឱ្យដាច់ប្រគេន ។

ហេតុនាំឱ្យដាច់ប្រគេន៧យ៉ាងគឺ:

១- អាហារដែលភិក្ខុទទួលប្រគេនហើយ តែភិក្ខុនោះត្រឡប់ភេទជាស្ត្រី (សម័យពុទ្ធកាល ធ្លាប់មានភិក្ខុត្រឡប់ភេទជាភិក្ខុនី ព្រោះអកុសលកម្មជាបច្ច័យ) ។

២- អាហាររបស់ភិក្ខុអ្នកធ្វើមរណកាលទៅ

៣- អាហាររបស់ភិក្ខុអ្នកលាសិក្ខាមកជាឃរាវាសវិញ

៤- អាហាររបស់ភិក្ខុអ្នកចូលគោរពកាន់សាសនាដទៃ (សម័យពុទ្ធកាល ភិក្ខុមានបញ្ហាតិច រមែងចូលទៅកាន់លទ្ធិតិរ្ថិយជាសាសនាដទៃ) ។

៥- អាហាររបស់ភិក្ខុដែលលះបង់ឱ្យដល់អនុបសម្បន្ន ។

---

(១) ក្នុងដីកាវិមតិពន្យល់ថា ភិក្ខុលើកឡើងដើម្បីឆាន់ដោយខ្លួនឯង ទើបឈ្មោះថា "ឧត្តហិតៈ"

៦- អាហាររបស់ភិក្ខុដែលលះបង់ចោលមិនមានអាល័យ ចង់ឆាន់ទៀត ។

៧- អាហាររបស់ភិក្ខុដែលត្រូវពួកចោរដណ្តើមយកទៅ ។

អាហាររបស់ភិក្ខុដែលមានហេតុទាំង ៧ យ៉ាងខាងលើនេះ លុះត្រាតែបានទទួលប្រគេនសាជាថ្មី ទើបឆាន់បានមិនមានទោស ព្រោះជាអាហារដាច់ប្រគេនហើយ ។

តាមហេតុដាច់ប្រគេន ៧ យ៉ាងនេះ ទាយកក៏អាចជួយចាត់ចែងរៀបចំអាហារដែលភិក្ខុបានទទួលប្រគេនហើយ ដើម្បីឱ្យមានរបៀបងាយឆាន់ដល់ភិក្ខុទាំងឡាយបាន មិនបាច់ប្រគេនឱ្យត្រឹមត្រូវតាមអង្គប្រគេនសាជាថ្មីទៀតទេ ។

វត្ថុត្រូវធ្វើឱ្យជាកប្បិយៈសិនទើបឆាន់បាន

ប្រភេទអាហារផ្លែឈើដែលមានពូជដុះបន្ត ដូចប្រភេទពូជខ្លះដុះពីឫស ខ្លះដុះពីមើម ខ្លះដុះពីគល់ ខ្លះដុះពីថ្នាំង ខ្លះពីចុង ខ្លះដុះពីគ្រាប់ ភិក្ខុមុននឹងឆាន់វត្ថុទាំងនេះ លុះត្រាតែអនុបសម្បន្នធ្វើនិយ

កិច្ចឱ្យគួរជាមុនសិន ទើបមិនមានទោសក្នុងវិន័យ ព្រោះទម្លាយវត្ថុ ដែលមានពូជដុះបន្ត ។

ដូច្នេះ ទាយកក៏អាចប្រគេនអាហារដែលមានពូជដុះបន្តបាន តែភិក្ខុមុននឹងឆាន់គួរឱ្យអនុបសម្បន្នធ្វើវិនយកិច្ចឱ្យសមគួរសិន ទើបឆាន់បានមិនមានទោស តែបើផ្លែឈើមានគ្រាប់អាចបន្ឋិចគ្រាប់ចេញបាន មិនបាច់ធ្វើវិនយកិច្ច គួរបន្ឋិចគ្រាប់ចេញដោយខ្លួនឯង ហើយឆាន់ក៏បាន ។

វិធីធ្វើវិនយកិច្ច

ភិក្ខុកាន់យកអាហារដែលមានពូជដុះបន្ត ចូលទៅរកអនុបសម្បន្ន គឺភិក្ខុចាប់វត្ថុនោះដោយដៃម្ខាងពោលថា អ្នកចូរធ្វើវត្ថុនេះឱ្យគួរ បាលីថា "**កប្បិយំ ករោហិ**" ឯអនុប្បសម្បន្នទទួលចាប់វត្ថុនោះដោយដៃម្ខាង ហើយប្រើចុងកាំបិត ឬចុងដែកស្រួចចាក់ទម្លាយវត្ថុនោះបន្ឋិចឱ្យដំណាលគ្នានឹងពាក្យពោលថា "គួរលោកម្ចាស់"[1] បាលីថា "**កប្បិយំ ករេ**" ។

(១) អដ្ឋកថាពន្យល់ និងពោលតាមក្រោយក៏បាន

តែត្រូវប្រើពាក្យបច្ចុប្បន្នគួរ មិនគួរប្រើពាក្យអតីត ឬអនាគត ។

(តាមព្រះវិន័យ វត្ថុសម្រាប់ធ្វើវិនយកិច្ច សូម្បីដោយភ្លើង ឬចុងក្រចក ក៏អាចប្រើបានដែរ) កាលធ្វើយ៉ាងនេះ សូម្បីចាក់ទម្លាយត្រូវតែវត្ថុ១ ឯវត្ថុដទៃដែលនៅជាប់ជាមួយនោះមិនបានត្រូវក៏ដោយ គួរឆាន់បានទាំងអស់ ។



វិធីធ្វើវិន័យកិច្ចចំពោះភិក្ខុសង្ឃ

សាច់១0យ៉ាងទ្រង់ហាមមិនឱ្យបរិភោគឆាន់

១- **មនុស្សមំសៈ** សាច់មនុស្ស

២- **ហត្ថិមំសៈ** សាច់ដំរី

៣- **អស្សមំសៈ** សាច់សេះ

៤- **សុនខមំសៈ** សាច់ឆ្កែ

៥- **អហិមំសៈ** សាច់ពស់

៦- **សីហមំសៈ** សាច់សីហៈ

៧- **ព្យគ្ឃមំសៈ** សាច់ខ្លាធំ

៨- **ឌីបិមំសៈ** សាច់ខ្លាដំបង

៩- **អច្ឆមំសៈ** សាច់ខ្លាឃ្មុំ

១0-**តរច្ឆមំសៈ** សាច់ឆ្កែព្រៃ ឬចចក

សាច់១0យ៉ាងនេះ បាលីហៅថា **អកប្បិយមំសៈ** ប្រែថា សាច់មិនគួរ គឺ មិនគួរភិក្ខុឆាន់ សូម្បីសាមណេរក៏មិនគួរដែរ ។

សាច់មនុស្ស ឬឆ្អឹង ឈាម ស្បែក របស់មនុស្ស កាលបើភិក្ខុឆាន់ ត្រូវអាបត្តិថុល្លច្ច័យ ។ សាច់ទី ២ រហូតដល់ទី ១០ កាលបើភិក្ខុ ឆាន់ត្រូវអាបត្តិទុក្កដ សូម្បីឆ្អឹង ឈាម ស្បែក ក៏ទ្រង់ហាមដូចគ្នា វៀរលែងតែខ្លាញ់ ។

ទ្រង់ហាមមិនឱ្យភិក្ខុឆាន់សាច់ឆៅនិងសាច់ដែលគេធ្វើឱ្យឆ្អិស

សូម្បីត្រីនិងសាច់ជាកប្បិយៈដែលទ្រង់អនុញ្ញាតឱ្យបព្វជិតឆាន់ក៏ដោយ ប៉ុន្តែបើត្រីនិងសាច់នោះនៅជារបស់ឆៅ គឺពុំទាន់បានចម្អិននៅឡើយ ក៏ទ្រង់ហាមមិនឱ្យបព្វជិតឆាន់ដែរ ភិក្ខុសាមណេរនិងឆាន់សាច់ជាកប្បិយៈបាន លុះត្រាតែបានចម្អិន ទើបមិនមានទោសក្នុងព្រះវិន័យ ។

ម្យ៉ាងទៀត ត្រីឬសាច់ ដែលគេសម្លាប់ដើម្បីប្រគេនចំពោះបព្វជិត គឺ ភិក្ខុឬសាមណេរ លោកហៅថា "**ឧទ្ទិសមំសៈ**" ប្រែថា "សាច់ដែលគេឧទ្ទិសចំពោះ" ។ ត្រីឬសាច់ដែលគេធ្វើឧទ្ទិសចំពោះនេះ កាលបើភិក្ខុឆាន់ត្រូវអាបត្តិទុក្កដ ។ ចំណែកត្រី ឬ សាច់ណា

ដែលគេសម្លាប់បម្រុងខ្លួនគេ ឬដើម្បីលក់ដូរ ជាអាហារសម្រាប់សាធារណៈជន ហៅថា **បឧត្តមំសៈ** ប្រែថា "សាច់របស់សត្វស្លាប់ឬសាច់ដែលប្រព្រឹត្តទៅតាមធម្មតា" លោកមិនរាប់ថាជា **ឧទ្ទិសមំសៈ** កាលបើយកសាច់ទាំងនោះធ្វើជាភោជន ប្រតេនភិក្ខុៗអាចឆាន់បាន មិនជាអាបត្តិឡើយ ។ ឧទ្ទិសមំសៈពិត ប៉ុន្តែភិក្ខុមិនដឹងក៏ឆាន់បាន មិនជាអាបត្តិ សូម្បីមិនមែនឧទ្ទិសមំសៈ តែថា ភិក្ខុសម្គាល់របស់នោះ ដោយសេចក្តីសង្ស័យហើយឆាន់ ត្រូវអាបត្តិទុក្កដ ។

ត្រីនិងសាច់រមែងបរិសុទ្ធដោយហេតុ៣យ៉ាងគឺ **អទិដ្ឋៈ** ដែលភិក្ខុមិនបានឃើញគេកំពុងសម្លាប់១ **អស្សុតៈ** មិនបានឮសម្រែកសត្វដែលគេកំពុងសម្លាប់១ **អបរិសង្កិតៈ** មិនបានរង្កៀសសង្ស័យចំពោះត្រីឬសាច់ដែលគេសម្លាប់ដើម្បីខ្លួន១ ។ សាច់ដែលបរិសុទ្ធដោយចំណែក៣យ៉ាងនេះ ទើបបព្វជិតឆាន់បានមិនមានទោស ។

រឿងមាសប្រាក់

មាសប្រាក់មិនត្រឹមតែភិក្ខុទទួលដោយដៃខ្ទួនឯងមិនបានប៉ុណ្ណោះទេ សូម្បីប្រើឱ្យអ្នកដទៃទទួល ឬត្រេកអរក្នុងមាសប្រាក់ដែលអ្នកដទៃទុកឱ្យ ខុសក្នុងកិច្ចព្រះវិន័យ ក៏ត្រូវទោស គឺត្រូវអាបត្តិនិស្សគ្គីយ៉ាចិត្តិយៈដែរ ភិក្ខុត្រូវលះបង់មាសប្រាក់នោះសិនទើបសម្តែងអាបត្តិដាច់ ។ គួរលះមាសប្រាក់ដែលបានទទួលនោះក្នុងកណ្តាលមុខសង្ឃ ពេលលះនោះ បើមានឧបាសក ឬវេយ្យាវច្ចករណាមួយដើរឆ្លងកាត់មក ហើយរ៉ាប់ទទួលចំណាយនាំវត្ថុដែលគួរមកប្រគេន ភិក្ខុគ្រប់រូប វៀរតែភិក្ខុអ្នកទទួ[illegible]ាសប្រាក់នោះចេញ អាចបរិភោគប្រើប្រាស់វត្ថុនោះបាន តែបើមិនមានអ្នកណាជួយចាត់ការ មាសប្រាក់នោះឱ្យទេ សង្ឃត្រូវសម្មតិភិក្ខុមួយរូបជាអ្នកឆ្លាត មិនលុះក្នុងអគ្គតិទាំង៤ អោយជាអ្នកនាំមាសប្រាក់នោះទៅចោល បើភិក្ខុអ្នកចោលនោះចំណាំទីធ្លាក់ ក៏ត្រូវអាបត្តិទុក្កដ ។ តែបើមិន មានសង្ឃដើម្បីលះបង់ទេ ភិក្ខុអ្នកទទួលមាសប្រាក់នោះ

លះចោល ដោយខ្លួនឯងក៏បាន ហើយសម្តែងអាបត្តិ ចេញខាងក្រោយ តែដែលទ្រង់អនុញ្ញាតឱ្យលះបង់មាសប្រាក់ក្នុងកណ្តាលមុខសង្ឃនោះ ដើម្បីអនុគ្រោះឱ្យសង្ឃបានបរិភោគប្រើប្រាស់កប្បិយវត្ថុដែលកើតអំពីមាសប្រាក់ ដែលបានលះបង់តាមវិន័យហើយ ។

ប្រសិនបើមានជនណាមានសទ្ធា ទុកដាក់មាសប្រាក់ក្នុងដៃរបស់អ្នកណាម្នាក់ ឬក្នុងដៃកប្បិយការកៈ ហើយពោលបវារណានូវបច្ច័យ ៤ (គឺចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ) ដល់ភិក្ខុ ព្រះមានព្រះភាគទ្រង់អនុញ្ញាតឱ្យភិក្ខុត្រេកអរចំពោះបច្ច័យ៤ ដែលកើតអំពីមាសប្រាក់ ដែលបានបវារណាទុកនោះ ។

ពាក្យបវារណាបច្ច័យ៤ដល់ភិក្ខុ

ទាយកជាម្ចាស់ទាន កាលប្រាថ្នាទុកដាក់មាសប្រាក់សម្រាប់បច្ច័យ៤ ដល់ភិក្ខុរូបណាមួយ គប្បីចូលទៅរកវេយ្យាវច្ចកររបស់ភិក្ខុនោះ ហើយប្រគល់មាសប្រាក់ទុកក្នុងដៃវេយ្យាវច្ចករនោះ ហើយពោលពាក្យបវារណាប្រាប់ភិក្ខុនោះថា :- **បពិត្រលោកម្ចាស់មាស**

ប្រាក់មានចំនួន (.....) ខ្ញុំព្រះករុណាបានឧកដាក់ក្នុងដៃវេយ្យាវច្ចករឈ្មោះ (.....) សូមលោកម្ចាស់បរិភោគប្រើប្រាស់នូវបច្ច័យ ៤ តែម្យ៉ាងចុះ (ដើម្បីសម្រេចនូវបុណ្យកុសល ដល់ខ្ញុំព្រះករុណាទាំងឡាយ សូមទានជ្រាប) ។

បើពោលជាភាសាបាលីថា **ឥមំ អប្បិយការកានំ ហត្ថេ ឋបិស្សតិ វេឥច្ចំ តុម្ហេ បច្ចយេ បរិភុញ្ជថ ។**

(បើពោលបវារណាដោយខ្លួនឯងមិនបានទេ គប្បីឱ្យវេយ្យាវច្ចករនោះ បវារណាជំនួសក៏បាន) ។



ការបវារណាបច្ច័យ ៤ ចំពោះភិក្ខុសង្ឃ

វិធីបដិបត្តិក្នុងមាសប្រាក់សម្រាប់ចូលកសាង

មាសប្រាក់មិនមែនមានទោស ចំពោះភិក្ខុអ្នកទទួលដើម្បីខ្លួនតែម្យ៉ាងទេ សូម្បីទទួលដើម្បីភិក្ខុដទៃ ឬដើម្បីកសាងវត្ថុទាំងឡាយ ផ្សេងៗមានវិហារឬចេតីយ៍ជាដើម ក៏មានទោសដែរ គឺត្រូវអាបត្តិទុក្កដ (ទោសតិចជាងទទួលដើម្បីខ្លួន) ។

ដើម្បីឱ្យផុតចាកទោសដល់ភិក្ខុ ទាយកជាម្ចាស់ទាន គប្បីប្រគល់មាសប្រាស់នោះ ទុកក្នុងដៃរបស់គណៈកម្មការវត្ត ឬអ្នកណាម្នាក់ ហើយពោលផ្តាំផ្ញើនឹងលោក(ភិក្ខុ)ថា **មាសប្រាក់ខ្ញុំព្រះករុណាបានទុកជាក់ក្នុងដៃរបស់លោកគណៈកម្មការចំនួន.....ដើម្បីកសាងវិហារ ឬចេតីយ៍ជាដើម សូមលោកម្ចាស់មេត្តាទទួលដឹងនូវការងារដែលគេធ្វើល្អ និងមិនល្អផងចុះ ។** ទាយកនឹងពោលពាក្យផ្តាំផ្ញើភិក្ខុមុន ហើយទើបយកទៅទុកជាក់ជាខាងក្រោយក៏បាន ។

វិធីបដិបត្តិក្នុងមាសប្រាក់ ដែលទាយកបានចង្អុលទិសដៅទុក

តាមពុទ្ធវិន័យ ភិក្ខុឬគណៈកម្មការនឹងចាត់ចែងបាសប្រាក់ ក៏ត្រូវផ្សៀងផ្គាត់ជាមួយពាក្យដែលទាយកជាម្ចាស់ទានបានពោលប្រគេនទុក គឺបើទាយកជាម្ចាស់ទានទុកដាក់មាសប្រាក់ដើម្បីឱ្យប្រើប្រាស់ក្នុងបច្ច័យទាំង ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ ភិក្ខុ ឬគណៈកម្មការ នឹងបង្ហោនទៅប្រើប្រាស់ក្នុងបច្ច័យណាមួយក៏បាន បើទាយកឧទ្ទិសចំពោះបច្ច័យមួយក្នុងបច្ច័យទាំង៣ (គឺ ចីវរ បិណ្ឌបាត គិលានភេសជ្ជៈ) កាលបើសង្ឃព្រមព្រៀងគ្នាហើយនឹងបង្ហោន ទៅប្រើប្រាស់ក្នុងបច្ច័យដទៃផ្សេងទៀតក៏បាន តែបើមាសប្រាក់ដែល ទាយកឧទ្ទិសចំពោះសេនាសនប្បច្ច័យ ភិក្ខុឬគណៈកម្មការ អាចចាត់ចែងក្នុងសេនាសនប្បច្ច័យតែម្យ៉ាង ព្រោះសេនាសនៈជាវត្ថុគរុភណ្ឌ (វត្ថុទ្រង់ហាមមិនឱ្យចែក) តែកាលបើមានសម័យ ទ្រង់អនុញ្ញាតឱ្យបង្ហោន ឬចំណាយបានតាមព្រះវិន័យ បើមានសម័យទុរភិក្ស ទ្រង់អនុញ្ញាតឱ្យភិក្ខុចំណាយទីសេនាសនៈ

ឬវត្ថុជាគរុភណ្ឌដើម្បីចង្ហាន់បិណ្ឌបាត ត្រាន់បានរសនៅ រក្សាវត្ថុជា សម្បត្តិសង្ឃដទៃផ្សេង ទៀត) ។

សម្បត្តិសឡជាគរុភណ្ឌ ២៥ ដែលទ្រង់ហាម មិនឱ្យតិក្ខុបឡោនទៅក្នុងបច្ចំយជទៃ គឺ :-

១- អាវាមោ សួនផ្តា សួនផ្លែ

២- អាវាមចត្ថុ ទីដីសម្រាប់ដាំសួនផ្តា សួនផ្លែ

៣- ទិហារោ ទីលំនៅ ដូចកុដិ សាលាជាដើម

៤- ទិហារចត្ថុ ទីដីសម្រាប់សង់លំនៅ

៥- មញ្ចោ គ្រែ

៦- បីឋ់ តាំង ឬ កៅអី

៧- តិសិ ពូក

៨- ពិម្ពោហនំ ខ្នើយ

៩- លោហកុម្ភី ឆ្នាំងលោហៈ

១០- លោហភាណកំ ខ្ទះលោហ:

១១- លោហឆារកោ ក្លមលោហ:

១២- លោហកដាហំ ធើងលោហ:

១៣- ឆាសី កាំបិត

១៤- ផរសុ ពូថៅ

១៥- កុឋារី ដីងចាំងឈើ

១៦- កុទ្ទាលោ ចប

១៧- និខាទនំ ពន្លាក

១៨- ឧល្លិ រល្លី

១៩- ឧេឡុ ឬស្សី

២០- ឆញ្ជំ ស្មៅដំណេកទន្សាយ

២១- ឆញ្ជទំ ស្មៅយ៉ាប្លង

២២- តិណំ ស្មៅធម្មតា

២៣- មត្តិកា ដីស្មិត

២៤- ឧារុភណ្ឌ គ្រឿងធ្វើអំពីឈើ

២៥- មត្តិកាភណ្ឌ គ្រឿងធ្វើអំពីដី

បើទាយកប្រគល់មា.ឲប្រាក់ឧទ្ទិសចំពោះវត្ថុទាំង ២៥ នេះ ហើយ ភិក្ខុឬគណៈកម្មការ មិនអាចបង្ហោនទៅដើម្បីបច្ច័យដទៃបានឡើយ គឺគួរបដិបត្តិដូចមាសប្រាក់ដែលគេឧទ្ទិសចំពោះសេនាសនប្បច្ច័យនោះដែរ ។

អនាមាសវត្ថុ (វត្ថុដែលភិក្ខុមិនគួរពាល់ត្រូវ)

ក្រៅអំពីកាយមាតុគ្រាម និងមាសប្រាក់ នៅមានវត្ថុដទៃទៀត ដែលភិក្ខុមិនគួរពាល់ត្រូវគឺជាវត្ថុនៃអាបត្តិទាំងអស់ :-

១- កាយមាតុគ្រាមជាដើម បើចាប់ត្រូវដោយដឹងថាជាមាតុគ្រាម សូម្បីមិនមានតម្រេកក៏ត្រូវអាបត្តិទុក្កដ ចាប់ត្រូវដោយតម្រេកត្រូវអាបត្តិសង្ឃាទិសេស ពាល់ត្រូវកាយបណ្ឌក (ខ្ទើយ) ដោយតម្រេកត្រូវអាបត្តិថុល្លច្ច័យ ពាល់ត្រូវកាយបុរស សត្វតិរច្ឆាន

ដោយតម្រេកត្រូវអាបត្តិទុក្កដ ។

២- សំពត់ស្បៃក សំពត់ដណ្តប់ និងគ្រឿងប្រដាប់តាក់តែង របស់មាតុគ្រាម ភិក្ខុក៏មិនគួរពាល់ត្រូវ. តែវត្ថុជាប់ទាក់ទងដោយកាយ បើមាតុគ្រាមគេប្រគេនមិនយកវិញ ភិក្ខុអាចកាន់យកវត្ថុនោះបាន ដូចភិក្ខុត្រូវចោរលួចចីវរ ឧបាសិកាប្រគេនសំពត់ស្បៃកដែលសមគួរធ្វើចីវរបាន ភិក្ខុកាន់យកវត្ថុនោះធ្វើចីវរបាន មិនមានទោស ។

៣- រូបចម្លាក់ធ្វើដោយវត្ថុផ្សេងៗ ដោយហោចទៅសូម្បីរូបគំនូរ ដែលធ្វើឱ្យមានសណ្ឋានជាស្រី ភិក្ខុពាល់ត្រូវ ក៏ជាអាបត្តិទុក្កដ។

៤- **ធញ្ញជាតិ** ៧ប្រភេទបានដល់ **សាលិ** ស្រូវសាលី **ឱហី** ស្រូវខ្យាយ **យវោ** ស្រូវដំណើប **គោធុមោ** ស្រូវសែ **កង្គុ** ថ្លៅ **វរកោ** ពោតឬស្ពួយ ឬស្មៅកន្ទុយដំរី **កុទ្រូសកោ** ស្មៅតែលលក ។

៥- **អបរណ្ណជាតិ** មានសណ្តែកបាយ សណ្តែករាជមាស ក្តី ផ្លែឈើមានខ្ចុរ និងស្វាយជាដើមក្តី ដែលនៅជាប់លើដើម ឬ តំនរដែលគេមិនបានប្រគេន ភិក្ខុមិនគួរពាល់ត្រូវ ព្រោះត្រូវអាបត្តិ ឈ្មោះថា ទុរុបចិណ្ណទុក្កដ គឺត្រូវអាបត្តិព្រោះរំពីសដៃ ចាប់លេង ។

៦- **រតនវគ្គ១០ប្រការ** បានដល់ កែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ សិលា ប្រវាឡ មាស ប្រាក់ កែវទទឹម កែវផ្កែក ភិក្ខុពាល់ត្រូវវត្ថុ១០ប្រការនេះ ត្រូវអាបត្តិទុក្កដ ។ ចំណែកមាស ប្រាក់ដែលទទួលទុកជាក់ដើម្បីប្រយោជន៍ខ្លួន ត្រូវអាបត្តិនិស្សគ្គីយ បាចិត្តិយ ទទួលដើម្បីអ្នកដទៃ សូម្បីទទួលឱ្យសង្ឃ ក៏មិនរួចចាក អាបត្តិទុក្កដ តែវត្ថុមានតម្លៃដទៃរួមនឹងរតនវត្ថុ១០នេះ បើជ្រុះនៅ ក្នុងវត្ត ឬទីលំនៅរបស់ភិក្ខុ ភិក្ខុត្រូវរើសទុកជាក់ឱ្យម្ចាស់គេ បើមិន **រើសទុកជាក់ទេ ភិក្ខុត្រូវអាបត្តិទុក្កដ** (ម្ចាស់មករកទ្រព្យដែលជ្រុះ ក្នុងវត្តមិនឃើញ អាចនឹងសង្ស័យថា ពួកភិក្ខុលួច ទើបទ្រង់ អនុញ្ញាតឱ្យភិក្ខុរើសទុកជាក់ដើម្បីការពារពាក្យតិះដៀល) តែបើ វត្ថុមានតម្លៃជ្រុះក្រៅវត្ត ហាមមិនឱ្យភិក្ខុចាប់ពាល់ទុកជាក់ គឺ មានទោស (អាបត្តិបាចិត្តិយៈ) ។

៧- អាវុធគ្រឿងប្រហារគ្រប់ប្រភេទ មានកាំបិត ស្ព ច្បូក ធ្នូ កាំភ្លើងជាដើម ភិក្ខុមិនគួរពាល់ត្រូវ តែបើមានអ្នកប្រគេន ហើយអាចយកទៅប្រើជាកប្បិយភណ្ឌបាន គួរទទួលតាមសមគួរ ។

៨- គ្រឿងជាក់សត្វ ឬចាប់សត្វទាំងឡាយ ដូចលប ទ្រូ សន្ទូច មង សំណាញ់ជាដើម ជាអនាមាសគ្រប់យ៉ាង ។

៩- គ្រឿងតន្ត្រីគ្រប់ប្រភេទ មានស្គរស្បែកជាដើម ក៏ជាវត្ថុនៃអាបត្តិទុក្កដទាំងអស់ ។

សិក្ខបទតូច៧ទាំងនេះ គ្រហស្ថក៏គួរជ្រាប ដើម្បីងាយស្រួលក្នុងការទំនុកបម្រុងដល់ភិក្ខុសង្ឃឱ្យត្រឹមត្រូវតាមព្រះវិន័យ និងជាការរួមចំណែកក្នុងការទ្រទ្រង់ព្រះពុទ្ធសាសនា ដែលមានវិន័យជាឫសគល់ ។ កុសលរបស់ឧបាសក ឧបាសិកា ដែលយល់ព្រះធម៌ និងព្រះវិន័យ រមែងជាកុសលដែលប្រកបដោយបញ្ញា មានផលច្រើន និងមានអានិសង្សច្រើន ។

ពោលអំពីស្បែកជើង

ស្បែកជើងធ្វើដោយស្បែក ភាសាបាលីហៅថា "ឧបាហនា" ទ្រនាប់ជើងដែលធ្វើអំពីវត្ថុផ្សេងៗ ក្រៅអំពីស្បែក ភាសាបាលីហៅថា "បាទុកា" ។

ព្រះមានព្រះភាគទ្រង់ហាមមិនឱ្យភិក្ខុប្រើប្រាស់ទ្រនាប់ជើងដែលកម្រើកទៅបានគ្រប់ប្រភេទ តែទ្រង់អនុញ្ញាតស្បែកជើង ៤ ជាន់ឱ្យភិក្ខុពាក់ប្រើប្រាស់ក្នុងវត្ត ឬព្រៃបាន ចូលទៅកាន់ស្រុកអាចពាក់បាន លុះត្រាតែមានអាពាធ ព្រោះទ្រង់បញ្ញត្តវិន័យទុកថា :-

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលទៅកាន់ស្រុកទេ ភិក្ខុណាពាក់ត្រូវអាបត្តិទុក្កដ តថាគតអនុញ្ញាតឱ្យភិក្ខុមានជម្ងឺពាក់ស្បែកជើងចូលទៅកាន់ស្រុកបាន ។

ដូច្នេះ ទាយកក៏អាចប្រគេនស្បែកជើងដល់ភិក្ខុពាក់ប្រើប្រាស់បាន តែស្បែកជើងដែលបិទកែង ឬគ្របខ្នងជើង រមែងមិនគួរ ព្រោះទ្រង់ហាមទុកថា :- **ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ**

ពាក់ស្បែកជើងបិទកែង មិនត្រូវពាក់ស្បែកជើងស្រោបរហូតដល់ស្មងជើង មិនត្រូវពាក់ស្បែកជើងបិទខ្នងជើង មិនត្រូវពាក់ស្បែកជើងក្លាត់សំឡឹត មិនត្រូវពាក់ស្បែកជើងមានខ្សែវិចិត្រដូចស្លាបទទា មិនត្រូវពាក់ស្បែកជើង មានខ្សែសណ្ឋានដូចកន្ទុយសត្វខ្លួយដែលវិចិត្រផ្សេងៗឡើយ ភិក្ខុណាពាក់ត្រូវអាបត្តិទុក្កដ ។

ស្បែកជើងដែលទ្រង់អនុញ្ញាត

ភាលិក៤យ៉ាង គឺរបស់មានកាលកំណត់ក្នុងការឆាន

១- **យាវកាលិក** សំដៅដល់អាហារគ្រប់យ៉ាងវ្យែ
កាលិក៣ ដែលនឹងពោលទុកខាងក្រោម ភិក្ខុទទួលប្រគេនពេល
ព្រឹក ឆាន់រហូតថ្ងៃត្រង់ ។

២- **យាមកាលិក** សំដៅដល់ទឹកផ្លែឈើ៨យ៉ាង ដែល
និយមហៅថា "ទឹកអដ្ឋបាន" រួមទាំងទឹកផ្លែឈើដែលគួរសង្គ្រោះ
ចូលដទៃទៀត វ្យែរទឹកផ្លែឈើ៨យ៉ាងដែលទ្រង់ហាមទុក (គឺ ទឹក
ផ្លែដូង ទឹកផ្លែត្នោត ទឹកឪឡឹក ទឹកឃ្លោក ទឹកត្រឡាច ទឹកល្ពៅ
ទឹកត្រសក់ ទឹកផ្លែខ្នុរសម្ល ខ្នុរណាំង) ភិក្ខុទទួលប្រគេនហើយ
ទុកឆាន់បានតែក្នុង ១ យាមគឺរយៈពេល ១ ថ្ងៃ ១ យប់ប៉ុណ្ណោះ ។

៣- **សត្តាហកាលិក** សំដៅដល់ភេសជ្ជៈ៥យ៉ាងគឺ
ទឹកដោះ រាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ សូម្បីស្ករស
ស្ករត្នោត ក៏សង្គ្រោះក្នុងស្ករអំពៅដែរ ភិក្ខុទទួលប្រគេនហើយ
ទុកដាក់ឆាន់ បាន៧ថ្ងៃ អស់កំណត់កាលអរុណនៃថ្ងៃទី៨រះឡើង

បើលះឱ្យអនុបសម្បន្នមុនអរុណថ្ងៃទី ៨ ហើយបានត្រឡប់មកវិញ ក៏អាចទុកដាក់បានបន្តទៀត ។

៤- **យាវជីវិក** សំដៅដល់ ថ្នាំរក្សារោគផ្សេងៗ ទាំងថ្នាំបូរាណទាំងថ្នាំពេទ្យបច្ចុប្បន្ន ភិក្ខុទទួលប្រគេនហើយ អាចទុកដាក់រហូតអស់ជីវិត ។

កាលិកសំសគ្គៈ (ការលាយឡំគ្នារវែងកាលិក)

កាលិកទាំង៤នេះ បើចូលគ្នា ត្រូវរាប់អាយុតាមកំណត់វេលារបស់កាលិកដែលមានអាយុខ្លី ដូចទឹកអដ្ឋបានលាយនឹងអាហារ ក៏ឆាន់បានត្រឹមពីព្រឹកដល់ថ្ងៃត្រង់ ទឹកឃ្មុំលាយនឹងទឹកអដ្ឋបានឆាន់បានត្រឹមតែមួយថ្ងៃមួយយប់ ខាងក្នុងអរុណរះឡើងថ្មីប៉ុណ្ណោះ ឬថ្នាំរក្សារោគជាយាវជីវិកលាយនឹងទឹកឃ្មុំ ក៏ទុកដាក់ឆាន់បានត្រឹម ៧ ថ្ងៃប៉ុណ្ណោះ យ៉ាងនេះជាដើម ។ សម្រាប់ជាយាវកាលិក ទ្រង់អនុញ្ញាតឱ្យឆាន់ ដើម្បីបំបាត់ឃ្លាន ដើម្បីបន្តជីវិតប្រព្រឹត្តព្រហ្មចរិយធម៌ ភិក្ខុឆាន់អាហារហួសពីថ្ងៃត្រង់ឡើងទៅត្រូវអាបត្តិ

បាចិត្តិយៈ ព្រោះឆាន់ អាហារក្នុងវេលាវិកាល ។

ទឹកអដ្ឋបាន រួមទាំងទឹកផ្លែឈើដែលសង្គ្រោះផង ទ្រង់អនុញ្ញាតឱ្យភិក្ខុឆាន់បាន ដើម្បីអនុគ្រោះដល់ទាយកអ្នកប្រាថ្នាធ្វើទានក្នុងវេលាវិកាល អដ្ឋបានជាទានអាចប្រគេនបានទាំងពេលថ្ងៃពេលយប់ ចំណែកអាហារ ទាយកអាចប្រគេនបានក្នុងពេលព្រឹកដល់ថ្ងៃត្រង់ប៉ុណ្ណោះ ក្រោយពីថ្ងៃត្រង់ទៅមិនគួរប្រគេនភិក្ខុ តែគួរឱ្យវេយ្យាវច្ចករឬសាមណេរទុកដាក់ប្រគេនភិក្ខុក្នុងថ្ងៃព្រឹកឡើង ។

សត្តាហកាលិក ជំពូក ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ភិក្ខុនឹងឆាន់បានលុះត្រាតែមានហេតុគឺអាពាធ។ ក្នុងទីនេះ សូម្បីត្រឹមតែអស់កម្លាំងល្ហិតល្ហៃ បើមិនមានហេតុដូចពោលទេ ឆាន់រមែងត្រូវអាបត្តិ ។

ថ្នាំរក្សារោគដែលជាយាវជីវិកក៏ដូចគ្នា កាលមានអាពាធជាហេតុ ទើបឆាន់បាន បើភិក្ខុនាំយាមកាលិក សត្តាហកាលិក យាវជីវិក មកឆាន់ជាអាហារ គឺឆាន់ដើម្បីឱ្យឆ្អែតដូចអាហារ ត្រូវអាបត្តិទុក្កដដូចគ្នា ។

គិលានភេសជ្ជៈរបស់សង្ឃ

គិលានភេសជ្ជៈ សំដៅដល់ ថ្នាំសម្រាប់អ្នកជម្ងឺ។ តាមធម្មតា ភិក្ខុមិនមែនឆាន់ថ្នាំរក្សារោគរាល់ថ្ងៃដូចអាហារបិណ្ឌបាតទេ លុះត្រាតែមានហេតុគឺអាពាធទើបឆាន់ ព្រោះហេតុដូច្នោះ កាលមានទាយកនាំភេសជ្ជៈប្រគេនជារបស់សង្ឃ ទើបគួរទុកដាក់ជារបស់កណ្តាល (របស់រួម) មានភិក្ខុអ្នករក្សាឃ្លាំងមើលថែទាំ កាលមានភិក្ខុណាមួយមានអាពាធ ទើបទៅសុំថ្នាំរក្សាអាពាធនោះ ជាមួយភិក្ខុអ្នកចែករបស់តិចតួច (**អប្បមត្តកវិស្សជ្ជកៈ**) ឬភិក្ខុអ្នករក្សាឃ្លាំងដែលសង្ឃសន្មតទុក។

ភេសជ្ជៈគឺទឹដោះខាប់ ទឹកដោះរាវ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ក៏ចាត់ជាថ្នាំរក្សារោគដែរ បើជារបស់សង្ឃទុកដាក់មិនមានកំណត់ បើមានច្រើនពេកគប្បីវាយរគាំងឱ្យភិក្ខុព្រមព្រៀងហើយចែកគ្នា ១គ្រា។

សម្រាប់ភេសជ្ជៈដែលទាយកប្រគេនចំពោះ ភិក្ខុបុគ្គល កាល

ទទួលហើយ ទុកឆាន់បានមិនលើសៗថ្ងៃ បើកន្លងលើសៗថ្ងៃ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ភេសជ្ជៈនោះជានិស្សគ្គីយ៍ ត្រូវលះបង់ សូម្បីលះបង់ហើយត្រឡប់បានមកវិញ ក៏មិនគួរឆាន់ តែបើនាំទៅប្រើក្នុងកិច្ចដទៃបាន ។

ភេសជ្ជៈគួរឆាន់និងមិនគួរឆាន់

ទឹកដោះគោទ្រង់អនុញ្ញាតមាន ៥ ប្រភេទ បាលីហៅថា "**បញ្ចគោរស**" គឺ **១ខីរំ** ទឹកដោះគោស្រស់ **២ឆធិ** ទឹកដោះគោជូរ **៣តក្កំ** ប្រែងទឹកដោះ **៤នវនីតំ** ទឹកដោះគោខាប់ **៥សប្បិ** ទឹកដោះគោរាវ ឬថ្លា ។

ទឹកដោះគោ៣ប្រភេទខាងដើម ជាភោជនទ្រង់អនុញ្ញាតឱ្យភិក្ខុឆាន់ក្នុងវេលាព្រឹកដល់ថ្ងៃត្រង់ តែទឹកដោះគោ២ប្រភេទខាងចុង ជាភេសជ្ជៈទ្រង់អនុញ្ញាតឱ្យភិក្ខុឆាន់ក្នុងវេលាវិកាលបាន ។ ទឹកដោះក្នុងបច្ចុប្បន្ន ដែលមានឈ្មោះថា "ទឹកដោះគោសុទ្ធ" ទាយកអាចប្រគេនភិក្ខុឆាន់នៅពេលព្រឹក ហួសពីថ្ងៃត្រង់ទៅមិនគួរ ព្រោះ

ជាទឹកដោះប្រភេទទី១ (តាមមតិរបស់លោកអ្នកទ្រទ្រង់វិន័យទាំងឡាយ ធ្លាប់បានពិចារណាគ្នាហើយ) សូម្បីទឹកត្រឡាច ទឹកសណ្តែក ទឹកដូង ដែលគេផលិតដាក់កំប៉ុងសព្វថ្ងៃនេះ ក៏ភិក្ខុមិនគួរឆាន់នៅពេលវិកាលដែរ ព្រោះជាវត្ថុឱ្យបែកធ្លាយសីលវិកាលសិក្ខាបទ ។ នៅមាន ទឹកកំប៉ុងដទៃទៀត ដែលលោកអ្នកទ្រទ្រង់វិន័យកំពុងតែសង្ស័យនៅឡើយ ព្រោះហេតុដូច្នេះ ក្នុងរឿងភេសជ្ជៈ សូមលោកអ្នករក្សាសីលវិកាលសិក្ខាបទ គប្បីពិចារណាឱ្យល្អិតល្អន់ល្អន់ដោយខ្លួនឯងចុះ ។

ម្យ៉ាងទៀត ទឹកអដ្ឋបាន បើភិក្ខុទទួលប្រគេនផ្លែឈើធ្វើដោយខ្លួនឯង អាចឆាន់បានរហូតថ្ងៃត្រង់ ក្នុងវេលាវិកាលប្រសិនបើសាមណេរ ឬគ្រហស្ថធ្វើប្រគេន ទើបឆាន់បាន តែគួរត្រងច្រោះឱ្យស្អាត ដើម្បីការពារសល់កាក ឬ សាច់ ជាហេតុឱ្យត្រូវទោសក្នុងវិកាលសិក្ខាបទ ។

ការប្រគេនចីវរ

បើទាយកប្រគេនចីវរដល់ភិក្ខុ ជាចំណែកបុគ្គល ភិក្ខុអ្នកទទួលជាធំក្នុងចីវរនោះ តែបើប្រគេនចំពោះសង្ឃ សង្ឃរមែងជាធំ គឺត្រូវបែងចែកដល់ភិក្ខុគ្រប់រូប អ្នកនៅក្នុងឧបចារសីមាឬវត្តនោះ បើចីវរមិនល្មមចែក គប្បីទុកដាក់ក្នុងឃ្លាំងដរាបមានច្រើន ល្មមចែកទូទៅបាន ។

កាលវេលាចែក គប្បីវាយរគាំងដើម្បីព្រមព្រៀងគ្នា ភិក្ខុអ្នកឆ្លាតដែលសង្ឃសម្មតិទុកឱ្យជាអ្នកចែកចីវរ ដែលហៅថា **ចីវរភាជកៈ** ត្រូវជាអ្នកចែកចីវរ ។

ក្នុងសម័យពុទ្ធកាល មិនមានចីវរដែលធ្វើស្រេចនៅឡើយ ចីវរក៏គឺសំពត់ដែលភិក្ខុបានទទួលជាចំណែកតូចខ្លះ ធំខ្លះ បើល្មមធ្វើជាត្រៃចីវរផ្ទាំងណាមួយ ភិក្ខុក៏ស្វែងរកមិត្តសំឡាញ់ឱ្យជួយកាត់ដេរ ការកាត់ដេរចីវរសម័យនោះ ភិក្ខុនាំគ្នាធ្វើដោយដៃផ្ទាល់ មិនមានម៉ាស៊ីនយន្ត ដូចសម័យបច្ចុប្បន្នទេ ទើបជារឿងលំបាក

ហេតុនោះឯង ទើបព្រះពុទ្ធជាម្ចាស់ ទ្រង់បន្ធូរព្រះវិន័យទុកច្រើនកន្លែង ក្នុងសម័យដែលធ្វើចីវរនោះ ដូចឆាន់អាហារដទៃបុនអាហារដែលទាយកនិមន្តទុកបាន (**បរម្បរភោជន**) ឬភោជនដែលគេនិមន្តចេញឈ្មោះភោជនតាំងអំពីភិក្ខុ៤រូបឡើងទៅ (**គណភោជន**) ក៏បានជាដើម ។

បើភិក្ខុបានទទួលចំណែកសំពត់ តែមិនល្មមនឹងធ្វើចីវរ ណាមួយ បាន អាចទុកដាក់សំពត់នោះបាន ត្រឹមតែ១០ថ្ងៃប៉ុណ្ណោះ បើទុកក្រៃកន្លងហួសពីកំណត់នោះទៅ ជានិស្សគ្គិយបាចិត្តិយ ក្បែរតែបានអធិដ្ឋានធ្វើជាសំពត់បរិក្ខារដទៃ ដូចជាសំពត់ជូតមុខ សំពត់ក្រាលដេក ។ល។

តែកាលភិក្ខុនៅមានសេចក្តីប្រាថ្នានឹងធ្វើចីវរ និងមានសេចក្តីសង្ឃឹមថា នឹងបានសំពត់មកបន្ថែមទៀត ដរាបល្មមធ្វើជាចីវរណាមួយ អាចទុកដាក់សំពត់ដែលបានទទួលការចែកនោះ បានកំណត់១ខែ ក្នុងរវាង១ខែនោះ បើមានសំពត់ដទៃមកផ្សំអាចធ្វើជាចីវរ

បានក៏ជាការល្អ បើមិនបានសំពត់ថ្មីមកបន្ថែមទៀតទេ ឬបានតែមិនគ្រប់ក៏ដោយ បើទុកសំពត់ឱ្យលើស១ខែ ត្រូវអាបត្តិនិស្សគ្គីយបាចិត្តិយៈ ។

ព្រះអង្គទ្រង់បញ្ញត្តសិក្ខាបទមិនឱ្យភិក្ខុ ទុកដាក់សំពត់លើស ១០ថ្ងៃ ឬ១ខែនេះ ក៏ដើម្បីការពារកិលេសដែលកើតពីការសន្សំ និងដើម្បីការពារពាក្យតិះដៀលអំពីគ្រហស្ថផង តែបើភិក្ខុបានក្រាលកឋិន បានទទួលអានិសង្សកឋិន៥យ៉ាង អាចទុកដាក់សំពត់បានមករហូតអស់កាលកំណត់កឋិន ដោយមិនចាំបាច់អធិដ្ឋាន ។

សេចក្តីសំខាន់គឺ បើទាយកនឹងប្រគេនចីវរដែលធ្វើស្រេចគប្បីពិនិត្យមើលពណ៌ និងខ្នាតឱ្យត្រឹមត្រូវតាមព្រះវិន័យ ។

ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឱ្យភិក្ខុ ជ្រលក់ចីវរដោយទឹកជ្រលក់ដែលកើតអំពីមើម ដើម សំបក ស្លឹក ផ្កា ផ្លែ ។ ដូច្នេះពណ៌ដែលច្បាស់អស់សង្ស័យ គឺពណ៌ដែលជ្រលក់ដោយទឹកជ្រលក់ពណ៌ខ្ជឹមខ្មុរ និងព្រោះទ្រង់បញ្ញត្តវិន័យទុកថា :- **ម្នាលភិក្ខុទាំង-**

ឡាយ ភិក្ខុមិនគប្បីទ្រទ្រង់ចីវរខ្សែវសុទ្ធ ចីវរលឿងសុទ្ធ ចីវរក្រហមសុទ្ធ ចីវរមានពណ៌ដូចជើងហង្ស ចីវរខ្មៅសុទ្ធ ចីវរក្រហមក្រាំ ចីវរលឿងខ្ចុំសុទ្ធ ចីវរមានជាយមិនបានកាត់ចេញ ចីវរមានជាយវែង ចីវរមានជាយជាផ្កាឈើ ចីវរមានជាយជាផ្លែឈើ ទ្រទ្រង់អាវ ទ្រទ្រង់មួក ទ្រទ្រង់សំពត់ឈ្មុត ភិក្ខុណាទ្រទ្រង់ត្រូវអាបត្តិទុក្កដ ។

ខ្នាតនៃត្រៃចីវរ

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់អនុញ្ញាតខ្នាតត្រៃចីវរដល់ភិក្ខុទាំងឡាយ ដោយកំណត់ខ្នាតធំបំផុតឱ្យតូចជាងចីវររបស់ព្រះ-សុគត និងកំណត់ខ្នាតតូចបំផុត ៖ គឺបណ្តោយនៃសង្ឃាដិ ឧត្តរាសង្គៈ អន្តរាវាសកៈ ៤ហត្ថ ១គក់ (គឺស្មើរ២ម៉ែត និង២០សង់ទី ម៉ែត្រ) ទទឹង សង្ឃាដិ និង ឧត្តរាសង្គៈ ២ហត្ថ ១គក់ (គឺស្មើរ១ម៉ែត្រ ៣០សង់ទីម៉ែត្រ) ទទឹងអន្តរាវាសកៈ (ស្បង់) ២ហត្ថ (ស្មើរ ១ម៉ែត្រ) ។ បើភិក្ខុ ឬសាមណេរ រាងខ្ពស់ឬមាឌធំ ក៏គួរកាត់តម្រូវ

តាមកម្ដស់ ឬមាឌរបស់លោក តែមិនធំជាងសុគតចីវរ និងមិនតូចជាងខ្នាត ដែលបានកំណត់ហើយ ។

សង្ឃាដីគួរដេរសំពត់ពីរជាន់ ព្រោះទ្រង់អនុញ្ញាតទុកថា :-

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវ សង្ឃាដិ ២ ជាន់ ឧត្តរាសង្គៈ (ចីពរ) ១ជាន់ អន្តរវាសកៈ (ស្បង់) **១ជាន់** ។





ตู้หนังสือ

សេនាសនៈរបស់សង្ឃ

ទាយកអាចឱ្យធ្វើកុដិប្រគេនចំពោះ ភិក្ខុបុគ្គលបាន សូម្បីភិក្ខុ ក៏អាចធ្វើ ឬឱ្យធ្វើកុដិដើម្បីខ្លួនឯងក្នុងទីដីរបស់សង្ឃបាន តែបើកុដិ នោះបូកលាបកំបោរ មិនមានទាយកជាម្ចាស់ ភិក្ខុត្រូវធ្វើឱ្យត្រូវ ប្រមាណ (បណ្តោយ ១២ ចំអាម ១ទឹង ៧ ចំអាម ជាចំអាម ព្រះសុគត) ត្រូវឱ្យសង្ឃធ្វើសង្ឃកម្មអនុញ្ញាតកន្លែងកសាង ត្រូវធ្វើ ក្នុងទីមានឧបចារៈ និងមិនមានរង្កៀស បើភិក្ខុកសាងហួស ប្រមាណ ត្រូវអាបត្តិសង្ឃាទិសេស១ បើមិនបានឱ្យសង្ឃអនុញ្ញាត ទីឱ្យ ត្រូវអាបត្តិសង្ឃាទិសេស១ទៀត បើកសាងក្នុងទីមិនមាន ឧបចារៈ

(ទីបត់រទេះមិនបាន) ត្រូវអាបត្តិទុក្កដ១ បើមានរង្កៀស (មានសត្វល្អិត) ត្រូវអាបត្តិទុក្កដ១ទៀត ។

បើកុដិនោះមានទាយកជាម្ចាស់ ភិក្ខុអាចធ្វើហូសប្រមាណបាន តែត្រូវឱ្យសង្ឃអនុញ្ញាតទីឱ្យ ទាំងក្នុងទីមានឧបចារៈ និងមិនមានទីរង្កៀស ។

សេនាសនៈរបស់ភិក្ខុបុគ្គល ភិក្ខុជាម្ចាស់នោះឯង រមែងជាធំ បើជារបស់សង្ឃត្រូវចែកតាមលំដាប់វស្សា សូម្បីក្នុងកិច្ចដទៃ។ ក្នុងកន្លែងផ្សេង។ក៏ត្រូវចែកតាមលំដាប់វស្សា វៀរតែ ៣កន្លែងប៉ុណ្ណោះ កន្លែងបន្ទោបង់ឧច្ចារៈ១ កន្លែងបន្ទោបង់បស្សាវៈ១ កន្លែងងូតទឹក១ ទាំង៣កន្លែងនេះតាមលំដាប់អ្នកមកដល់មុន ។

ភិក្ខុអ្នកចាត់ការសេនាសនៈ ឈ្មោះថាសេនាសនគាហាបកៈ (ភិក្ខុអ្នកឱ្យកាន់យកសេនាសនៈ) រមែងចែកតាមរដូវកាល ដូចរដូវវស្សា ឬក្នុងកាលដែលមានភិក្ខុមកប្រជុំគ្នាច្រើន ។ ភិក្ខុដែលបានទទួល ឬកាន់យកសេនាសនៈហើយ និងនៅគ្រប់គ្រងសេនាសនៈ

នោះរហូតមិនបានឡើយ ស្រេចហើយតែភិក្ខុជាសេនាសនគាហាបក: នីងផ្ទាស់ប្តូរពេលណា ក៏ត្រូវផ្ទាស់ប្តូរពេលនោះ ព្រោះទ្រង់បញ្ញត្តថា :- **ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម អាសនៈប្រសើរ និងដំបាយប្រសើរ ដល់ភិក្ខុតាមលំដាប់វស្សាចាស់ខ្ចី សេនាសនៈជារបស់សង្ឃ ភិក្ខុមិនត្រូវឃាត់ឃាំងតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុណាឃាត់ឃាំងត្រូវអាបត្តិទុក្កដ ។** ម្យ៉ាងទៀត ភិក្ខុ៤ពួកទ្រង់ហាមមិនឱ្យឃ្លាតចាកកន្លែង (គឺ ភិក្ខុចាស់ជាងខ្លួន១ ភិក្ខុរក្សាឃ្លាំង១ ភិក្ខុអាពាធ១ ភិក្ខុមានឧបការៈចំពោះសង្ឃ១) ។

សេចក្តីផ្សេងគ្នារបស់វិនយកិច្ច និងសង្ឃកម្ម

វិនយកិច្ច សំដៅដល់កិច្ចដែលទ្រង់អនុញ្ញាតតាមព្រះវិន័យ ដូចជាធ្វើកប្បិយៈ ផ្លែឈើដែលមានពូជដុះបន្ត កិច្ចលះបង់វត្ថុជានិស្សគ្គីយ៍ជាដើម ។

វិនយកិច្ចទាំងនេះ មិនចាំបាច់ធ្វើក្នុងសីមាក៏បាន កិច្ចខ្លះធ្វើជា

មួយសាមណេរ ឬគ្រហស្ថក៏បាន ។

ចំណែកសង្ឃកម្ម គឺជាកម្មដែលពួកភិក្ខុត្រូវរួមគ្នាធ្វើ ព្រោះហេតុនោះ ទើបត្រូវអាស្រ័យសេចក្តីព្រមព្រៀងគ្នានៃភិក្ខុទាំងឡាយក្នុងសីមាជាមួយគ្នា តាំងពី៤រូបឡើងទៅ មានការសូធ្យប្រកាសសូមសេចក្តីយល់ឃើញក្នុងកម្មណាមួយរបស់សង្ឃ ដើម្បីសេចក្តីមាំទាំក្នុងកម្មនោះ និងសេចក្តីយល់ឃើញត្រូវគ្នារបស់សង្ឃ ដើម្បីការពារពាក្យតិះដៀលខាងក្រោយ ទើបមានវិន័យបញ្ញត្តិថា ភិក្ខុណាមួយដឹងអធិករណ៍ដែលសង្ឃធ្វើត្រឹមត្រូវតាមធម៌ ហើយសើរើដើម្បីធ្វើថ្មីទៀត ត្រូវអាបុត្តិបាចិត្តិយៈ នេះសំដៅដល់សង្ឃកម្មដែលសង្ឃធ្វើទុកល្អហើយ គឺភិក្ខុយល់ឃើញល្អហើយ បើភិក្ខុណាមួយតិះដៀល ឬសើរើ រមែងមានទោស ។

សង្ឃកម្មមាន៤យ៉ាងគឺ **អបលោកនកម្ម១ ញត្តិកម្ម១ ញត្តិទុតិយកម្ម១ ញត្តិចតុត្ថកម្ម១** ។ បើកម្មណាស្រាលៗដូចការចែកអាហារ ឬបច្ច័យ៤ជាដើម ប្រើអបលោកនកម្ម (សូធ្យ

ប្រកាសសេចក្តីយល់ឃើញអំពីសង្ឃ ៣ ដង) ។

បើកម្មសំខាន់ជាងនោះ ដូចឧបោសថកម្ម បវារណាកម្ម ប្រើ ញត្តិកម្ម (សូធ្យញត្តិសូមអនុមតិអំពីសង្ឃអ្នកព្រមព្រៀងគ្នា មួយដង) ។

បើកម្មដែលសំខាន់ជាងនោះទៀត ដូចការសន្ទតិសីមា ការ ដកសីមា ប្រើញត្តិទុតិយកម្ម (សូធ្យញត្តិម្តង សូធ្យប្រកាសសូម អនុមតិម្តង អំពីសង្ឃអ្នកព្រមព្រៀងគ្នា) ។

បើឧបសម្បទា (បំពេញជាភិក្ខុ) ការឱ្យបរិវាស ឱ្យមានត្ត ដែលជាកម្មសំខាន់បំផុត ត្រូវប្រើញត្តិចតុត្ថកម្ម (សូធ្យញត្តិម្តង សូធ្យសូមអនុមតិអំពីសង្ឃអ្នកព្រមព្រៀងគ្នា ៣ ដង) ។

ព្រះវិន័យមានសារៈសំខាន់ដល់ព្រះពុទ្ធសាសនាយ៉ាងណាខ្លះ?

ពាក្យថា "**វិន័យ**" បើប្រែសេចក្តីឱ្យងាយស្តាប់ថា "ការ បង្គាប់បញ្ជា" បានដល់ ច្បាប់សម្រាប់គ្រប់គ្រងសេចក្តីប្រព្រឹត្តិរបស់ មនុស្សក្នុងសង្គមឱ្យមានរបៀបរៀបរយល្អ ជាបែបផែនតែមួយ

ដើម្បីបានរស់នៅរួមគ្នាយ៉ាងសុខសប្បាយ ។ តែបើប្រែតាមព្យញ្ជនៈ ថា " ច្បាប់សម្រាប់ដឹកនាំហ្វឹកហាត់កាយវាចានៃបុគ្គលម្នាក់ៗ ឱ្យប្រព្រឹត្តតែអំពើមានប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ " ។ ការរស់នៅរួមគ្នាជាពួក បើខ្វះរបៀបព្រះវិន័យ គឺម្នាក់ៗប្រព្រឹត្តតែតាមអំពើចិត្ត សេចក្តីជម្លោះ ការប៉ះទង្គិចគ្នា ក៏រមែងកើតមាន មិនអាចរស់នៅដោយសេចក្តីសុខសប្បាយឡើយ ។ ព្រោះការរស់នៅរួមបើមានគ្នាកាន់តែច្រើន ក៏មានរឿងកាន់តែច្រើនឡើងដែរ ។

ព្រះពុទ្ធជាម្ចាស់ កាលត្រាស់ដឹងបាន ២០ វស្សាមានបរិស័ទច្រើន ក៏ផ្តើមមានរឿងកើតឡើង ទើបទ្រង់បញ្ញត្តព្រះវិន័យដល់សាវកទាំងឡាយជាបន្តបន្ទាប់ ដោយព្រះអង្គទ្រង់សម្លឹងឃើញប្រយោជន៍ ១០ យ៉ាង នឹងកើតមានដល់សាវក និងសាសនារបស់ព្រះអង្គ ក្រោយពេលបានបញ្ញត្តព្រះវិន័យរួចហើយ ។ ម្យ៉ាងទៀត ព្រះមហាកស្សបៈ សម្តែងថា **និន្នយោ សាសនស្ស ចូឡំ** (វិន័យជាឫសគល់នៃព្រះពុទ្ធសាសនា) **និន្នយោ នាម សាស**

ឧសុ្ស អាយុ (វិន័យ ឈ្មោះថា ជាអាយុជីវិតរបស់ព្រះពុទ្ធសាសនា) ។ **ក្នុងអដ្ឋកថា សមន្តបា្បសាទិកា** សម្តែងថា ភិក្ខុណាមួយ មានចិត្តក្លែងប្រព្រឹត្តល្មើសនូវវិន័យ គឺសិក្ខាបទត្រឹមតែអាបត្តិទុក្កដ រមែងធ្វើសេចក្តីអន្តរាយដល់សុគតិ មគ្គ ផល និព្វាន ដូចជនអ្នកធ្វើអនន្តរិយកម្ម មានសម្លាប់មាតាបិតាជាដើម រមែងធ្វើសេចក្តីអន្តរាយដល់ការត្រាស់ដឹងនូវលោកុត្តរធម៌ ដូច្នោះឯង ។

ព្រោះហេតុនោះ បើពុទ្ធសាសនិកជន ជាអ្នកស្រឡាញ់ព្រះពុទ្ធសាសនា គួរគោរពប្រតិបត្តិតាមព្រះវិន័យដែលជាអាយុនៃព្រះពុទ្ធសាសនា ។ ផ្ទុយទៅវិញ បើពុទ្ធសាសនិកជន លះបង់ចោលនូវព្រះវិន័យហើយ ក៏ឈ្មោះថា ជាអ្នកសម្លាប់ព្រះពុទ្ធសាសនា ។

ទ្រង់បញ្ញត្តវិន័យព្រោះឃើញប្រយោជន៍១០យ៉ាងគឺ

១- ដើម្បីឃើញប្រពៃរបស់សង្ឃ (គឺភិក្ខុសង្ឃត្រេកអរទទួលបដិបត្តិតាម) ។

២- ដើម្បីសង្ឃនៅសប្បាយជាមួយគ្នា

៣- ដើម្បីញុំាញីសង្កត់សង្កិន ភិក្ខុមិនខ្មាស់មិនខ្លាចបាប (គឺប្រព្រឹត្តខុសធម៌វិន័យ) ។

៤- ដើម្បីសេចក្តីសប្បាយដល់ភិក្ខុ អ្នកមានសីលជាទីស្រឡាញ់ ។

៥- ដើម្បីឱ្យជនមិនទាន់ជ្រះថ្លា ធ្វើមជ្រះថ្លាឡើង

៦- ដើម្បីឱ្យជនដែលជ្រះថ្លាហើយ រឹងរឹតតែជ្រះថ្លាថែមទៀត ។

៧- ដើម្បីការពារអាសវធម៌ក្នុងបច្ចុប្បន្ន (គឺឈ្លោះប្រកែកទាស់ទែងគ្នា) ។

៨- ដើម្បីការពារអាសវធម៌ក្នុងបរលោក (គឺមិនឱ្យធ្លាក់ទៅកាន់អបាយភូមិ) ។

៩- ដើម្បីអនុគ្រោះដល់ព្រះវិន័យ

១០- ដើម្បីឱ្យព្រះពុទ្ធសាសនាតាំងនៅបានយូរ ។

ព្រះពុទ្ធសាសនាគឺព្រះធម៌ទាំងឃ

សាសនាមកអំពីភាសាបាលីថា "សាសនំ" ប្រែថា ពាក្យប្រៀនប្រដៅ បានដល់ព្រះធម៌វិន័យ ។ បើព្រះធម៌វិន័យចំណែកណាមួយត្រូវលះបង់ហើយ ព្រះសាសនាចំណែកនោះ ក៏ឈ្មោះថាសាបសូន្យ ។ ការដែលព្រះសាសនារុងរឿងចម្រើន ឬសាបសូន្យ មិនមែនអាស្រ័យវត្ថុសម្ភារៈដូចកុដិ វិហារ ជាដើមទេ តែអាស្រ័យដែលពុទ្ធបរិស័ទអាចយល់ដឹងពាក្យប្រៀនប្រដៅ ហើយប្រព្រឹត្តបដិបត្តិតាមព្រះធម៌វិន័យនោះបានតិច ឬក៏ច្រើន ។

ហេតុចម្រើនឯសាបសូន្យនៃព្រះសាសនា

ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត ទ្រង់ត្រាស់នឹងភិម្ពិលភិក្ខុថា កាលតថាគត បរិនិព្វានហើយ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា គោរពកោតក្រែងក្នុងព្រះសាស្តា ក្នុងព្រះធម៌ ក្នុងព្រះសង្ឃ ក្នុងសិក្ខា និងក្នុងបដិសណ្ឋារៈ នេះឯងជាហេតុ ជាបច្ច័យឱ្យព្រះសាសនាតាំងនៅបានយូរ ។ (ចំណែកការសាបសូន្យមានន័យផ្ទុយគ្នា) ។

ឥរិយាបថដ៏សមរម្យរបស់ពុទ្ធបរិស័ទ

ការមានឥរិយាបថដ៏សមរម្យ ជាការសម្តែងលក្ខណៈថ្លៃថ្នូរដល់ខ្លួនឯង និងជាការសម្តែងសេចក្តីគោរពចំពោះអ្នកដទៃ អាចធ្វើឱ្យចិត្តរបស់អ្នកបានជួប បានឃើញកើតសេចក្តីត្រេកអរជ្រះថ្លាបាន។ បុគ្គលអ្នកបន្ទាបបន្ថ្មន់ខ្លួនគោរពអ្នកដទៃ តែងបានយសនិងបញ្ញា ព្រោះធ្វើឱ្យអ្នកដទៃមានចិត្តស្រឡាញ់ចង់អនុគ្រោះ ។ ការគោរពអ្នកដទៃ គឺជាអំណោយមួយដ៏ថ្លៃថ្លាបំផុត ក្នុងកិច្ចបដិសណ្ឋារៈ ព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរអាហារភោជនដ៏ឆ្ងៃមបំផុត គឺអាហារភោជនរបស់បុគ្គលអ្នកគោរពរាប់អានស្និទ្ធស្នាលគ្នា ។

ក្នុងការធ្វើនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ជាងសេចក្តីគោរពទាំងឡាយ ទាំងក្នុងផ្លូវលោក និងផ្លូវធម៌ គឺការគោរពចំពោះព្រះរតនត្រៃ ដែលជាសេចក្តីគោរពមានផលដ៏ប្រសើរថ្លៃថ្លា ។

សេចក្តីគោរពក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

ការមិនពាក់ស្បែកជើង មិនបាំងឆ័ត្រ មិននិយាយសើចលេង ឬរឿងរ៉ាវឥតប្រយោជន៍ផ្សេងៗ និងមិនខាកស្តោះក្នុងទីព្រះលាន ចេតីយ៍ ឬដើមពោធិព្រឹក្ស និងទីដែលតម្កល់ព្រះពុទ្ធរូប ហើយ នមស្សការថ្វាយរង្គំដោយគោរព ឈ្មោះថា

"ធ្វើសេចក្តីគោរពក្នុងព្រះពុទ្ធ" ។

កាលធម្មកថិកកំពុងសម្តែងធម៌ ជាអ្នកមិនដេកលក់ មិន ជជែករឿងរ៉ាវផ្សេងៗ មានចិត្តមិនរាយមាយ តាំងចិត្តស្តាប់ធម៌ ដោយគោរព ម្យ៉ាងទៀតជាអ្នកពោលធម្មីកថា សូធ្យសរភញ្ញ និងជាអ្នក មិនបំផ្លាញរោងស្តាប់ធម៌ ឈ្មោះថា

"ធ្វើសេចក្តីគោរពក្នុងព្រះធម៌" ។

ជាអ្នកក្រាបថ្វាយបង្គំតាមលំដាប់វស្សា និងជាអ្នកគោរព កោតក្រែងក្នុងភិក្ខុជាថេរៈ នវកនិងមជ្ឈិម គឺ ឱ្យអាសនៈ មិនឈរ ឬអង្គុយចំពីមុខ ឬជ្រៀតជ្រែត មិនអង្គុយលើអាសនៈខ្ពស់ជាង

ភិក្ខុ ។ ម្យ៉ាងទៀត មិនពាក់ស្បែកជើង ឬទទូរក្បាល វាសដៃ និយាយជាមួយភិក្ខុ ។ កាលបើមិនបានសូមអនុញ្ញាតអំពីភិក្ខុ ឬភិក្ខុមិនទាន់បានឱ្យឱកាស មិនគួរពោលធម្មីកថា ឬដោះស្រាយបញ្ហា ឈ្មោះថា **"ធ្វើសេចក្តីគោរពក្នុងព្រះសង្ឃ"** ។

(ស្រង់យកសេចក្តីអំពី ព្រះត្រៃបិដក និងអដ្ឋកថា)

ការគោរពព្រះរតនត្រៃតាមផ្លូវកាយគឺការថ្វាយបង្គំ

មនុស្សសម័យពុទ្ធកាល និយមក្រាបថ្វាយបង្គំព្រះរតនត្រៃ ដោយបញ្ចង្គប្រតិស្ឋាន ដែលជាការថ្វាយបង្គំប្រកបដោយអង្គ ៥ គឺ ក្បាលជង្គង់ ២ បាតដៃ ២ សិរសៈ (ក្បាល) ១ ឱ្យក្រាបចុះព្រមគ្នាស្មើជាមួយផ្ទៃ ហើយក្រាបថ្វាយបង្គំ ៣ ដង ។ តែបែបនេះបច្ចុប្បន្នសព្វថ្ងៃនិយមប្រើសម្រាប់កុលបុត្តអ្នកចូលទៅសូមបួសម្តងម្កាល ប៉ុណ្ណោះ ជាទូទៅនិយមថ្វាយបង្គំតាមបែបទេវបុត្ត និងទេវធីតា ។ តែនៅមានការ ថ្វាយបង្គំមួយបែបទៀត គឺអង្គុយបត់ជើងរាបស្មើនឹងផ្ទៃ។ តែវិរិយាបថនេះ សមគួរប្រើនៅពេលស្តាប់ធម៌ សូធ្យធម៌

ឬថ្វាយបង្គំមាតាបិតាគ្រូអាចារ្យវិញល្អជាង ។

វិធីថ្វាយបង្គំដោយបញ្ចុងបតិស្ឋានមាន៣ចង្វាក់

- ចង្វាក់ទី១ អង្គុយច្រហោង បញ្ឈរជង្គង់ឡើងទាំង២ដាក់កែងដៃទាំង២លើក្បាលជង្គង់ ប្រណមដៃទាំង២ឡើង ។
- ចង្វាក់ទី២ ខណៈថ្វាយបង្គំ គប្បីច្រត់ដៃស្តាំចុះត្រង់ផ្ទៃខាងមុខ បន្ទាប់មកច្រត់ដៃឆ្វេងឱ្យហួសដៃស្តាំបន្តិច ហើយច្រត់ជង្គង់ទាំង ២ ចុះលើផ្ទៃ ហើយរុញដៃស្តាំស្មើនឹងដៃឆ្វេង ។
- ចង្វាក់ទី៣ បង្ហោនកាយនិងសិរសៈសង្កត់ចុះលើខ្នងដៃទាំង ២ ថ្វាយបង្គំ ៣ ដង ។



រូបភាពទី១ រូបភាពទី២ រូបភាពទី៣

វិធីថ្វាយបង្គំតាមបែបទេវបុត្ត ទេវធីតាមាន៥ចង្វាក់

- ចង្វាក់ទី១ អង្គុយបត់ជើងរាបនឹងផ្ទៃ តែដាក់ដៃទាំង២លើភ្លៅ ។
- ចង្វាក់ទី២ អង្គុយលុតជង្គង់គឺច្រត់ជង្គង់ទាំង២ចុះ បើឧបាសកលុតជង្គង់ដូចទេវបុត្រ បើឧបាសិកាលុតជង្គង់ដូចទេវធីតា ហើយលើកដៃប្រណមឡើងទុកត្រង់ចន្លោះទ្រូង ។
- ចង្វាក់ទី៣ គឺលើកដៃឡើងប្រណម្យ ដោយឱ្យចុងម្រាមមេដៃទាំង ២ នៅក្នុងចន្លោះចិញ្ចើម ហើយធ្វើឱ្យចុងម្រាមចង្អុលដៃទល់ជើងសក់ខាងលើថ្ងាស ។
- ចង្វាក់ទី៤ គឺបន្ទាបខ្លួនក្រាបចុះ ឱ្យផ្ទៃមុខសង្កត់លើខ្នងដៃទាំង ២ ដាក់បាតដៃទាំង ២ ឱ្យរាបស្មើជាមួយផ្ទៃ សម្រាប់ឧបាសក ឱ្យកែងដៃទាំង ២ ទល់ក្បាលជង្គង់ទាំង ២ ចំណែកឧបាសិកា និយមធ្វើកែងដៃទាំង ២ តាបក្បាលជង្គង់ ។

- ចង្វាក់ទី៥ គឺងើបមុខឡើង ហើយបដិបត្តិតាមចង្វាក់ទី ៤ ឱ្យគ្រប់ ៣ ដង ជាកិច្ចបញ្ចប់វិធី ។



រូបភាពទី១



រូបភាពទី២



រូបភាពទី៣



រូបភាពទី៤



រូបភាពថ្វាយបង្គំបត់ជើង

ការបដិបត្តិចំពោះព្រះសង្ឃ

ព្រះពុទ្ធដីកាថា :-

ម្នាលភិក្ខុទាំងឡាយ ត្រកូលប្រកបដោយអង្គ ៩ បើភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅ ឬចូលទៅហើយ ក៏គួរអង្គុយនៅ គឺ :-

១- ក្រោកទទួលដោយសេចក្តីពេញចិត្ត (**មនាបេន បច្ចុដ្ឋេន្តិ**)

២- ថ្វាយបង្គំដោយសេចក្តីពេញចិត្ត (**មនាបេន អភិវាទេន្តិ**)

៣- ឱ្យអាសនៈដោយសេចក្តីពេញចិត្ត (**មនាបេន អាសនំ ទេន្តិ**)

៤- មិនលាក់លៀមរបស់ដែលមាន (**សន្តមស្ស នបរិគុយ្ហន្តិ**)

៥- របស់ដែលមានច្រើនឱ្យច្រើន (**ពហុកម្បិ ពហុកំ ទេន្តិ**)

៦- របស់ដែលថ្លៃថ្លាឱ្យរបស់ដែលថ្លៃថ្លា (**បណីតម្បិ បណីតំ ទេន្តិ**)

៧- ឱ្យដោយគោរព មិនឱ្យដោយមិនគោរព (**សក្កច្ចំ ទេន្តិ នោ អសក្កច្ចំ**) ។

៨- ចូលទៅអង្គុយជិតដើម្បីស្តាប់ធមិ (**ឧបនិសីទន្តិ ធម្មស្សវនាយ**)

៩- ត្រេកអរនឹងភាសិតរបស់ភិក្ខុនោះ (**ភាសិតមស្ស រមិស្សន្តិ**)

ត្រកូលដែលភិក្ខុមិនគួរចូលទៅ ក៏មានសេចក្តីផ្ទុយគ្នា ។

(**ស្រង់ចាកតម្ពីរអង្គុត្តរនិកាយ នវកនិបាត កុលសូត្រ**) ។

ការចើបឡើងឧទូលព្រះភិក្ខុសង្ឃ

បើអង្គុយលើកៅអី ឬអង្គុយរាបនឹងផ្ទៃ កាលភិក្ខុសង្ឃនិមន្តដើរមក និយមដោះស្បែកជើងងើបឡើងឈរទទូល កាលលោកនិមន្តដើរឆ្លងមកដល់ត្រង់មុខ និយមបង្អោនខ្លួនបន្តិចហើយប្រណមដៃសំពះ កាលលោកអង្គុយរៀបរយហើយ ទើបអង្គុយចុះដូចដើម បើមានទីវានដ៏សមរម្យ គួរក្រាបថ្វាយបង្គំព្រះភិក្ខុសង្ឃ ជាការធ្វើសេចក្តីគោរពម្តងទៀត ។

នៅពេលព្រះសង្ឃនិមន្តដើរ ទោះជានៅក្នុងទីវត្ត ឬក្រៅវត្ត មិនគួរធ្វើសេចក្តីគោរពដោយលុតជង្គង់ថ្វាយបង្គំ ឬបត់ជើងថ្វាយបង្គំទេ ព្រោះអាចធ្វើឱ្យយឺតដំណើរព្រះសង្ឃ ឬអាចគ្រោះថ្នាក់ដោយសារដំណើររបស់អ្នកដទៃ ដូចជាការលុតជង្គង់ថ្វាយបង្គំនៅតាមផ្លូវសាធារណៈជាដើម ។ បើចង់គោរព ត្រឹមតែលើកដៃសំពះប៉ុណ្ណោះ ចាត់ជាការប្រពៃ ។

ការតាមជូនដំណើរព្រះសង្ឃត្រឡប់

បើអង្គុយនិយមងើបឡើងឈរជូនដំណើរលោក កាលលោកនិមន្តដើរឆ្លងកាត់មកដល់ត្រង់មុខ និយមបង្ខោនកាយទាបចុះបន្តិច ព្រមទាំងលើកដៃសំពះ តែបើកំពុងជាប់សូធ្យធម៌ ឬស្តាប់ធម៌ មិនគួរងើបទេ ព្រោះនាំឱ្យរាយមាយក្នុងធម៌ និងខ្វះសេចក្តីគោរពចំពោះធម៌ផង ។

បើម្ចាស់ផ្ទះ ឬប្រធានកម្មវិធី (ម្ចាស់បុណ្យ) គួរតាមជូនដំណើរលោកឱ្យផុតបរិវេណផ្ទះ ឬបានឡើងរថយន្តចេញផុតទៅ

ហើយ។ តែនិយមដើរខាងឆ្វេងព្រះសង្ឃ ។ មុននឹងលោកចេញទៅ គួរបង្ខោនកាយលើកដៃសំពះផង ជាការសមរម្យ ។

ការឱ្យអាសនៈ(ទីអង្គុយ)ដល់ព្រះភិក្ខុសង្ឃ

និយមរៀបអាសនៈសង្ឃ អោយឃ្លាតអំពីឧបាសកឧបាសិកាបន្តិច បើប្រើកន្ទេលឬកម្រាលនិយមក្រាលកន្ទេលព្រះសង្ឃសង្កត់លើកន្ទេលក្រហស្ត បើបានព្រះសង្ឃខ្ពស់ជាងបន្តិច ជាការប្រពៃ ។

បើរៀបជាកៅអី និយមរៀបកៅអីព្រះសង្ឃនៅខាងមុខ បើប្រើត្រែ ត្រូវប្រើត្រែមានជើងមិនខ្ពស់ជាងកន្លះម៉ែត្រ ដើម្បីការពារការមានទោសដល់ព្រះសង្ឃ ក្នុងពុទ្ធវិន័យ ។ ម្យ៉ាងទៀត ក្នុងពុទ្ធវិន័យ ទ្រង់ហាមមិនឱ្យភិក្ខុអង្គុយលើត្រែជាមួយស្ត្រី ឬមនុស្សខ្ចើយ មិនតែប៉ុណ្ណោះសូម្បីអាសនៈវែងមានកន្ទេលជាដើម ក៏ទ្រង់ហាមដែរ រៀវតែវត្ថុនោះក្រាលនៅជាប់ជានិច្ច មិនកម្រើកផ្លាស់ប្តូរទៅទីដទៃ ។

ម្យ៉ាងទៀត កាលកំពុងអង្គុយលើអាសនៈ បើឃើញព្រះ-

សង្ឃនិមន្តមកបំណាងនឹងអង្គុយ គួរដើបឱ្យអាសនៈ ឬចាត់ចែងអាសនៈប្រគេនព្រះសង្ឃ ។ បើបុរសអង្គុយលើកៅអីក្នុងជួរជាមួយព្រះសង្ឃក៏បាន តែជាស្ត្រីគួរអង្គុយឱ្យឃ្លាតអំពីព្រះសង្ឃបន្តិច បើមានបុរសនៅត្រង់ចន្លោះកណ្តាលជាការសមរម្យណាស់ ។

ក្នុងពិធីបុណ្យនៅផ្ទះ បើនៅមិនទាន់ចូលដល់កម្មវិធីទេគួររៀបចំអាសនៈក្នុងទីដ៏សមគួរណាមួយ គ្រាន់បានព្រះសង្ឃសម្រួលតិរយាបថនិងសម្រាកកាយ បើបានក្នុងទីដ៏ស្ងាត់បន្តិច ក៏ជាការប្រពៃដើម្បីលោកបានឱកាសសន្ទនាធម៌គ្នា ។ តែបើរៀបនៅលើផ្ទះដែលមានបង្គន់ឬបន្ទប់ទឹក គួរពោលវាចាបវារណាឱ្យលោកនិមន្តប្រើប្រាស់នូវបង្គន់ឬបន្ទប់ទឹកតាមសប្បាយផង ។

វិធីប្រគេនចង្ហាន់ព្រះសង្ឃ

អាហារដែលត្រូវឆាន់កន្លងបំពង់ក ដូចជាបាយ ឬថ្នាំជាដើម លុះត្រាតែទាយកបានប្រគេនត្រឹមត្រូវតាមអង្គប្រគេនក្នុងព្រះវិន័យ ទើបភិក្ខុអាចឆាន់បាន មិនត្រូវទោសក្នុងពុទ្ធវិន័យ ។ តែបើវត្ថុសម្រាប់ប្រើប្រាស់ខាងក្រៅ ដូចជា ចាន កែវ ស្លាបព្រា ជាដើមដែលមិនត្រូវឆាន់កន្លងបំពង់កចូលទៅ ទាយកមិនបាច់ប្រគេនក៏បាន ។

នៅពេលចូលទៅប្រគេនចង្ហាន់ ទាយកគប្បីចូលឱ្យបានជិតភិក្ខុអ្នកទទួលចម្ងាយ ៧០ សង់ទីម៉ែត្រ ដោយកំណត់អំពីក្បាលជង្គង់របស់លោក មកដល់អវយវៈរបស់ទាយកអ្នកប្រគេន វៀរតែដៃដែលលាតចេញប្រគេន ។ ការប្រគេន នឹងចាប់វត្ថុណាប្រគេនមុនក៏បាន តែគួរប្រគេនវត្ថុណាដែលនៅជិតលោកមុន ដើម្បីស្រួលប្រគេនវត្ថុដទៃខាងក្រោយទៀត ។

បើឧបាសក និយមអង្គុយលុតជង្គង់ប្រគេន ដូចទេវបុត្រ សូមមើលរូបភាពខាងក្រោមនេះ ។

ឧបាសកប្រគេនចង្ហាន់ភិក្ខុសង្ឃ

បើឧបាសិកានិយមអង្គុយលុតជង្គង់ប្រគេន ដូចទេវធីតា សូមមើលរូបភាពខាងក្រោមនេះ ។



ឧបាសិកាប្រគេនចង្ហាន់ភិក្ខុសង្ឃ

ការបដិបត្តិនៅពេលច្រាស្រ័យសន្ទនាជាមួយព្រះសង្ឃ

បើឧបាសក

និយមអង្គុយលត់ជង្គង់ ឬអង្គុយបត់ជើងរាប ប្រណមដៃឆ្ពោះទៅរកព្រះសង្ឃ ឱ្យល្មមអាចសន្ទនាស្តាប់បានច្បាស់ តែបើមានករណីចាំបាច់ត្រូវប្រញាប់ ដូចត្រូវរាយការរឿងរ៉ាវផ្សេងៗ ដែលមិន

ត្រូវប្រើវេលាវែង ឬក៏ទីកន្លែងអង្គុយមិនអំណោយ គឺមិនសមរម្យ នឹងឈរប្រាស្រ័យសន្ទនាដោយឥរិយាបថសង្រួមក៏បាន ។



ឧបាសកប្រាស្រ័យជាមួយភិក្ខុសង្ឃ

បើឧបាសិកា

ក៏មានឥរិយាបថសមរម្យដូចឧបាសកដែរ តែមិនសូវនិយមឈរសន្ទនា ។ . និយមអង្គុយឱ្យឃ្លាតឆ្ងាយអំពីព្រះសង្ឃជាងបុរសបន្តិច ។ ក្នុងករណីមានព្រះសង្ឃតែមួយអង្គ បើមានបំណងចង់ចូលទៅប្រាស្រ័យកិច្ចការជាមួយព្រះសង្ឃ គប្បីយកក្មេងប្រុសដឹងក្តី

ម្ដាក់ទៅជាមួយផង ដើម្បីជៀសវាងការមានទោសដល់ព្រះភិក្ខុ
សង្ឃក្នុងពុទ្ធវិន័យ ។



ឧបាសិកាប្រាស្រ័យជាមួយភិក្ខុសង្ឃ

បុណ្យទក្ខិណានុប្បទាន

បន្ទាប់អំពីបុណ្យសង្ឃទាន នៅមានបុណ្យមួយទៀត ដែលពុទ្ធបរិស័ទនិយមធ្វើ គឺបុណ្យទក្ខិណានុប្បទាន (បុណ្យឧទ្ទិសផលដល់ពួកញាតិអ្នកធ្វើមរណៈកាលទៅ) បុណ្យនេះតែងនិយមធ្វើក្រោយពេលដែលញាតិបានស្លាប់ទៅថ្មីៗ ដូចជាបុណ្យគម្រប់ ៧ ថ្ងៃ គម្រប់ ១០០ ថ្ងៃ និងខួបគម្រប់ ១ ឆ្នាំ ពិសេសនៅរដូវបុណ្យភ្ជុំបិណ្ឌមួយឆ្នាំៗ ដោយមានជំនឿថា ផលបុណ្យនឹងបានដល់ពពួកញាតិអ្នកធ្វើមរណកាលទៅហើយ ។ តែក៏នៅមានសេចក្តីសង្ស័យខ្លះថា រយៈពេលប៉ុន្មានទើបញាតិត្រឡប់មកទទួលយក ? ផលបុណ្យនឹងសម្រេចដល់ញាតិនោះដូចម្តេច ? តើមានវិធីដទៃក្រៅអំពីទក្ខិណានុប្បទាននេះ អាចឱ្យសម្រេចផលដល់ញាតិអ្នកស្លាប់ដែរឬទេ ?

ដើម្បីយល់ច្បាស់ក្នុងទក្ខិណានុប្បទាននេះ សូមពិចារណានូវព្យញ្ជនៈនិងអត្ថនេះថា ទក្ខិណានុប្បទានមានសេចក្តីយ៉ាងណា ? ហេតុដូចម្តេចទើបទ្រង់ឱ្យធ្វើទក្ខិណានុប្បទាន ? ការឧទ្ទិសនូវទក្ខិណានុប្បទាននោះដូចម្តេច ? ហេតុអ្វីចាំបាច់មានព្រះសង្ឃមកទទួលនូវទាន ? ផលនៃទក្ខិណាទាន រមែងសម្រេចដល់ប្រេតនោះដូចម្តេច ? ។

ពាក្យថាឧក្ខិណានុប្បទាន

ពាក្យថាឧក្ខិណានុប្បទាន ជាពាក្យរួមរបស់ភាសាបាលីពីរបទ គឺ **ឧក្ខិណា + អនុប្បទាន** ។ **ឧក្ខិណា** ប្រែថា ទានដែលបុគ្គលជឿកម្មនិងផល ហើយឱ្យ គឺជាឈ្មោះនៃបុណ្យកុសល ។ **អនុប្បទាន** ប្រែថា តាមឧទ្ទិសឱ្យ ។ ដូច្នេះ ពាក្យថា **ឧក្ខិណានុប្បទាន** ប្រែថា ទក្ខិណាទានដែលបុគ្គលតាមឧទ្ទិសឱ្យដល់បុគ្គលអ្នកស្លាប់ទៅហើយ ឬអំណោយដែលគេឧទ្ទិសទក្ខិណាទានចំពោះបុគ្គល ដែលទៅកាន់បរលោកហើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ណែនាំឱ្យធ្វើឧក្ខិណានុប្បទាន

ព្រះដ៏មានព្រះភាគ ទ្រង់បានឃើញច្បាស់នូវសេចក្តីទុក្ខ និងស្រែកឃ្លានដ៏ខ្លាំងក្លា របស់ពួកសត្វអ្នកចូលទៅកាន់ប្រេតវិស័យ មិនឃើញមានហេតុដទៃនាំឱ្យបានសម្បត្តិ ដូចកសិកម្ម ពាណិជ្ជកម្ម គោរក្ខកម្ម ជាដើម ក្នុងបេត្តភូមិនោះឡើយ ពួកប្រេតទាំងនោះអាចញ៉ាំងជីវិតឱ្យរស់នៅ ដោយសារផលនៃទានដែលញាតិមិត្តសម្លាញ់

ឧទ្ទិសឱ្យអំពីមនុស្សលោកនេះប៉ុណ្ណោះ ។ ម្យ៉ាងទៀតពួកប្រេតនោះ សូម្បីដើរត្រេចស្វែងរកជួបជនជាញាតិហើយ ក៏មិនអាចស្រែកអង្វរសុំថា សូមលោកមេត្តាឱ្យនូវវត្ថុឈ្មោះនេះ ឬវត្ថុឈ្មោះនោះដល់ពួកយើងដូច្នោះឡើយ ព្រោះហេតុដូច្នោះ ព្រះដ៏មានព្រះភាគទើបទ្រង់ត្រាស់ក្នុងតិរោកុឌ្ឌសូត្រលើកដល់ជនជាញាតិថា : **បុគ្គល កាលរលើកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត និងជាសម្ឡាញ់របស់អញដូច្នេះហើយ គួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ ។**

ទក្ខិណាទាននេះ **ក្នុងអដ្ឋកថាសិង្គាលសូត្រ** បានពន្យល់ថា បុគ្គលជាញាតិ គប្បីតាមឱ្យនូវទក្ខិណាទានដល់ញាតិអ្នកធ្វើមរណៈកាលទៅ ចាប់ផ្តើមតាំងអំពីថ្ងៃទី៣ បន្ទាប់អំពីថ្ងៃស្លាប់ទៅ ។

តាមសេចក្តីនេះ សម្តែងឱ្យឃើញថា បុគ្គលជាញាតិអាចធ្វើទក្ខិណានុប្បទាន ក្រោយអំពីញាតិស្លាប់ទៅបាន៣ថ្ងៃ ថ្ងៃណាមួយក៏

អាចធ្វើបាន ។

ម្យ៉ាងទៀត មិនទ្រង់ឃើញហេតុដទៃណា ដែលពួកញាតិគប្បីធ្វើឱ្យបានសម្រេចនូវប្រយោជន៍ដល់ប្រេតជាញាតិនោះ មានតែទក្ខិណាទាននេះប៉ុណ្ណោះ ទើបសម្រេចផលដ៏ល្អឿនរហ័យដល់ប្រេតជាញាតិដូចជាទឹកដែលហូរធ្លាក់ចុះអំពីកំពូលភ្នំ ។ សមដូចព្រះពុទ្ធដីកាក្នុង **តិរោកុឌ្ឌសូត្រ**ថា :- **ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។ (ម្យ៉ាងទៀត) ផ្នូរទឹកមានទន្លេនិងស្ទឹងជាដើមដ៏ពេញ រមែងញុំាងសាគរឱ្យពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។**

ទាយកជាញាតិគប្បីឲ្យទក្ខិណាទានដូចម្តេច?

ទាយកជាញាតិ ជាហេតុវិសេសមួយក្នុងការញុំាងផលនៃទក្ខិណាទានឱ្យកើតឡើងដល់ប្រេតទាំងឡាយជាញាតិ។ សូម្បីកាល

មានព្រះសង្ឃមកជាបដិគ្គាហកៈនៃទាន ទាំងពួកប្រេតក៏មករងចាំទទួលអនុមោទនាយក តែបើទាយកជាញាតិមិនបានឧទ្ទិសឱ្យនូវចំណែកបុណ្យនោះទេ ក៏មិនអាចញុំាងកុសលចិត្តប្រកបដោយសោមនស្សរីករាយ ឱ្យកើតឡើងដល់ពួកប្រេតទាំងឡាយនោះឡើយ ដូចពួកប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារ មិនអាចទទួលនូវចំណែកបុណ្យបាន ព្រោះព្រះរាជាព្រះបាទពិម្ពិសារថ្វាយទានដល់ព្រះពុទ្ធដ៏ប្រសើរហើយ តែមិនបានឧទ្ទិសឱ្យ ព្រោះហេតុដូច្នោះ ទើបព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ក្នុងតិរោកុឌ្ឌសូត្រណែនាំទាយកជាញាតិថា : **ញាតិទាំងឡាយឯណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយយ៉ាងនេះថា ទាននេះចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខចុះ ។**

សួរថា ពាក្យដែលទ្រង់ឧទ្ទិសឱ្យផលនៃទក្ខិណាទានដល់ប្រេតជាញាតិ មិនខុសក្នុងរឿងកម្មផលទេឬ? ព្រោះកម្មរបស់បុគ្គល

ម្នាក់ធ្វើ ហេតុអ្វីទើបសម្រេចផលដល់បុគ្គលម្នាក់ទៀត ?

ព្រះពុទ្ធដីកានេះ **អដ្ឋកថានៃតិរោកុឌ្ឌសូត្រ** លោកពន្យល់ថា សូម្បីកាលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ទាននេះចូរមានដល់ញាតិទាំងឡាយក៏ដោយ កម្មដែលបុគ្គលម្នាក់ធ្វើហើយ រមែងមិនឱ្យផលដល់បុគ្គលម្នាក់ទៀត តែវត្ថុនោះដែលញាតិឱ្យដោយការឧទ្ទិសយ៉ាងនេះប៉ុណ្ណោះ រមែងជាបច្ច័យដល់កុសលកម្មរបស់ញាតិទាំងឡាយ (អ្នកកើតជាប្រេតនោះ) ។

ពាក្យឧទ្ទិសបុណ្យដល់ញាតិអ្នកស្លាប់ដោយសេចក្តីសង្ខេប

ឥទំ នោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ

ប្រែថា ទាននេះចូរមានដល់ញាតិទាំងឡាយរបស់ខ្ញុំ សូមញាតិទាំងឡាយចូរបានដល់នូវសេចក្តីសុខចុះ ។

ហេតុដូចម្តេចចាំបាច់មានព្រះសង្ឃមកឆន្ទលន្ទភាន?

ព្រះសង្ឃមានប្រយោជន៍ដល់ទក្ខិណានុប្បទាន ២ យ៉ាងគឺ :-

១- ព្រះសង្ឃជាស្រែបុណ្យដ៏ប្រសើរ អាចញុំងទាយកអ្នក

មានពូជគឺទេយ្យធម៌សូម្បីតិចតួច ឱ្យបានសម្រេចនូវបុណ្យកុសលច្រើន ។ បើមិនមានព្រះសង្ឃមកធ្វើជាបដិគ្គាហក: នៃទក្ខិណាទាននោះទេ ទាយកធ្វើដូចម្តេចនឹងបាននូវបុណ្យកុសលឧទ្ទិសដល់ប្រេតជាញាតិ ។

២- ព្រះសង្ឃជាអ្នកមានសីល មានវត្តបដិបត្តិល្អ អាចញ៉ាំងចិត្តរបស់ពួកប្រេតឱ្យជ្រះថ្លាត្រេកអរបាន ។ **នៅក្នុងអដ្ឋកថាទក្ខិណាវិភង្គសូត្រ** មានសម្តែងអំពីប្រវត្តិរបស់នាយព្រានម្នាក់ឈ្មោះ **ឥន្ទ្រមាណៈ** កាលបំណងនឹងឧទ្ទិសឱ្យទក្ខិណាទានដល់ពួកញាតិអ្នកស្លាប់ទៅ ក៏បានឱ្យនូវទានដល់ភិក្ខុទ្រុស្តសីលមួយរូបនោះឯង អស់ពេលពាក្រា ក្នុងគ្រាទី៣ ពួកប្រេតនោះក៏ស្រែកឡើងថា ភិក្ខុទ្រុស្ត សីលបានបួនឆាន់អាហារអស់ហើយ ។ នៅពេលក្រោយមកព្រាននោះ ក៏ឱ្យទានដល់ភិក្ខុអ្នកមានសីលមួយរូបដែលនិមន្តមកដល់ពេលនោះផលនៃទក្ខិណាទានក៏បានសម្រេចដល់គេ (គឺដល់ប្រេតនោះ) ។ ព្រោះហេតុដូច្នោះ ព្រះពុទ្ធជាម្ចាស់ទើបទ្រង់ត្រាស់ក្នុង

តិរោកុឌ្ឌសូត្រថា :- **មានតែទក្ខិណាទាននេះឯង ដែលបុត្តលឱ្យ ហើយ ដំកល់ទុកប្រពៃហើយក្នុងសង្ឆ ទើបសម្រេចផលដោយរួស រាន់ ដើម្បីបយោជន៍ដល់ប្រេតនោះ អស់កាលជាយូរអង្វែង ។**

ផលនៃទក្ខិណាទានបានសម្រេចដល់ប្រេត ជាញ្ញាតិនោះតើដូចម្តេច?

សូម្បីទាយកជាញ្ញាតិ បានឱ្យនូវទក្ខិណាទានក្នុងសង្ឆ ថែម ទាំងបានឧទ្ទិសឱ្យនូវចំណែកបុណ្យ តែបើប្រេតជាញ្ញាតិនោះមិន បានមកអនុមោទនាទទួលយកទេ ផលក៏មិនបានសម្រេចដល់ លុះត្រា ប្រេតជាញ្ញាតិនោះមកអនុមោទនាទទួលយកដោយខ្លួនឯង ទើបអាចទទួលបាននូវផលនៃទក្ខិណានុប្បទាននោះ ។ ព្រោះហេតុ នោះ ព្រះពុទ្ធជាម្ចាស់ទើបទ្រង់សម្តែងក្នុងតិរោកុឌ្ឌសូត្រថា :-

ប្រេតជាញ្ញាតិទាំងនោះ ជាអ្នកមកប្រជុំគ្នា មកជួបជុំគ្នា ហើយ ក្នុងមន្ទីរឱ្យទាននោះ កាលបើបាយនិងទឹកមានល្មមត្រាន់ **ក៏អនុមោទនាដោយគោរព ។**

ទក្ខិណាទានប្រកបដោយអង្គ៣

១-បេតានំ អត្តនោ អនុមោទនេន ប្រែតមកអនុមោទនាដោយខ្លួនឯង ។

២- ទាយកានំ ឧទ្ទិស្សន ទាយកជាញាតិបានឧទ្ទិសចំណែកបុណ្យឱ្យ ។

៣- ទក្ខិណេយ្យសម្បទាយ ដល់ព្រមដោយទក្ខិណេយ្យបុគ្គល (បុគ្គលអ្នកញ៉ាំងទក្ខិណាទានឱ្យមានផលច្រើន បានដល់ព្រះសង្ឃ និងលោកអ្នកមានសីល) ។

ទក្ខិណាទានដែលប្រកបដោយ អង្គទាំង៣នេះហើយ រមែងសម្រេចផលដល់ពួកប្រែតជាញាតិយ៉ាងឆាប់រហ័ស ដូចពួកប្រែតជាព្រះញាតិរបស់ព្រះបាទពិម្ពិសារដូច្នោះ ។

ប្រវត្តិញាតិរបស់ព្រះបាទពិម្ពិសារកើតជាប្រែត

មានសេចក្តីដំណាលថា :- ក្នុងកប្បទី៩២ រាប់ត្រឡប់ពីកប្បបច្ចុប្បន្ននេះទៅ មាននគរឈ្មោះ **ភាសី** ក្នុងនគរនោះ មាន

ព្រះរាជានាមថា **ជយសេន** ព្រះទេវីរបស់ព្រះរាជានោះព្រះនាមថា **សិរិមា** ។ ព្រះពោធិសត្វព្រះនាមថា **បុស្ស** កើតក្នុងគភ៌បស់ព្រះនាង កាលញាណចាស់ក្លាហើយ ក៏ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណបានជាព្រះពុទ្ធ ព្រះរាជាជយសេនទ្រង់កើតសេចក្តីត្រេកអរជ្រះថ្លាក្នុងព្រះទ័យថា :- "ព្រះឱរសរបស់យើង ទ្រង់ចេញសាងព្រះផ្នួស ហើយបានត្រាស់ដឹងជាព្រះពុទ្ធ ដូច្នេះព្រះពុទ្ធក៏ជារបស់យើង ព្រះធម៌ក៏ជារបស់យើង ព្រះសង្ឃក៏ជារបស់យើង យើងប៉ុណ្ណោះត្រូវឧបដ្ឋាកជានិច្ចគ្រប់វេលា បុគ្គលដទៃមិនគួរឡើយ" ទ្រង់គិតដូច្នេះហើយ ទ្រង់ឧបដ្ឋាកដោយព្រះអង្គឯង មិនទ្រង់ប្រទានឱកាសដល់អ្នកដទៃណាឡើយ ។

កាលណោះ ម្ចាស់បង ម្ចាស់ប្អូនរបស់ព្រះដ៏មានព្រះភាគផ្សេងព្រះមាតាពីព្រះអង្គ នាំគ្នាត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយតែងកើតឡើងដើម្បីសត្វលោកទាំងពួង មិនដើម្បីប្រយោជន៍ដល់បុគ្គលម្នាក់ប៉ុណ្ណោះទេ តែព្រះបិតារបស់យើងមិនទ្រង់ប្រទានឱកាស

ដល់យើងនិងអ្នកដទៃឡើយ តើយើងនឹងត្រូវបានឧបដ្ឋាកដោយឧបាយយ៉ាងណាហ្ន៎ ? កាលទ្រង់ត្រិះរិះឃើញហើយ ក៏ទ្រង់ធ្វើឱ្យស្រុកជនបទរបស់ព្រះរាជាកើតភាពចម្រូងចម្រាស់ខុសច្បាប់យ៉ាងខ្លាំង ។ កាលនោះព្រះរាជាទ្រង់ជ្រាបដំណឹង ទើបទ្រង់បញ្ជូនព្រះរាជឱរសទាំង៣ព្រះអង្គនោះទៅបង្ក្រាប ព្រះរាជឱរសទាំងនោះបានបង្ក្រាបស្រេចហើយក៏ត្រឡប់មក ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យណាស់ ក៏ទ្រង់ប្រទានពរថា បើរាជបុត្តប្រាថ្នាវត្ថុណា ចូរទទួលវត្ថុនោះចុះ ។ ព្រះរាជឱរសទាំងនោះ ទ្រង់ក្រាបទូលថា ខ្ញុំទូលព្រះបង្គំប្រាថ្នាឧបដ្ឋាកព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រះរាជាក៏ទ្រង់បដិសេធ សុំឱ្យទទួលយកពរដទៃទៀតចុះ ។ ព្រះរាជឱរសក្រាបទូលថា ទូលព្រះបង្គំមិនប្រាថ្នាពរដទៃទេ ។ ព្រះរាជាត្រាស់ថា បើដូច្នេះ អ្នកចូរកំណត់វេលាទទួលយកចុះ ។ ព្រះរាជឱរសទូលសូម៧ឆ្នាំ ។ ព្រះរាជាមិនព្រះរាជទាន ។ ព្រះរាជឱរសទើបទូលសូមថយចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥ ឆ្នាំ ៤ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ៧

ខែ ៦ ខែ ៥ ខែ ៤ ខែ រហូតដល់ត្រៃមាស (៣ខែ) ព្រះរាជា ទើបទ្រង់ ព្រះរាជទានឱ្យ ។

ព្រះរាជឱរសទាំងនេះ កាលបានទទួលព្រះរាជទានពរហើយ ក៏ទ្រង់រីករាយព្រះទ័យខ្លាំងណាស់ ក៏ទ្រង់នាំគ្នាចូលទៅគាល់ព្រះដ៏មានព្រះភាគ ថ្វាយបង្គំហើយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គបំណងឧបដ្ឋាកព្រះដ៏មានព្រះភាគអស់ត្រៃមាស សូមព្រះដ៏មានព្រះភាគមេត្តាអនុគ្រោះទ្រង់ទទួលចាំវស្សាអស់ត្រៃមាសសម្រាប់ខ្ញុំព្រះអង្គផងចុះ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ទទួលដោយតុណ្ហីភាព គឺស្ងៀម ។ បន្ទាប់មក ព្រះរាជឱរសក៏ទ្រង់ឱ្យដំណឹងដល់នាយស្មៀន ក្នុងជនបទរបស់ព្រះអង្គដើម្បីបានជ្រាបថា "ព្រះអង្គនឹងឧបដ្ឋាកព្រះដ៏មានព្រះភាគអស់ត្រៃមាសនេះ សុំលោកចាត់ចែងគ្រឿងឧបដ្ឋាកឱ្យដល់ព្រមគ្រប់យ៉ាង មានការកសាងព្រះវិហារជាដើម ។ កាលបានទ្រង់ជ្រាបដំណឹងថា នាយស្មៀនបានចាត់ចែងគ្រឿងឧបដ្ឋាកសព្វគ្រប់ហើយ

ទើបព្រះរាជឱរសទាំងនោះ ក៏ទ្រង់ស្លៀកដណ្តប់សំពត់កាសាយៈ ព្រមដោយបុរសជាវេយ្យាវច្ចៈ ២៥០ នាក់ ហែហមនាំព្រះដ៏មានព្រះភាគស្តេចយាងទៅកាន់ជនបទនោះ ហើយក៏ទ្រង់បវារណាថ្វាយនូវព្រះ វិហារដើម្បីចាំវស្សា និងនៅឧបដ្ឋាកព្រះមានព្រះភាគដោយគោរពរហូតអស់ ៣ ខែ ។

គហបតីបុត្តម្នាក់ មាននាទីជាអ្នករក្សាឃ្លាំងឱ្យព្រះរាជឱរសទាំងនោះ ព្រមទាំងភរិយា ជាអ្នកមានសទ្ធាជ្រះថ្លាបានបដិបត្តិក្នុងការថ្វាយទានដល់ព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាម្ចាស់ជាប្រមុខដោយសេចក្តីគោរព ។ នាយស្លឹនក៏នាំគហបតីបុត្តនោះឱ្យធ្វើការឱ្យទានដោយគោរព មួយអន្លើដោយបុរសអ្នកជនបទ ១១000 នាក់ ។

បណ្តាជនទាំងនោះ ពួកជនខ្លះ មានចិត្តឥស្សាមច្ឆរិយៈគ្របសង្កត់ ពួកគេក៏ធ្វើសេចក្តីអន្តរាយដល់ទាន តីស៊ីទេយ្យធម៌ដោយខ្លួនឯងខ្លះ ឱ្យដល់ពួកកូនខ្លះ នឹងយកភ្លើងដុតរោងទានជាដើម ។ កាលដល់វេលាបវារណាចេញវស្សាហើយ ព្រះរាជឱរសទាំងឡាយ

ក៏ទ្រង់ធ្វើសក្ការៈដ៏ធំដល់ព្រះដ៏មានព្រះភាគជាម្ចាស់ ហើយទ្រង់បៀហេមព្រះដ៏មានព្រះភាគស្តេចយាងទៅកាន់រាជនិវេសន៍របស់ព្រះរាជបិតាវិញ ។ ព្រះដ៏មានព្រះភាគស្តេចទៅនៅទី នោះហើយក៏បរិនិព្វានទៅ ។ ព្រះរាជា ព្រះរាជបុត្ត នាយស្មៀន និងនាយរក្សាឃ្លាំងព្រមទាំងជនជាបរិវារ ធ្វើកាលកិរិយាហើយតាមលំដាប់ ក៏ទៅកើតក្នុង ស្ថានសួគ៌ ចំណែកឯពួកជនដែលមានចិត្តឥស្សានិងមច្ឆរិយៈក៏នាំគ្នាទៅកើតក្នុងនរក ។ ពួកជនទាំង ២ ពួកនោះក៏ចុតិអំពីស្ថានសួគ៌ចូលកាន់ស្ថានសួគ៌ ចុតិអំពីនរកចូលទៅកាន់នរក ដោយប្រការយ៉ាងនេះ កប្បក៏កន្លងទៅ ៩២ កប្ប (ផែនដី) ។

ក្នុងភទ្រកប្បនេះ ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **កស្សបៈ** ជនដែលត្រូវឥស្សាមច្ឆរិយៈគ្របសង្កត់នោះ ក៏មកកើតជាប្រេត ។ កាលនោះ ពួកមនុស្សទាំងឡាយ តែងធ្វើទានឧទ្ទិសដល់ពួកប្រេតជាញាតិរបស់ខ្លួនៗថា :- **ឥទំ ន ញាតំ ញាតីនំ ហោន្តុ** សូមទាននេះ ចូរមានដល់ពពួកញាតិរបស់ខ្ញុំ ។

ពួកប្រេតទាំងនោះក៏បាននូវសម្បត្តិ ។ ឯពួកប្រេតទាំងនេះ មិនបានឃើញញាតិណាមួយឧទ្ទិសផលឱ្យសោះ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគអង្គនោះ ទូលសួរថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន តើធ្វើយ៉ាងណា ទើបពួកយើងបានទទួលសម្បត្តិខ្លះ ព្រះដ៏មានព្រះភាគត្រាស់ថា ក្នុងអនាគតកាល នឹងមានព្រះពុទ្ធព្រះនាមថា **គោតម** ក្នុងកាលណោះ នឹងមានព្រះរាជាព្រះនាម **ពិម្ពិសារ** ក្នុង ៩២កប្ប អំពីភទ្រកប្បនេះ ព្រះអង្គបានជា ញាតិរបស់ពួកលោក ព្រះអង្គបានថ្វាយទានដល់ព្រះពុទ្ធជាម្ចាស់ ហើយនឹងឧទ្ទិសនូវចំណែកបុណ្យដល់ពួកលោក ពួកលោកនឹងបាន ក្នុងកាលណោះ ។ ពួកប្រេតនោះ បានឮព្រះពុទ្ធតម្រាស់យ៉ាងនេះ ក៏នឹកសប្បាយចិត្តយ៉ាងក្រៃលែង ហាក់ដូចជាព្រះពុទ្ធត្រាស់ថា ពួកអ្នកនឹងបានទទួលក្នុងថ្ងៃស្អែកនេះ ។

លុះកាលកន្លងទៅមួយពុទ្ធន្តរ (មួយចន្លោះព្រះពុទ្ធ) ព្រះដ៏មានព្រះភាគជាម្ចាស់នៃយើង ក៏ឧបត្តិកឡើងក្នុងលោក ព្រះរាជ

ឱរសទាំង ៣ ព្រះអង្គនោះ ក៏ចុតិចាកទេវលោក មួយអន្លើដោយ បុរស់ទាំងនោះ ២៥០ នាក់ ទៅកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងដែន មគធៈ ក៏បួសជាឥសីបានជាជដិល ៣ រូប នៅគយាសីសប្រទេស ។ នាយស្មៀនក្នុងជនបទ បានជាព្រះបាទពិម្ពិសារ គហបតីបុត្តអ្នករក្សា ឃ្លាំង បានជាមហាសេដ្ឋីឈ្មោះវិសាខៈ ភរិយារបស់គហបតីបុត្តនោះ បានជាធីតារបស់សេដ្ឋីឈ្មោះធម្មទិន្នា បរិស័ទដ៏សេស បានជារាជ បរិស័ទរបស់ព្រះបាទពិម្ពិសារទាំងអស់ ។

ព្រះដ៏មានព្រះភាគនៃយើង ទ្រង់បានត្រាស់ដឹងជាព្រះពុទ្ធ បាន៧សប្តាយ៍ ស្តេចក៏យាងមកកាន់ក្រុងពារាណសីតាមលំដាប់ ទ្រង់ សម្តែងធម្មចក្កប្បវត្តិសូត្រប្រោសភិក្ខុបញ្ចវគ្គីយ៍ជាដើម ទ្រង់ទូន្មានជដិល ៣រូប ដែលមានបរិវារ១000 ទើបស្តេចយាងទៅកាន់ក្រុងរាជគ្រឹះ ហើយ សម្តែងធម៌ដល់ព្រះបាទពិម្ពិសារឱ្យតាំងនៅក្នុងសោតាបត្តិផល ព្រម ដោយព្រាហ្មណ៍និងគហបតីអ្នកស្រុកមគធៈ ១១ម៉ឺននាក់ ក្នុងថ្ងៃ

នោះឯង ព្រះបាទពុម្ពិសារមានព្រះទ័យជ្រះថ្លាក្រាបទូលអារាធនា
ព្រះដ៏មានព្រះភាគជាម្ចាស់ ដើម្បីទទួលភត្តាហារក្នុង ថ្ងៃស្អែក ។
ក្នុងថ្ងៃដែលព្រះដ៏មានព្រះភាគស្តេចយាងទៅទទួលមហាទានរបស់
ព្រះរាជាពិម្ពិសារនោះឯង ពពួកប្រេតទាំងនោះ ក៏នាំគ្នាឈរឡោម
ព័ទ្ធរាជនិវេសន៍ ដោយសង្ឃឹមថា ឥឡូវនេះ ព្រះរាជាជាញាតិនឹង
ឧទ្ទិសទានដល់យើងៗ ។ ចំណែកឯព្រះបាទពិម្ពិសារ បានទ្រង់ថ្វាយ
ទានហើយទ្រង់មានព្រះទ័យខ្វល់ខ្វាយតិតដល់ការ ចាត់ចែងសេនា-
សនៈថ្វាយព្រះដ៏មានព្រះភាគជាម្ចាស់ ក៏មិនបានគិតឧទ្ទិសផលដល់
អ្នកណាៗឡើយ ។ ពួកប្រេតទាំងនោះក៏អស់សង្ឃឹម លុះពេល
កណ្តាលអាធ្រាតទើបនាំគ្នាស្រែក ដែលមានសម្លេងគួរឱ្យភ័យខ្លាច
យ៉ាងក្រៃលែងក្នុងរាជនិវេសន៍ ។

ព្រះរាជាទ្រង់ឃើញហេតុយ៉ាងនេះ ទ្រង់មានព្រះទ័យតក់
ស្លុតយ៉ាងខ្លាំង ហើយក៏ទ្រង់នាំរឿងនេះទៅក្រាបទូលសួរព្រះដ៏មាន
ព្រះភាគជាម្ចាស់ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ថ្វាយព្រះពរ

មហាបពិត្រ សូមមហាបពិត្រកុំទ្រង់ព្រួយព្រះទ័យអ្វី ទីឯមិនមានវត្ថុ
កាចអាក្រក់ដល់មហាបពិត្រឡើយ យប់មិញនេះ ពពួកព្រះញាតិ
ចាស់ៗរបស់មហាបពិត្រមានកើតជាប្រេត ពពួកប្រេតទាំងនោះ
ក្រាច់នៅអស់មួយចន្លោះព្រះពុទ្ធហើយ ដោយសេចក្តីសង្ឃឹមចំពោះ
ព្រះមហាបពិត្រថា កាលទ្រង់បានថ្វាយទានដល់ព្រះពុទ្ធជាម្ចាស់
ហើយ ទីឯទ្រង់ឧទ្ទិសនូវចំណែកបុណ្យដល់យើង កាលថ្ងៃម្សិលមិញ
ព្រះមហាបពិត្រមិនបានឧទ្ទិសចំណែកបុណ្យដល់ពួកប្រេតនោះ ពួក
ប្រេតនោះក៏អស់សង្ឃឹម ទើបនាំគ្នាធ្វើសម្ដែងកូរឱ្យភ័យខ្លាចដូច្នេះ។
ព្រះបាទពិម្ពិសារក្រាបទូលថា បើដូច្នេះ កាលខ្ញុំព្រះអង្គបានថ្វាយ
ទានហើយឧទ្ទិសឱ្យគេ ពួកគេនឹងបានទទួលឬ ? ព្រះមានព្រះភាគ
ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ។ នៅពេលនោះព្រះបាទពិម្ពិសារ
ក៏ក្រាបទូលនិមន្តព្រះមានព្រះភាគ ដើម្បីទទួលភត្តាហារថ្ងៃស្អែក
ក្នុងរាជនិវេសន៍ ។ ដល់ថ្ងៃស្អែកឡើង ព្រះមានព្រះភាគជាម្ចាស់ ក៏
ស្តេចយាងទៅទទួលទានក្នុងរាជនិវេសន៍ ពេលនោះពពួកប្រេតទាំង

នោះនាំគ្នាទៅឈរត្រង់ខាងក្រៅជញ្ជាំងផ្ទះជាដើម ដោយសង្ឃឹមថា ថ្ងៃនេះពួកយើងនឹងបានអ្វីខ្លះ ។ ព្រះមានព្រះភាគទ្រង់បានធ្វើរូបប្រេតនោះឱ្យព្រះរាជាបានឃើញច្បាស់ ។

ព្រះបាទពិម្ពិសារទ្រង់ថ្វាយទឹកទក្ខិណោទក (ឱ្យទឹកជាទាន) ទ្រង់ឧទ្ទិសថា **ឥទំ ញាតីនំ ហោន្តុ** សូមទាននេះចូរមានដល់ញាតិរបស់យើង ។ ពេលនោះឯង ស្រះបោក្ខរណីមិដៅដាសដោយផ្កាឈូកក៏កើតដល់ប្រេតទាំងនោះ ពួកប្រេតទាំងនោះក៏ងូតទឹកស្រះនោះ បំបាត់នូវសេចក្តីក្រវល់ក្រវាយ សេចក្តីលំបាក សេចក្តីស្រេកហើយ ក៏មានពណ៌សម្បុរដូចមាស ។ លំដាប់នោះ ព្រះរាជាទ្រង់ថ្វាយយាគូ និងខាទនីយភោជនីយាហារ ហើយឧទ្ទិសឱ្យ ពេលនោះអាហារជាទិព្វបានកើតឡើងដល់ប្រេតទាំងនោះ ។ ពួកប្រេតនោះ ក៏នាំគ្នាបរិភោគរបស់ទិព្វនោះ ក៏មានឥន្ទ្រិយ៍ស្រស់ថ្លាពេញលេញ ។

លំដាប់នោះ ព្រះរាជាទ្រង់ថ្វាយសំពត់និងសេនាសនៈជាដើម

ហើយទ្រង់ឧទ្ទិសឱ្យ ពេលនោះគ្រឿងអលង្ការផ្សេងៗ មានសំពត់ទិព្វ យានជំនិះទិព្វ ប្រាសាទទិព្វ គ្រឿងអលង្ការទិព្វជាដើម ក៏កើតដល់ប្រេតទាំងនោះ ។

សម្បត្តិគ្រប់យ៉ាងដែលពួកប្រេតនោះបានទទួល ព្រះមានព្រះភាគទ្រង់អធិដ្ឋានឱ្យព្រះរាជាទ្រង់បានឃើញ ។ ព្រះរាជាមានព្រះទ័យរីករាយក្រៃលែង ព្រោះទ្រង់បានឃើញសភាពនេះផ្ទាល់ ។

កាលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សោយស្រេចហើយ ក៏ទ្រង់ធ្វើភត្តានុមោទនា គឺសម្តែងធម៌ទេសនាប្រារព្ធបុណ្យទក្ខិណានុប្បទានរបស់ព្រះបាទពិម្ពិសារ ដោយតិរោកុឌ្ឌសូត្រ ។ ព្រះសូត្រនេះ ព្រះសង្ឃតែងនិយមសូត្រនៅពេលមុនឆាន់ ។

(ចប់ប្រវត្តិប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារ)



តិរោកុឌ្ឌសូត្រ

ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងថា :- ប្រេតទាំងឡាយមកកាន់ផ្ទះនៃញាតិ ដោយគិតថា ជាផ្ទះរបស់ខ្លួន ហើយឈរនៅជិតទាំងក្រៅជញ្ជាំងផ្ទះទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុងនឹងទ្វារផ្ទះ ទាំងឡាយខ្លះ ។

កាលបើបាយទឹក បង្អែមនិងចង្ហាបមានគ្រប់គ្រាន់ ដែលពួកញាតិតាក់តែងទុកហើយ មិនមានញាតិណាមួយនឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ ។

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹកនិងភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយយ៉ាងនេះថា :- ទានេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយបានដល់នូវសេចក្តីសុខចុះ ។

ចំណែកប្រេតជាញាតទាំងនោះ ជាអ្នកមកប្រជុំគ្នា មកជួបជុំគ្នាហើយក្នុងមន្ទីរឱ្យទានេះ កាលបើបាយនឹង ទឹកមានល្មម

ត្រប់ត្រាន់ ក៏អនុមោទាដោយគោរពថា :- យើងទាំងឡាយបាន
សម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមពួកញាតិទាំង
ឡាយរបស់យើងទាំងឡាយនោះ រស់នៅយឺនយូរ ការបូជាដែល
ញាតិទាំងឡាយធ្វើហើយដល់យើងទាំងឡាយក្តី ញាតិទាំងឡាយ
ជាអ្នកឱ្យ ទានក្តី មិនមែនជាអ្នកឥតផលឡើយ ។

កសិកម្មក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្មក៏មិន
មានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិ
ដូច្នោះ ក៏មិនមាន ការលក់ទិញផ្លាស់ប្តូរដោយប្រាក់ក៏មិនមានបុគ្គល
ទាំងឡាយធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញ៉ាំងទុវ
អត្ថភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទាន ដែល
ញាតិឱ្យហើយអំពីលោកនេះ ។

ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទំនាបដូចម្តេច
មិញ ទានដែលបុគ្គលឱ្យហើយ អំពីលោកនេះ រមែងសម្រេចផល
ដល់ប្រេតទាំងឡាយ ដូច្នោះដែរ ។

ផ្ទូវទឹកមានទន្លេនិងស្ទឹងជាដើម ដ៏ពេញ រមែងញ៉ាំងសាគរឱ្យ ពេញប្រៀបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

បុគ្គលកាលរលឹកឃើញនូវឧបការគុណ ដែលលោកធ្វើទុក ដល់ខ្លួន ក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះ បានធ្វើគុណនេះដល់អញ ជនទាំងអស់នោះ ជាញាតិមិត្ត ជាសម្ឆាញ់ របស់អញដូច្នេះហើយ ត្រូវឱ្យទក្ខិណាទាន ចំពោះប្រេតទាំងឡាយ ។

ការយំសោកសៅនិងការខ្សឹកខ្សួលដទៃណា មិនមាន ប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ដល់ ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះ ដដែល គឺឥតបានដឹងបានឲ្យឡើយ ។

លុះតែទក្ខិណាទាននេះ ដែលបុគ្គលឱ្យហើយ តម្កល់ទុក ប្រពៃហើយក្នុងសង្ឆ ទើបសម្រេចផលដោយរួសរាន់ ដើម្បី ប្រយោជន៍ដល់ប្រេតនោះ អស់កាលជាយូរអង្វែង ។

ញាតិធម៌នោះឈ្មោះថា មហាបពិត្របានសម្តែងជាំបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្នូរចំពោះប្រែតទាំងឡាយ ឈ្មោះថា បានធ្វើហើយផង កំលាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា បានបំពេញឱ្យហើយផង បុណ្យឈ្មោះថា បានសន្សំទុកមិនមែនតិចឡើយផង ។

(ចប់តិរោកុឌ្ឌសូត្រ)



សេចក្តីពន្យល់ក្នុងតិរោកុឌ្ឌសូត្រ

ព្រះអរហន្តជាសាវកទាំងឡាយ ជាអ្នកដឹងច្បាស់នូវគុណព្រះពុទ្ធ បានអធិប្បាយពន្យល់នូវសេចក្តីដែលកំបាំងជ្រៅរបស់តិរោកុឌ្ឌសូត្រនេះ ក្នុងអដ្ឋកថាឈ្មោះ បរមត្ថជោតិកានៃគម្ពីរខុទ្ទកនិកាយ ខុទ្ទកបាឋ តែមិនបាននាំយកសេចក្តីពន្យល់ក្នុងអដ្ឋកថានោះមកសម្តែងទុកក្នុងទីនេះទេ សូមនាំយកសេចក្តីពន្យល់ក្នុងគម្ពីរមង្គលទីបនី មកសម្តែងវិញ ព្រោះមានសេចក្តីងាយយល់ជាង ។

សេចក្តីពន្យល់ក្នុងមង្គលទីបនី

ក៏ព្រះដ៏មានព្រះភាគ កាលទ្រង់សម្តែងនូវភាពនៃប្រេតទាំងឡាយ ដែលមកហើយឈរក្នុងទីនោះ។ ដល់ព្រះរាជា ទើបទ្រង់ត្រាស់ព្រះគាថាជាបឋមថា :-

តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិង្ឃាដកេសុ ច

ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ

ប្រេតទាំងឡាយ មកកាន់ផ្ទះនៃញាតិ ដោយគិតថា ផ្ទះរបស់

ខ្លួន ហើយឈរនៅជិតខាងក្រៅជញ្ជាំងផ្ទះទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយខ្លះ ។

បណ្តាបទទាំងឡាយនោះ បទថា **តិរោកុឌ្ឌេសុ** មានសេចក្តីថា ប្រែតទាំងឡាយនោះ ស្ថិតនៅតឹសម្រេចការឈរនៅ ក្នុងទីខាងក្រៅទាំងឡាយ ដែលជាចំណែកខាងក្រៅនៃកំផែង និងជញ្ជាំងផ្ទះ ។

ក្នុងបទថា **សន្ធិសិង្ឃាដកេសុ** នេះ គប្បីវិនិច្ឆ័យដូចតទៅ : ច្រកផ្លូវមានមុម ៤ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **សន្ធិ** (ទីត) ឬសូម្បីទីតនៃផ្ទះ ទីតនៃជញ្ជាំង ទីតនៃបង្ខូច ព្រះដ៏មានព្រះភាគក៏ទ្រង់ត្រាស់ថាសន្ធិដែរ ។ ច្រកផ្លូវមានមុម ៣ ហៅថា **សិង្ឃាដកៈ** បាទគាថា **ទ្វារពាហាសុ តិដ្ឋន្តិ** មានសេចក្តីថា ឈរផ្អែកពាហានៃទ្វារក្រុងនិងទ្វារផ្ទះទាំងឡាយ ។ ផ្ទះនៃញាតិក្នុងកាលមុនក្តី ផ្ទះដែលខ្លួនធ្លាប់នៅអាស្រ័យមកហើយ ដោយភាពនៃខ្លួនជាម្ចាស់ក្តី ផ្ទះទាំង ២ ប្រភេទនេះក្តី ឈ្មោះថា ផ្ទះរបស់ខ្លួន ក្នុងពីរបទនេះថា

"សកំ ឃរំ" ។ ព្រះមានព្រះភាគទើបទ្រង់ត្រាស់យ៉ាងនេះ ព្រោះប្រេតទាំងឡាយនោះមកដោយសម្គាល់ថា ជាផ្ទះរបស់ខ្លួន ។

ឥឡូវនេះ ព្រះសាស្តា កាលទ្រង់សម្តែងភាវៈនៃញាតិណាមួយ កាលបើបាយទឹកជាដើម សូម្បីមានច្រើន មិនមានសូម្បីគ្រាន់តែសេចក្តីនឹករលឹក ដល់ប្រេតទាំងឡាយនោះ។ ដែលដើរប្រាថ្នាចំពោះពួកញាតិទាំងឡាយថា "ញាតិទាំងឡាយ គប្បីឱ្យអាហារវត្ថុណាមួយ ឧទ្ទិសឱ្យពួកយើងទាំងឡាយខ្លះ" ដូច្នេះ ព្រោះបច្ច័យនៃកម្ម ដែលមានផលក្តៅក្រហាយដ៏ក្រៃលែង ដែលប្រេតទាំងឡាយនោះ បានធ្វើហើយ ទើបទ្រង់ត្រាស់គាថាទី ២ ថា :-

បហូតេ អន្នបានម្ហិ ខជ្ជភោជ្ជេ ឧបដ្ឋិតេ ន
តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា

"កាលបើបាយទឹក បង្អែមនឹងចម្ហាបច្រើន ដែលពួកញាតិចាត់ចែងទុករួចហើយ មិនមានញាតិណាមួយ នឹករលឹកទៅដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយ ជាបច្ច័យ" ។

បណ្តាបទទាំងនោះ បទថា "**បហូតេ**" បានដល់ មិនតិច គឺច្រើន ។ ព្រោះលោកផ្ទាស់ ៣ អក្សរ ឱ្យទៅជា ប អក្សរ ។ បទថា "**អន្នបានម្ហិ**" បានដល់ កាលបើគ្រឿងស៊ី និងគ្រឿងផឹក ។ បទថា "**ខជ្ជភោជ្ជេ**" បានដល់ កាលបើគ្រឿងទំពាស៊ី និងគ្រឿងស្រស់ស្រូប ។ បទថា "**ឧបដ្ឋិតេ**" គឺពួកញាតិចូលទៅតម្កល់ទុកហើយ គឺចាត់ចែងទុកហើយ បានដល់តាក់តែងទុកហើយ ។ បទថា "**កោចិ**" មានសេចក្តីថា មាតាក្តី បិតាក្តី មិនរលឹកឃើញដល់សត្វទាំងឡាយដែលទៅកើតក្នុងបេតវិស័យនោះ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះកម្មជាបច្ច័យ គឺព្រោះកម្មគឺសេចក្តីកំណាញ់ផ្សេងដោយការហាមឃាត់ នូវបាយនិងទឹកជាដើម ដែលខ្លួនធ្វើហើយជាហេតុ ។ មែនពិត កម្មនោះ របស់សត្វទាំងឡាយនោះ តែងមិនឱ្យញាតិទាំងឡាយនឹករលឹកឃើញដូច្នេះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សរសើរនូវទានដែលព្រះរាជាទ្រង់ថ្វាយឧទ្ទិសឱ្យញាតិទាំងឡាយ ដែលស្លាប់ទៅ

ហើយ ទើបទ្រង់ត្រាស់ព្រះគាថា ទី ៣ ថា :-

ឯតំ ញាតីនំ យេ ហោន្តិ អនុកម្បកា សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ

ញាតិទាំងឡាយណា ជាអ្នកអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ ក៏យ៉ាងនោះដែរ ។

បណ្តាបទទាំងនោះ បទថាឯតំ បានសេចក្តីថា ថ្វាយព្រះពរមហារាជ ជនទាំងឡាយណា ជាអ្នកអនុគ្រោះ ជនទាំងនោះ រមែងឧទ្ទិសនូវទឹកនិងភោជន ដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាល ដល់ញាតិទាំងឡាយ ដូចជាព្រះមហាបពិត្រថ្វាយទាន ដូច្នោះដែរ ។

បទថា **ឯតន្តិ** មានសេចក្តីថា ញាតិទាំងឡាយ មានបុត្រជាដើមនោះ តែងឱ្យ គឺ ឧទ្ទិសប្រគល់ឱ្យថា "សូមទាននេះមានដល់ញាតិទាំងឡាយ របស់ពួកយើង" ។ បទថា "**ញាតីនំ**" គឺ ដល់ពួកញាតិ ដែលកើតក្នុងប្រេតវិស័យ ។ បទថា "**យេ**" គឺ ជនទាំង

ឡាយណាមួយ គឺបុត្រធីតា និងបងប្អូនប្រុស-ស្រី ។ បទថា "**អនុកម្បកា**" បានដល់អ្នកដែលប្រាថ្នានូវប្រយោជន៍ គឺ អ្នកដែលស្វែងរកនូវប្រយោជន៍ ។ បទថា "**សុចី**" បានដល់ ដ៏បរិសុទ្ធ គឺ សមគួរដល់ចិត្ត ប្រកបដោយធម៌ បានមកដោយធម៌ ។ បទថា "**បណីតំ**" បានដល់ ដ៏ខ្ពង់ខ្ពស់ គឺ ដ៏ប្រសើរ ។ បទថា "**ការេន**" បានដល់ ក្នុងកាលដែលប្រេតទាំងឡាយ មកឈរនៅ ក្នុងទីទាំងឡាយ មានទីជិតខាងក្រៅជញ្ជាំងជាដើមខ្លះ ក្នុងកាលដែលគួរបរិភោគ នៃទក្ខិណេយ្យបុគ្គលទាំងឡាយខ្លះ ។ បទថា "**កប្បិយំ**" បានដល់ ដ៏សមគួរ គឺ ដ៏គួរ គួរសម ដល់ការបរិភោគ នៃព្រះអរិយទាំងឡាយ ។ បទថា "**បានភោជនំ**" បានដល់ ទឹក និង ភោជន។ ក្នុងព្រះគាថាទី៣ នេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នូវទេយ្យធម៌ គ្រប់បែបយ៉ាង ដោយលើកយកនូវទឹកនិងភោជន ជាប្រធាន ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវទាន ដែលព្រះរាជាគប្បីឧទ្ទិសឱ្យដល់ប្រេតទាំងឡាយនោះ ទើបទ្រង់ត្រាស់

កន្លះគាថាខាងដើម នៃព្រះគាថាទី ៤ ថា :-

ឥទំ ខោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ

"ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមឱ្យញាតិទាំងឡាយបាននូវសេចក្តីសុខ" ។

បណ្តាបទទាំងនោះ បទថា "**ឥទំ**" ជាពាក្យសម្តែងប្រាប់នូវទេយ្យធម៌ ។ ពាក្យថា "**ខោ**" គ្រាន់តែជានិបាត ។ អាចារ្យពួកខ្លះពោលថា "**នោ**" ដូច្នេះ ក៏មាន ។ អធិប្បាយថា របស់ពួកយើងទាំងឡាយ ។ បទថា "**ញាតីនំ**" មានសេចក្តីថា ចូរមានដល់ញាតិទាំងឡាយ ដែលទៅកើតក្នុងប្រេតវិស័យ ។ បាទគាថា "**សុខិតា ហោន្តុ ញាតយោ**" មានសេចក្តីថា សូមញាតិទាំងឡាយ ដែលទៅកើតក្នុងប្រេតវិស័យនោះ ចូរសោយនូវទាននេះ បានដល់នូវសេចក្តីសុខចុះ ។

ឥឡូវនេះ កាលបើទាយក ពោលថា "សូមឱ្យទាននេះ មាន

ដល់ញាតិទាំងឡាយរបស់ពួកយើង" ដូច្នេះ កម្មដែលបុគ្គលដទៃធ្វើ ហើយ រមែងហុចផលឱ្យដល់បុគ្គលដទៃ ក៏មិនមែន ប៉ុន្តែថា វត្ថុដែលទាយកឧទ្ទិសឱ្យ យ៉ាងដូច្នោះ រមែងជាបច្ច័យដល់កុសលកម្ម របស់ប្រេតទាំងឡាយនោះប៉ុណ្ណោះ ។ ព្រោះហេតុនោះ កាលបើវត្ថុនោះឯង គឺទាយកឧទ្ទិសឱ្យ ហើយ ដល់ប្រេតទាំងឡាយនោះ កុសលកម្ម នឹងញុំាងផលឱ្យកើត ក្នុងខណៈនោះ ដោយប្រការណា ព្រះ ឥសិ កាលទ្រង់សំដែងនូវ ប្រការនោះ ទើបទ្រង់ត្រាស់កន្លះគាថាខាងចុង នៃព្រះគាថាទី ៤ នឹងកន្លះគាថាខាងដើម ព្រៃះគាថាទី ៥ ថា :-

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា
បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ

"ចំណែក ប្រេតជាញាតិ ជាអ្នកមកប្រជុំគ្នាទាំងនោះ មកប្រជុំគ្នាហើយ ក្នុងមន្ទីរឱ្យទាននោះ កាលបើបាយនិងទឹក មានច្រើន ក៏អនុមោទនា ដោយគោរព" ។

បណ្តាបទទាំងនោះ ២ បទ ថា "ឥត ញាតិឡេតា" សម្ពន្ធ
នឹងគ្នា ។ បទថា "តត្ត" បានដល់ក្នុងមន្ទីរដែលគេឱ្យទាននោះ ។
បទថា "សមាគន្ត្វា" មានេសេចក្តីថា មកហើយដោយជុំវិញ គឺ
ប្រជុំគ្នា បានដល់ ជាមួយនឹងគ្នា ។ បទថា "សមាគតា" មាន
សេចក្តីថា ជាអ្នកមកព្រមគ្នាហើយ ដើម្បីប្រយោជន៍នេះ ថា "ញាតិ
ទាំងឡាយ របស់ពួកយើងទាំងនេះនឹងឧទ្ទិសទាន ដើម្បីប្រយោជន៍
ដល់ពួកយើង" ។ បទថា "អន្ថបានម្ហិ" មានសេចក្តីថា កាលបើ
បាយទឹក ដែលញាតិទាំងឡាយឧទ្ទិសឱ្យ ដល់ខ្លួននោះ មានច្រើន ។
បាទគាថា ថា "សក្កច្ចំ អនុមោឧរេ" មានសេចក្តីថា ញាតិទាំង
ឡាយ ដែលលះបង់លោកនេះទៅហើយ ជ្បឹច្បាស់នូវកម្មនិងផល
មិនលះបង់នូវសេចក្តីកោតក្រែង និងជាអ្នកមានចិត្តមិនរាយមាយ
រមែងរីករាយ គឺ តែងអនុមោទនា បានដល់ ជាអ្នកកើតបីតិ និង
សោមនស្ស ថា **"សូមទាននេះ កើតមានដើម្បីជាប្រយោជន៍ ដើម្បី
សេចក្តីសុខដល់ពួកយើង"** ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវអាការៈនៃសេចក្តីសសើរ (ឱ្យពរសព្វសាធុការ) ចំពោះញាតិ របស់ពួកប្រេតទាំងនោះ ដែលបានសោយនូវផលនៃកម្ម ដែលអាស្រ័យញាតិទាំងឡាយ ទើបត្រាស់កន្លះគាថាខាងចុង នៃគាថា ទី៥ និងកន្លះគាថាខាងដើម នៃគាថា ទី៦ ថា :-

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ
អម្ហាកញ្ច កតា បូជា ទាយកា ច អនិប្ផលា

"យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា សូមញាតិរបស់យើងទាំងឡាយនោះរស់នៅយឺនយូរ ការបូជា គឺញាតិទាំងឡាយធ្វើហើយ ដល់យើងទាំងឡាយក្តី ទាយក គឺអ្នកឱ្យទានក្តី ក៏មិនមែនឥតផលឡើយ" ។

បណ្តាបទទាំងនោះ ២ បទ ថា "**ចិរំ ជីវន្តុ**" មានសេចក្តីថា ជាអ្នករស់នៅយឺនយូរ គឺ ចូរជាអ្នកមានអាយុវែង ។ ២ បទ ថា "**នោ ញាតី**" ប្រែថា ពួកញាតិរបស់យើង ។ បទថា "**ហេតុ**"

បានដល់ ព្រោះហេតុនៃញាតិទាំងឡាយ គឺ ព្រោះអាស្រ័យញាតិទាំងឡាយណា ។ បទថា "**លភាមសេ**" មានសេចក្តីថា ពួកយើងបានសម្បត្តិប្រាកដដូច្នេះ ។

ក៏ប្រេតទាំងឡាយនោះ កាលអាងនូវសម្បត្តិ ដែលខ្លួនបានហើយ ក្នុងខណៈនោះ ទើបពោលយ៉ាងនេះ ដោយអំណាចនៃការសសើរ (ឱ្យពរសព្ទសាធុការ) ។ មែនពិត ទក្ខិណាទាន (ទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយឱ្យ) ជាទានអាចញុំាងផលឱ្យកើតក្នុងខណៈនោះឯង ដល់ប្រេតទាំងឡាយនោះ ក៏ព្រោះអង្គ ៣ យ៉ាង គឺ ព្រោះការអនុមោទនា របស់ប្រេត ១ ព្រោះការឧទ្ទិស នៃទាយកទាំងឡាយ ១ ព្រោះការដល់ព្រមដោយព្រះទក្ខិណេយ្យបុគ្គល ១ ។ បណ្តាហេតុ ៣ យ៉ាងនោះ ទាយកជាហេតុវិសេស ។ ព្រោះហេតុនោះ ប្រេតទាំងនោះ ទើបពោលថា "**ពួកយើងបានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយណា.....**" ដូច្នេះជាដើម ។

បាទគាថា ថា "**អម្ហាកញ្ច ករា បូជា**" មានសេចក្តីថា ការបូជា តី ទាយកទាំងឡាយ កាលឧទ្ទិសនូវទានេះ យ៉ាងនេះថា "**សូមទាននេះ សម្រេចដល់ញាតិទាំងឡាយ របស់ពួកយើង**" ដូច្នេះ ឈ្មោះថា បានធ្វើហើយ ដល់យើងទាំងឡាយ ។ ឯទាយកទាំងឡាយនោះ ក៏ឈ្មោះថា ជាអ្នកមិនឥតប្រយោជន៍ ព្រោះកម្មរមែងឱ្យផលក្នុងសន្តាន ជាទីកើតនៃកម្ម ដែលសម្រេចដោយការបរិច្ចាគ

ឥឡូវនេះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងនូវការមិនមានហេតុដែលនាំឱ្យបាននូវសម្បត្តិ មានកសិកម្ម និងគោរក្ខកម្ម ជាដើម ដទៃទៀតក្នុងប្រេតវិស័យនោះ និងភាពគឺការញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយទានដែលទាយកឱ្យហើយ អំពីមនុស្សលោកនេះ របស់សត្វទាំងឡាយ ដែលកើតក្នុងប្រេតវិស័យ ទើបត្រាស់គាថាទី ៧ ព្រមដោយកន្លះគាថាខាងចុងនៃគាថា ទី ៦ ថា :-

ន ហិ តត្ថ កសី អត្ថិ គោរក្ខេ ន វិជ្ជតិ
វណិជ្ជា តាទិសី នត្ថិ ហិរញ្ញេន កយាកយំ ឥតោ ទិន្នេន

យាវបេត្តិ បេតា ភាលភតា តហិ

"កសិកម្ម ក៏មិនមានក្នុងភូមិនៃប្រេតនោះ គោរក្ខកម្ម ក៏មិនមានក្នុងភូមិនៃប្រេតនោះ ពាណិជ្ជកម្មដែលជាហេតុបានសម្បត្តិដូច្នោះ ក៏មិនមាន ការលក់ចិញ្ចៀសប្តូរ ដោយប្រាក់ ក៏មិនមានបុគ្គលទាំងឡាយ ធ្វើកាលកិរិយាលះលោកនេះទៅហើយ រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលពួកញាតិឧទ្ទិសឱ្យហើយ អំពីលោកនេះ" ។ បណ្តាបទទាំងនោះ បទថា "ន ហិ តត្ថ" មានសេចក្តីថា បពិត្រមហារាជ ក៏ប្រេតវិស័យនោះ កសិកម្ម មិនមានទេ ។ ពាក្យថា "**គោរក្ខេត្ថ**" មានសេចក្តីថា ក្នុងប្រេតវិស័យនោះ សូម្បីការរក្សា គោ ពោលគឺកម្មគ្រឿងចិញ្ចឹមជីវិត ដោយការរក្សាគោទាំងឡាយ ហើយ លក់បញ្ចូគោរស ក៏មិនមាន ។ អធិប្បាយថា ប្រេតទាំង ឡាយ អាស្រ័យនូវកសិកម្ម និងគោរក្ខកម្មនោះ ក៏មិនមានដែរ ។ បទថា "តាទិសី" មានសេចក្តីថា ប្រេតទាំងនោះ អាស្រ័យនូវ

ពាណិជ្ជកម្មបែបណា តប្បីបានសម្បត្តិ សូម្បីពាណិជ្ជកម្មបែបនោះ ក៏មិនមានដែរ ។ បទថា "**កយាកយំ**" មានសេចក្តីថា ប្រេតទាំងនោះ អាស្រ័យការលក់ទិញផ្លាស់ប្តូរឯណា តប្បីបាននូវសម្បត្តិ សូម្បីការលក់ទិញផ្លាស់ប្តូរ ដោយប្រាក់ គឺដោយកហាបណៈ បែបនោះ ក៏មិនមានដែរ ។ បទថា "**យាវបេន្តិ**" មានសេចក្តីថា រមែងញុំងអត្តភាពឱ្យរស់នៅ គឺឱ្យប្រព្រឹត្តទៅ ដោយផលទានដែលញាតិទាំងឡាយ ឬ មិត្រនិងអាមាត្យទាំងឡាយ ឱ្យហើយអំពីមនុស្សលោកនេះ ។ បទថា "**បេតា**" បានដល់ សត្វទាំងឡាយដែលទៅកើតក្នុងប្រេតវិស័យ ។ បទថា "**កាលគតា**" បានដល់ អ្នកទៅហើយ ដោយមរណកាលរបស់ខ្លួន ។ បាលីថា **កាលកតា** ដូច្នេះក៏មាន ។ អធិប្បាយថា ធ្វើកាលកិរិយា គឺធ្វើមរណកាលទៅហើយ។ បទថា "**តហិ**" បានដល់ក្នុងប្រេតវិស័យនោះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រកាសនូវសេចក្តីដែលព្រះអង្គទ្រង់ត្រាស់ហើយ ដោយឧបមា ២ យ៉ាង ទើបទ្រង់

ត្រាស់ ២ ព្រះគាថា ថា :-

ឧន្នតេ ឧទកំ តុដ្ឋិ យថា ឯកំ បវត្តតិ ឯវមេវ ឥតោ ឧទ្ធំ បេតានំ ឧបកប្បតិ ។ យថា នទិយោ បូរា បរិបូរេន្តិ សាគរំ ឯវមេវ ឥតោ ឯកំ បេតានំ ឧបកប្បតិ ។

"ទឹកធ្លាក់ចុះ លើទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេច មិញ ទានដែលបុគ្គលឱ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នេះដែរ ។ ឯទឹកមានទន្លេ និងស្ទឹងជាដើម ដងពេញ រមែងញុំាងសាគរឱ្យពេញប្រៀប ដូចម្តេចមិញ ទានដែល បុគ្គលឱ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយ ដូច្នោះដែរ" ។

បណ្តាបទពួកនោះ បទថា "**ឧន្នតេ**" បានដល់ លើទីទួល គឺលើភូមិភាគដែលខ្ពស់ ។ បទថា "**តុដ្ឋិ**" បានដល់ទឹកដែលភ្លៀងទាំងឡាយបង្អុរចុះហើយ ។ ២ បទថា "**ឯកំ បវត្តតិ**" មាន

សេចក្តីថា រមែងហូរទៅ គឺរមែងហូរធ្លាក់ចុះទៅកាន់ភូមិភាគដែលទំនាប ។ បទថា "**ឧបកប្បតិ**" បានដល់ រមែងកើត គឺរមែងប្រាកដ បានដល់មិនប្រាសចាក អំពីការកើតផល ។ ព្រោះថា បេតលោក ជាទីតាំងនៃការសម្រេចនៃទាន ប្រៀបដូចជា ទីទំនាប ជាទីតាំងនៃ ការហូរធ្លាក់ចុះទៅនៃទឹក ដូច្នេះឯង ។ ព្រោះហេតុនោះ ព្រះដ៏មាន ព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេច ផលដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងហៅថា ទីដ៏សមគួរ" ។ ស្ថឹងធំ ហៅថា ផ្លូវទឹក ។ បទថា "**បូរ**" បានដល់ ពេញដោយទឹក ដែលហូរមកអំពីជ្រោះ ភ្នំ ជ្រលង ព្រែក អូរ ប្រឡាយ បឹង ហើយ ញ៉ាំងសាគរឱ្យពេញ ។

ប្រេតទាំងឡាយ ត្រូវសេចក្តីសង្ឃឹមគ្របសង្កត់ហើយថា "ពួកយើង នឹងបានវត្ថុអ្វីមួយ អំពីផ្ទះនេះ" ដូច្នេះហើយ សូម្បីមកកាន់ផ្ទះនៃពួកញាតិហើយ ក៏មិនអាចដើម្បីនឹងសូមថា "សូមអ្នកទាំងឡាយ ឱ្យនូវវត្ថុនេះ ដល់យើងទាំងឡាយ" ដូច្នេះបានឡើយ

ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សំដែងថា "កុលបុត្រ កាលនឹករលឹកដល់វត្ថុជាគ្រឿងនឹករលឹកទាំងឡាយនេះ គប្បីឱ្យទក្ខិណាទានដើម្បីប្រេតទាំងឡាយនោះ" ដូច្នេះ ទើបទ្រង់ត្រាស់ព្រះគាថាទី១០ ថា :-

អដាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្ពេ កតមនុស្សរំ

"បុគ្គល កាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា "អ្នកនេះ បានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយ ជាញាតិមិត្រនិងជាសម្លាញ់របស់អញ" ដូច្នេះហើយគួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ"។

បណ្តាបទនោះ ២ បទថា "**ទក្ខិណំ ទជ្ជា**" មានសេចក្តីថា កុលបុត្រ កាលនឹករលឹក គឺកាលតាមរឭកនូវឧបការគុណដែលលោកធ្វើហើយក្នុងកាលមុនគ្រប់យ៉ាង យ៉ាងនេះថា "អ្នកនោះ បានឱ្យទ្រព្យ ឬស្រូវឈ្នោះនេះដល់អញ" ថា "អ្នកនោះបានធ្វើកិច្ចការ

ឈ្មោះនេះដល់អញ" ថា "អ្នកឯណោះ ឈ្មោះថាជាញាតិរបស់អញ ព្រោះជាអ្នកទាក់ទងគ្នាខាងមាតា ឬខាងបិតា" ថា "អ្នកឯណោះ ឈ្មោះថាជាមិត្រ ព្រោះជាអ្នកអាចជួយការពារដោយអំណាចនៃសេចក្តីស្រឡាញ់" ដូច្នេះ និង ថា "បុគ្គលឯណោះ ជាសម្លាញ់ដែលលេងដីជាមួយនឹងគ្នា" ដូច្នេះ គប្បីឱ្យ គឺ គប្បីប្រគល់ឱ្យនូវទាន ចំពោះប្រេតទាំងឡាយ ។ បាលីថា "**ឧទ្ទិស្ស ទជ្ជា**" ដូច្នេះខ្លះក៏មាន ។ ក្នុងបទថា "**ទជ្ជា**" នោះ គប្បីជ្រាបវិគ្រោះដូចតទៅ :- សម្បត្តិណា ដែលបុគ្គលគប្បីឱ្យ ហេតុនោះ សម្បត្តិនោះ ឈ្មោះថា **ទជ្ជា** ប្រែថា សម្បត្តិដែលបុគ្គលគប្បីឱ្យ ។ សម្បត្តិដែលបុគ្គលគប្បីឱ្យនោះ គឺជាអ្វី ? ។ គឺ ទក្ខិណា ដើម្បីប្រេតទាំងឡាយ ។ ទក្ខិណានោះ អ្នកណាគប្បីឱ្យ ? ។ គឺ កុលបុត្រ អ្នកដែលនឹករលឹក អធិប្បាយថា អ្នកដែលតាមរលឹក នូវឧបការគុណដែលលោកធ្វើហើយ ក្នុងកាលមុន ដោយន័យជាដើមថា "អ្នកនោះ បានឱ្យនូវរបស់នេះដល់អញ....." ដូច្នេះ ។ ក៏បទថា "**អនុស្សរំ**" នេះ ជា

បឋមាវិភត្តិ ចុះក្នុងអត្ថ នៃកិរិយាវិភត្តិ ដូច្នេះឯង ។

ព្រះសាស្តា កាលទ្រង់សម្តែងថា "ក៏ជនទាំងឡាយណា រវល់តែមានសេចក្តីទុក្ខ មានការយំសោក និងកាខ្សឹកខ្សួល ព្រោះញាតិស្លាប់ទៅជាដើម មិនបានឧទ្ទិសឱ្យនូវវត្ថុអ្វី។ ដើម្បីប្រយោជន៍ដល់ប្រេតទាំងនោះ ការយំនិងសេចក្តីសោកសៅជាដើមនោះ របស់ជនទាំងនោះ គ្រាន់តែជាអ្នកញ៉ាំងខ្លួនឱ្យក្តៅក្រហាយតែម៉្យាងប៉ុណ្ណោះឯង ការយំជាដើមនោះ មិនអាចញ៉ាំងប្រយោជន៍បន្តិចបន្តួចឱ្យសម្រេចដល់ប្រេតទាំងឡាយបានឡើយ" ដូច្នេះ ទើបត្រាស់គាថាទី ១១ ថា :-

ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា
ន តំ បេតានមត្ថាយ ឯវំ តិដ្ឋន្តិ ញាតយោ

"កាយំ ការសោកសៅ ការខ្សឹកខ្សួល ដរាបណា មិនមានប្រយោជន៍ឡើយ ការយំជាដើមនោះ មិនសម្រេចប្រយោជន៍ ដល់ប្រេតទាំងឡាយទេ ញាតិទាំងឡាយ រមែងឋិតនៅយ៉ាងនោះដែល

ឥតបានដឹងបានឮឡើយ ។

ក៏រីយាបង្ហូរចេញនូវទឹកភ្នែករបស់បុគ្គលអ្នកយំទាំងឡាយ ឈ្មោះថា ការយំ ក្នុងគាថានេះ ។ គប្បីសម្ពន្ធពាក្យដែលសេសសល់ ថា "**ន ហិ អាគតំ**" ។ ការសោយសោក គឺការក្តៅចិត្ត បានដល់ការក្រៀមក្រំ ពួដំខាងក្នុង ឈ្មោះថា ការសោកសៅ ។ ២ បទថា "**យា ឧញ្ញា**" គឺ អំពើដទៃឯណា ក្រៅអំពីការយំនិងការសោកសៅទាំងឡាយក្តី ។ ការខ្សឹកខ្សួល គឺ ការរើរាយដោយវាចា ដោយន័យថា "ឱបុត្រតូចតែមួយ អ្នកទៅក្នុងទីណា ?" ដូច្នេះ ជាដើម របស់បុគ្គលដែលត្រូវសេចក្តីវិនាសនៃញាតិពាល់ត្រូវហើយ ឈ្មោះថា ការខ្សឹកខ្សួល ។ អធិប្បាយថា សូម្បីការរើរាយដោយវាចានោះ នណាក៏មិនត្រូវធ្វើឡើយ ។ **ឥ** សព្ទ ក្នុងទីទាំងពួង ជាវិកប្បត្ថៈ ។ បាទគាថា ថា "**ន តំ បេតានមត្ថាយ**" មានសេចក្តីថា ការស្រែកយំជាដើមនោះ រមែងមិនប្រព្រឹត្តទៅដើម្បីឧបការៈដល់បុគ្គលទាំងឡាយ ដែលធ្វើកាលកិរិយាទៅហើយ

ព្រោះហេតុនោះ ការស្រែកយំជាដើមនោះ នរណា ក៏មិនគួរធ្វើឡើយ ។ មែនពិត ញាតិទាំងឡាយ រមែងស្ថិតនៅយ៉ាងដូច្នោះដដែល អធិប្បាយថា ឥតបានដឹងឡើយ ។

ព្រះមានព្រះភាគ លុះត្រាស់នូវភាវៈនៃការយំជាដើម ជាការឥតប្រយោជន៍ ដោយប្រការដូច្នេះហើយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងនូវទក្ខិណា ដែលព្រះរាជាទ្រង់ព្រះរាជទានហើយ មានប្រយោជន៍ ទើបទ្រង់ត្រាស់គាថាទី ១២ ថា :-

អយញ្ច នោ ទក្ខិណា ទិន្នា សទ្ធម្មិ សុបតិដ្ឋិតា
ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ

"លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឱ្យហើយ ឥម្ពល់ទុកប្រពៃហើយ ក្នុងព្រះសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះ អស់កាលជាអង្វែង" ។

ព្រះដ៏មានព្រះភាគ កាលនឹងទ្រង់សម្តែងនូវទានដែលព្រះរាជា ទ្រង់ព្រះរាជទានហើយ ក្នុងពេលនោះ ដោយច្បាស់លាស់

ទើបទ្រង់ត្រាស់ដោយពាក្យថា "អយំ" ក្នុងគាថានោះ។ ច សព្ទចុះក្នុងឥតិរេកាជាតកៈ។ ដោយ ច សព្ទនោះ ព្រះអង្គទ្រង់សម្តែងបំភ្លឺ នូវសេចក្តីប្លែកផ្សេងគ្នា ដែលនឹងទ្រង់ត្រាស់នុ៎ះឯង ថា "ការស្រែកយំជាដើម មិនមានប្រយោជន៍ បន្តិចបន្តួចដល់បុគ្គលដែលស្លាប់ទៅហើយឡើយ យ៉ាងណាមិញ ឯទក្ខិណាទាននេះ នឹងមិន មានប្រយោជន៍ដល់បុគ្គលដែលស្លាប់ទៅហើយ យ៉ាងដូច្នោះក៏ទេដែរ ទក្ខិណាទាន រមែងមានប្រយោជន៍ ដល់បុគ្គលដែលស្លាប់ទៅហើយនោះ អស់កាលជាយូរអង្វែង"។ សព្ទថា ខោ ចុះក្នុងវិធារណៈ។ ២ បទថា "ទក្ខិណា ទិន្នា" មានសេចក្តីថា បពិត្រមហារាជ ទានដែលព្រះអង្គទ្រង់ឧទ្ទិសឱ្យហើយដល់ពួកញាតិរបស់ព្រះអង្គ ក្នុងថ្ងៃនេះ។ ព្រះសង្ឃជាស្រែបុណ្យដ៏ខ្ពង់ខ្ពស់របស់សត្វលោក ព្រោះហេតុណា ព្រោះហេតុនោះ ទក្ខិណាទាន ឈ្មោះថា គឺព្រះអង្គ ទ្រង់ដម្កល់ទុកប្រពៃហើយ ក្នុងព្រះសង្ឃ។ ពាក្យថា "ហិតាយស្ស" គឺដើម្បីជាប្រយោជន៍ដល់ជននោះ

គឺជនដែលលះលោកនេះទៅហើយ អស់រាត្រីដ៏យូរ គឺអស់កាលជាយូរអង្វែង បាទគាថា ថា "**ឋានសោ ឧភយត្ថិ**" មានសេចក្តី ថា រមែងមាន គឺរមែងសម្រេច បានដល់រមែងឱ្យផលក្នុងខណៈនោះនុ៎ះឯង។ មានពាក្យអធិប្បាយថា "ដោយកាលមិនយឺតយូរ"។ ប្រៀបដូចជា ការព្យាករណ៍បញ្ហា រមែងជាក់ច្បាស់ក្នុងខណៈនោះនុ៎ះឯង ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ក៏ការព្យាករណ៍បញ្ហានោះ រមែងជាក់ច្បាស់ចំពោះតថាគតដោយរួសរាន់" ដូច្នេះ យ៉ាងណាមិញ សូម្បីក្នុងគាថានេះ ទក្ខិណាកាលសម្រេចផលក្នុងខណៈនោះនុ៎ះឯង ព្រះអង្គទ្រង់ត្រាស់ហើយថា "ទក្ខិណារមែងសម្រេចផលដោយរួសរាន់" ដូច្នេះ យ៉ាងនោះ ។ ម្យ៉ាងទៀត ឋានៈណាដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយថា "ម្នាលព្រាហ្មណ៍ ទាននោះ រមែងសម្រេចផលដល់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងជាទីដ៏គួរ" ដូច្នេះទក្ខិណាទានសម្រេចផលក្នុងទីនោះ ផ្សេងដោយឋានៈ មានខុប្បិបាសិកវន្តប្រេត បរទត្តបជីវីប្រេត និងនិជ្ឈាម

តណ្ហិកប្រែតជាដើម ព្រះអង្គទ្រង់ត្រាស់ថា "រមែងសម្រេចដោយឋានៈ" ដូច្នេះ ប្រៀបដូចជាបុគ្គលអ្នកឱ្យនូវកហាបណៈ គេហៅក្នុងលោកថា "បុគ្គលនោះ តែងឱ្យនូវកហាបណៈ" ដូច្នេះ យ៉ាងនោះឯង ។ ក៏ក្នុង អត្ថវិកប័្បនេះ បទថា "ឧបកប្បតិ" បានដល់ រមែងប្រាកដ មានពាក្យអធិប្បាយថា "រមែងកើតឡើង" ដូច្នេះ ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សរសើរព្រះរាជាដោយគុណតាមសេចក្តីពិត ទើបត្រាស់គាថាទីបញ្ចប់ថា :-

សោ ញាតិធម្មោ ច អយំ និទស្សិតោ បេតាន បូជា ច កតា ឧឡារា ពលញ្ច តិក្ខួនមនុប្បធិន្តំ តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ ។

"ញាតិធម៌នោះឈ្មោះថា មហាបពិត្របានសម្តែងជាបែបយ៉ាងហើយ ការបូជាដ៏ថ្លៃថ្លា ចំពោះប្រេតទាំងឡាយ ឈ្មោះថាព្រះអង្គបានធ្វើហើយ និងកម្លាំងកាយ នៃភិក្ខុទាំងឡាយ ឈ្មោះថាព្រះអង្គបានបំពេញឱ្យហើយ បុណ្យមិនមែនតិច ឈ្មោះថា ព្រះអង្គ

បានសន្សំទុកហើយ" ។

ការធ្វើកិច្ចដែលពួកញ្ញាតិគប្បីធ្វើ ដើម្បីញ្ញាតិទាំងឡាយ ឈ្មោះថា ញ្ញាតិធមិ ក្នុងគាថានោះ ។ បទថា "**និឧស្សិរតា**" មានសេចក្តីថា បពិត្រមហារាជ ញ្ញាតិធមិ គឺព្រះអង្គកាលថ្វាយនូវទក្ខិណានេះ ឈ្មោះថា ទ្រង់សម្តែងជាបែបយ៉ាងហើយ គឺ ទ្រង់ធ្វើជាបែបយ៉ាងហើយ បានដល់ ឱ្យប្រាកដ ដល់ជនច្រើន យ៉ាងនេះថា "ញ្ញាតិធមិ សូម្បីព្រះអង្គ គប្បីបំពេញដោយការធ្វើកិច្ចដែលញ្ញាតិទាំងឡាយគប្បីធ្វើដើម្បីពួកញ្ញាតិ យ៉ាងដូច្នោះឯង មិនគប្បីធ្វើខ្លួនឱ្យក្តៅក្រហាយដោយការយំជាដើមដែលមិនមានប្រយោជន៍ឡើយ" ។ បទថា "**ខុឡ្យាវា**" មានសេចក្តីថា ការបូជាដើម្បីប្រេតទាំងឡាយ បរិបូណិ គឺ សម្រេចហើយ បានដល់ គឺព្រះអង្គញ្ញុំងប្រេតទាំងឡាយ នោះឱ្យបាននូវទិព្វសម្បត្តិ ឈ្មោះថា ទ្រង់បានធ្វើហើយ ។ បទថា "**ពលំ**" មានសេចក្តីថា កម្លាំងកាយនៃភិក្ខុទាំងឡាយ គឺ ព្រះអង្គ ទ្រង់ញ្ញុំងសង្ឃ មានព្រះពុទ្ធជាប្រធាន ឱ្យឆ្អែតឆ្អន់ដោយអាហារ

មានបាយនិងទឹកជាដើម ឈ្មោះថា បានបំពេញឱ្យហើយ ។ បទថា "**បសុតំ**" មានសេចក្តីថា បុណ្យ គឺព្រះអង្គទ្រង់ញុំាងចេតនា ជាហេតុលះបង់មានគុណ មានការអនុគ្រោះជាដើម ជាបរិវារឱ្យកើតឡើង ឈ្មោះថា ទ្រង់បានសន្សំទុកហើយ ។

ព្រះសាស្តាទ្រង់បញ្ចប់ទេសនា ដោយគាថានេះ ។ កាលចប់ទេសនា សត្វ ៨ ម៉ឺន ៤ ពាន់ អ្នកកើតសេចក្តីសង្វេក ព្រោះការពណិនានូវទោស នៃការកើតក្នុងប្រេតវិស័យហើយ ប្រារព្ធសេចក្តីព្យាយាម ដោយយកចិត្តទុកដាក់ បានសម្រេចធម៌ហើយ ។

ព្រះសាស្តា ទ្រង់ត្រាស់ទេសនាតិរោកុឌ្ឍសូត្រនេះឯង ដល់ទេវតា និងមនុស្សទាំងឡាយ តាំងពីថ្ងៃទី ២ រហូតដល់ថ្ងៃទី ៧ ។ ការបានសម្រេចធម៌ បានមានហើយ យ៉ាងដូច្នេះដែរ ។ គាថាទាំង ១៣ គាថានេះ ព្រះធម្មសង្គាហកាចារ្យ ចងក្រងហើយក្នុងបេតវត្ថុ ដោយឈ្មោះថា "**តិរោកុឌ្ឍបេតវត្ថុ**" មានខុទ្ទកបាឋៈ ដោយឈ្មោះថា "**តិរោកុឌ្ឍសូត្រ**" ដោយប្រការដូច្នេះ ។

តិរោកុឌ្ឍសូត្រ ចប់ ។

ពុទ្ធភាសិតសរសើរអំពីបុញ្ញឫទ្ធិ (គឺបុណ្យមានឫទ្ធិដ៏ធំក្រៃលែង)

ឥធិកណ្ហសុត្រ

បុរសរមែងកប់កំណប់ទ្រព្យទុក ក្នុងទីដ៏ជ្រៅមានទឹកជាទីបំផុត ដោយគិតថា កាលកិច្ចគឺសេចក្តីត្រូវការកើតឡើងហើយទ្រព្យនេះ នឹងជាប្រយោជន៍ដល់អត្តាអញ ដើម្បីដោះខ្លួនអំពីរាជភ័យខ្លះ ដើម្បីដោះខ្លួនឱ្យរួចអំពីចោរភ័យខ្លះ ដើម្បីដោះបំណុលខ្លះក្នុងពេលទុរភិក្ខភ័យខ្លះ ក្នុងកាលមានអន្តរាយទាំងឡាយខ្លះ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍យ៉ាងនេះឯង ។ កំណប់ទ្រព្យទាំងអស់នោះ មិនមែនសម្រេចដល់បុគ្គលនោះសព្វកាលទេ ព្រោះថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្សនាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមិតដែលមិនជាទីស្រលាញ់ នាំយកនូវកំណប់ទ្រព្យនោះ ក្នុងកាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅក្នុងវេលាណា កំណប់ទ្រព្យទាំងអស់

នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។

កំណប់ទ្រព្យដែលស្ត្រីឬបុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតីយ៍ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬក្នុងមាតា ក្នុងបិតា ឬថាក្នុងបងប្រុស-ស្រី ជាច្បង កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណា មិនគប្បីបំផ្លាញបាន ជាកំណប់ទ្រព្យដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យ គឺបុណ្យនុ៎ះទៅ ។

កំណប់ទ្រព្យ គឺបុណ្យ មិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។ កំណប់គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរសន្សំនូវកំណប់ទ្រព្យ គឺបុណ្យនោះ ។

កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឱ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ

ប្រាថ្នានូវផលណា។ ផលទាំងពួងនោះ រមែងសម្រេចដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។

ភាពជាអ្នកមានសប្បុរផូរផង់ មានសម្ផេងពិរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតិ មានយសបរិវារ ផលទាំងអស់រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនុ៎ះ ។

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រលាញ់ ភាពជាស្តេចនៃទេវតា ក្នុទេពនិកាយទាំងឡាយ ផលទាំងអស់នោះ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនេះ ។

សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិគឺព្រះនិព្វានណាផង សម្បត្តិទាំងអស់នេះ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនេះ ។

ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាមដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជានិងវិមុត្ត ឥដ្ឋ

ផលទាំងអស់នេះ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនេះ ។

បដិសម្ភិទា វិមោក្ខ សាវកបារមីញ្ញាណ បច្ចេកសម្ពោធិញ្ញាណ និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់នេះ រមែងបានដោយកំណប់ទ្រព្យគឺបុណ្យនេះ ។

បុញ្ញសម្បទានេះ ឱ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ ។

ចប់និធិកណ្ឌសូត្រ ។

កំណប់ទ្រព្យរបស់បុរសស្ត្រីមាន៤យ៉ាង

១- **ឋាវរៈនិធិ** កំណប់ទ្រព្យមាំមួនកម្រើកមិនបានដោយខ្លួនឯង ដូច មាស ប្រាក់ ស្រែ ចំការ ទីដីសង់ផ្ទះ ជាដើម ។

២- **ជង្គមនិធិ** គឺកំណប់ទ្រព្យដែលកម្រើកខ្លួនឯងបាន ដូច ទាសា ទាសី គោ ក្របី ដំរី សេះ ជ្រូក មាន់ ទា រ ជាដើម។

៣- **អន្តសមនិធិ** គឺកំណប់ទ្រព្យស្ទើរដោយអវយវៈតូចធំ បានដល់ភាពជាពហុសូត្រ ជាអ្នកចេះដឹងច្រើន ទាំងចំណេះផ្លូវលោក និងផ្លូវធម៌ និងជាអ្នកជំនាញក្នុងកិច្ច ការនោះៗ ។

៤- **អនុគាមិកៈនិធិ** កំណប់ទ្រព្យដែលជាប់តាមខ្លួនជានិច្ច បានដល់បុណ្យដែលសម្រេចដោយ ទាន សីល ភាវនា ស្តាប់ធម៌ សម្តែងធម៌ជាដើម ។

បណ្តាកំណប់ទ្រព្យទាំង៤នេះ ព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សរសើរនូវអនុគាមិកៈនិធិ ថាជាកំណប់ទ្រព្យមានឫទ្ធិដ៏ធំក្រៃលែង ។

ស្រង់ចេញពីអដ្ឋកថានៃព្រះសូត្រនេះ ។

បត្តិទានគាថា

យំកិញ្ចិឃាលី

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន ឆាចា មនសា តិទសេ សុកតំ កតំ យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា យេ ច តត្ថ ន ជានន្តិ ទេឆា គន្ធា និវេទយុំ សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា មនុញ្ញំ ភោជនំ សព្វេលភន្តុ មម ចេតសាតិ ។

យំកិញ្ចិប្រែ

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម

អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ.

កាយេន ឆាចាមនសា ដោយទ្វាទាំងពា គឺកាយវាចាចិត្ត.

ឥទញ្ច សុគតំ កតំ អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានត្រៃត្រឹង្ស សួគ៌បាន.

យេ សត្តា សញ្ញិនោ អត្ថិ សត្វទាំងឡាយណា គឺមនុស្ស ឬទេវតា ឬព្រហ្ម ដែលជាសត្វមានបញ្ញាក្តី.

យេ ច សត្តា អសញ្ញិនោ សត្វទាំងឡាយណា ជាអសញ្ញីសត្វ គឺសត្វដែលឥតសញ្ញាក្តី.

កតំ បុញ្ញផលំ មយ្ហំ សព្ពេ ភាគី ភវន្តុ តេ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបានទទួលចំណែកនៃបុណ្យ ហើយចូរសោយផលនៃបុណ្យដែលខ្ញុំបានធ្វើ ហើយបានឧទ្ទិសផ្សាយឱ្យទៅនេះចុះ.

យេ កំ កតំ សុឥទិកំ ឥន្តំ បុញ្ញផលំ មយា បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយទទួលផលនៃបុណ្យ ដែល

ខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ.

យេ ច តត្ថ ន ជានន្តិ ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ.

ទេវា តញ្ហា នវេទយុំ សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផង ថាជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេនោះចុះ.

សព្វេ លោកម្ហិ យេ សត្តា ឋិតន្តាហារហេតុកា សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ.

មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្តដែល

សម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ ។

យំកិញ្ចិំប្រែពាក្យកាព្យ

កម្មកុសលឯណា ដែលជាការឥតសៅហ្មង
យើងខ្ញុំបានកសាង ដោយទ្វាកាយវាចាចិត្ត ។
កុសលទាំងអស់នោះ អាចជួយដោះជួយបង្ខិត
នាំសត្វឱ្យជាប់ចិត្ត ស្ថិតនៅនាស្ថានឧត្តម ។
សត្វណាមានសញ្ញា មនុស្សទេវតាឬតន្ត្រព្រហ្ម
ដែលមានស័ក្តិតូចធំ ព្រមទាំងសត្វឥតសញ្ញា ។
សូមបានចំណែកបុណ្យ ដែលជាគុណល្អថ្លៃថ្លា
យើងខ្ញុំបានរចនា ចាត់ចែងការកុសលហ្មឹង ។
ម្យ៉ាងទៀតសត្វឯណា ឆ្ងាយអស្ចារ្យពុំបានដឹង
សូមទេវតាទៅប្តឹង ឱ្យដំណឹងយ៉ាងនេះថា ។
នរជននៅឯនុ៎ះ ស្រីឬប្រុសបានជ្រះថ្លា
កសាងបុញ្ញកិរិយា វត្ថុជាផ្លូវឆើតឆាយ ។

ហើយគេឧទ្ទិសផល ឱ្យបានដល់អ្នកទាំងឡាយ
ចូរមានចិត្តស្រស់ស្រាយ បន្ទន់កាយទទួលយក ។
សត្វលោកទាំងអស់នោះ ដែលបានរស់តរៀងមក
ដោយបានបរិភោគ នូវអាហារទើបរស់បាន ។
សត្វទាំងអស់នោះណា បានសុខាសព្វគ្រប់ប្រាណ
អាហារយ៉ាងចំណាន សូមឱ្យបានកុំខានឡើយ ។

តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។
គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនឹងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា ។
ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា

គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញ្ញាតិកា
ប្រាំពីរសន្តាន ។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើនថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។
ខ្ញុំសូមសច្ចា កើតជាតិណាៗ សូមឱ្យខ្ញុំសុខ
សូមមានបញ្ញ ភ្លឺថ្លាមុះមុត រូចផុតពីទុក្ខ
ដល់និញ្ចានហោង ។

យាទេវតាឌាលី

យា ទេវតា សន្តិ ទិហារទាសិនី
ឡូបេ ឃរេ ពោធិឃរេ តហឺ តហឺ
តា ធម្មឧានេន ភទន្តុ បូជិតា
សោត្ថឺ ភរោន្តេធ ទិហារមណ្ឌលេ
ថេរោ ច មជ្ឈា នទកា ច ភិក្ខវោ

សាវាមិកា ឧានបតី ឧបាសិកា
គាមា ច ឧេសា និគមា ច ឥស្សរា
សប្បាណភូតា សុខិតា ភវន្តុ តេ
ឥលាពុឥា យេបិ ច អណ្ឌសម្ភវា
សំសេឧឥាតា អឥវោបបាតិកា
និស្សានិកំ ធម្មវរំ បដិច្ច តេ
សព្វេបិ ឧុក្ខស្ស ភវោន្តុ សំខយំ ។

ឡាតុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សឡោ ហោតុ សមគ្គោ ច អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សឧម្មោ សព្វេបិ ធម្មចារិនោ
ចុឌ្ឍី សម្បាបុណេយ្យាម ធម្មារិយប្បវេឧិតេ ។

យាទេវតាប្រែ

ប្រែថា យា ទេវតា សន្តិ វិហារវាសិនី ឋូបេ យរេ ពោធិយរេ តហឺ តហឺ ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងទីវត្តជាទីនៅនៃសង្ឆ ព្ជ៏ខ្សឹនព្រះសថូប ព្ជ៏ខ្សឹនព្រះពោធិព្រឹក្សក្នុងទីនោះ។.

តា ធម្មទានេន តវន្ត្ុ បូជិតា ទេវតាទាំងឡាយនោះជាបុគ្គលគឺយើងទាំងឡាយបូជាហើយដោយធម្មទាន.

សោត្ថឺ ភវោន្តេធ វិហារមណ្ឌលេ ចូរធ្វើនូវសូគិស្តីក្នុងមណ្ឌលនៃវត្តជាទីនៅនៃសង្ឆនេះ.

ថេរោ ច មជ្ឈា នវកា ច ភិក្ខវោ ភិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសក្តី.

សារាមិកា ទានបតី ឧបាសកា ឧបាសក និងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទាន ព្រមទាំងអារាមិកជនគឺញ្យោមវត្តក្តី

គាមា ច នេសា និគមា ច ឥស្សរា ជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាឥស្សរៈជាធំក្តី.

សប្បាណភូតា សុខិតា ភវន្តុ តេ សត្វទាំងឡាយនោះៗ ចូរឱ្យដល់នូវសេចក្តីសុខ.

ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា អថវោបបាតិកា មួយវិញទៀត សត្វទាំងឡាយឯណាដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែកជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី.

និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្វេបិ ទុក្ខស្ស ករោន្តុ សំខយំ

សត្វទាំងឡាយទាំងអស់នោះ កាលបើបាន អាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ.

ហោតុ ចិរំ សតំ ធម្មោ សូមឱ្យធម៌របស់សប្បុរសទាំងឡាយស្ថិតនៅអស់កាលយូរអង្វែងទៅ.

ធម្មធរា ច បុគ្គលា បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរអង្វែងទៅ).

សង្ឃោ ហោតុ សមគ្គោ ៖ សូមព្រះសង្ឃព្រមព្រៀងគ្នា.

អត្ថាយ ច ហិតាយ ច ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង.

អម្ហេ រក្ខតុ សទ្ធម្មោ សព្ពេបិ ធម្មចារិនោ សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង.

ឥទ្ធី សម្បាបុណោយ្យាម ធម្មាវិយប្បវេធិរេ សូមឱ្យយើងទាំងឡាយបានដល់សេចក្តីចម្រើនក្នុងធម៌ ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។

យាចទេវតា ប្រែពាក្យកាព្យ

យើងខ្ញុំទាំងអស់គ្នា សូមបូជាដោយធម្មទាន
ដល់ទេវតាដែលមាន នៅទីឋានវត្តនេះក្តី ។
នាខ្សឹនព្រះសថូប ឬនៅនាខ្សឹនចេតិយ
សូមមានចិត្តមេត្រី ធ្វើទីកដីទីវត្តនេះ ។
សូមឱ្យសុខសូស្តី ទុក្ខសោកអ្វីកុំមានសោះ
ម្យ៉ាងទៀតសង្ឃទាំងអស់ ដែលមានផ្ទូសជាថេរ: ។
ឬក៏ជាមជ្ឈិម ឬនៅត្រឹមជានវក
ឬក៏ឧបាសក ឧបាសិកាជាម្ចាស់ទាន ។
ព្រមទាំងអ្នកនិគម ឬអ្នកធំអម្បាលមាណ
គ្រប់ស្រុកប្រទេសឋាន សូមឱ្យបានសុខឯកអ័គ្ឃ ។
ម្យ៉ាងទៀតសត្វឯណា ដែលកើតជាជលម្ពុជ:
ឬជាអណ្ឌជ: សំសេទជ:កំណើតក្តី ។
ឬក៏ឧបបាតិក: គ្រប់ៗថ្នាក់ជនលោកកីយ៍

ដោយអំណាចសេចក្តី ធម៌បាលីថ្លៃបវរ ។
កុំឱ្យមានទុក្ខសោក ក្តីវិយោគសំសារចរ
ម្យ៉ាងទៀតសូមព្រះធម៌ ថ្លៃបវរស្ថិតនៅវែង ។
និងអ្នកចេះធម្មៈ សូមតាំងនៅយូរអង្វែង
នឹងសូមអស់គម្តែង សង្ឃម៉ឺនសែនសាមគ្គីធម៌ ។
ដើម្បីប្រយោជន៍ច្រើន នឹងចម្រើនកុសលធម៌
ហើយសូមព្រះសទ្ធម្ម ជួយគាំទ្រយើងគ្រប់គ្នា ។
ហើយសូមអស់យើងខ្ញុំ ចេះចាំគ្រប់កងធម្មា
ដែលអង្គព្រះអរិយា ទ្រង់ទេសនាទុកហើយហោង ។

(ចប់ឃាថាវែងប្រែពាក្យកាព្យ)

ប្រពៃណីសូមអាហារដែលសេសសល់អំពីព្រះសង្ឃ

នៅសម័យពុទ្ធកាល មានឧបាសកម្នាក់ ឈ្មោះចិត្តគហបតី ជាឧបាសកមានសទ្ធាជ្រះថ្លាគោរពកោតក្រែងក្នុងព្រះពុទ្ធព្រះធម៌ ព្រះសង្ឃ ព្រោះគាត់ជាអរិយបុគ្គលថ្នាក់អនាគាមី ទាំងជាធម្មកថិក

ដែលមានឧបាសកបរិស័ទដ៏ច្រើនចោមរោម ។ ចិត្តគហបតី ឧបាសកនេះ កាលណាគាត់បាននិមន្តព្រះសង្ឃមកទទួលចង្ហាន់នៅ ឯផ្ទះគាត់ ក្រោយពេលព្រះសង្ឃឆាន់ស្រេចហើយ គាត់តែងពោលវាចាសុំភោជនដែលសេសសល់អំពីព្រះសង្ឃ ។ ព្រោះហេតុដូច្នេះ ពាក្យសុំអាហារដែលសេសសល់នេះ ទើបជាប់បានជាប្រពៃណីរបស់ពុទ្ធសាសនិកជនខ្មែរយើងរហូតមក តែមិនធ្លាយមទូទៅគ្រប់ទីកន្លែងទាំងអស់ទេ ព្រោះឃើញថា មិនជាទោសអ្វី នេះគ្រាន់តែចិត្តគហបតីគាត់ធ្វើសេចក្តីគោរពក្នុងព្រះភិក្ខុសង្ឃប៉ុណ្ណោះ ។

ពាក្យសុំអាហាររបស់ចិត្តគហបតី

សេសភោជនំ ទិសេថ

សូមលោកម្ចាស់ លះបង់នូវភោជនាហារដែលសេសសល់ ។

(ពាក្យនេះនៅកន្លែងខ្លះ លោកអ្នកចេះភាសាបាលី បានតែងឱ្យមានសេចក្តីវែងជាងនេះទៀតក៏មាន ដើម្បីធ្វើឱ្យពិរោះស្តាប់) ។

វិធីវេរភត្ត និង បច្ចំយផ្សេងៗ

ឈ្មោះភត្តទាំង ១៤ នោះគឺ

១- សឡ្យភត្តំ	៨- អាគន្តុកភត្តំ
២- ឧទ្ទេសភត្តំ	៩- គមិកភត្តំ
៣- និមន្តនភត្តំ	១០- គិលានភត្តំ
៤- សលាកភត្តំ	១១- គិលានុប្បដ្ឋាកភត្តំ
៥- បក្ខិកភត្តំ	១២- និច្ចភត្តំ
៦- ឧបោសថិកភត្តំ	១៣- កុដិកភត្តំ
៧- បាដិបទិកភត្តំ	១៤- ទារកភត្តំ

វិធីវេរសឡ្យភត្តដល់ព្រះភិក្ខុសឡ្យ

នមោ តស្ស

ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។ (បីចប់) ។

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ

ធម្មេនេវ ឧបាធិតោ មាតាបិតុអាធិកេ គុណវន្តេ ឧទ្ទិស្ស ឥមំ (សឡ្យកត្តំ) សបរិក្ខារំ ពុទ្ធប្បមុក្ខស្ស សឡ្យស្ស ទេម តេ គុណវន្តាធយោ ឥមំ សឡ្យកត្តំ អត្តនោ សន្តកំ ទិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សប្បទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្តេន ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចំរើន រីចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំ ទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើង ដោយធម៌ យើងខ្ញុំព្រះករុណាទាំងឡាយ សូមឧទ្ទិសចំពោះលោក អ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម យើងខ្ញុំព្រះករុណា ទាំងឡាយ សូមវេរនូវស្ឃភត្តនេះ ព្រមទាំងបរិក្ខារ ប្រគេនដល់ ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំង ឡាយ មានមាតាបិតាជាដើមនោះ សម្តាល់នូវសង្ឃភត្តនេះ ថាដូច

ជារបស់នៃខ្លួន ហើយសូមអនុមោទនាយកចុះ លុះអនុមោទនារួច ហើយ សូមឱ្យរួចរំដោះចាកទុក្ខទាំងពួង ឱ្យបានសម្រេចដោយ សម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស១ សម្បត្តិទេវតា១ សម្បត្តិព្រះនិព្វាន១ ដោយសមគួរតាមសេចក្តីប្រាថ្នា របស់លោក អ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែល ហូរជូនមកមិនដាច់នេះហោង ។

... អស់វារៈពីរដងផង ។ ... អស់វារៈបីដងផង ។

(ចំណែកពាក្យវេរឈ្មោះភត្តដទៃទៀត ត្រាន់តែផ្លាស់ឈ្មោះ សង្ឃភត្ត ហើយបញ្ជូនឈ្មោះភត្ត ដែលខ្លួនត្រូវការមកជំនួស ឯពាក្យដទៃទៀតដូចដើមទាំងអស់) ។

ទិធីទេរសឡឋាន

ទយំ ភន្តេ ឥមានិ ខាឧនីយភោជនីយាឧីនិ សវ្ជេត្វា សឡ្យស្ស ឧេម សាធុ ភន្តេ សឡ្យោ ឥមានិ ខាឧនីយភោជនីយាហាឧីនិ ចជិត្តណ្ហតុ អម្ហាកំ ឧីយភ្តំ

អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំព្រះករុណាទាំងឡាយ បានតាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយនិងភោជនីយាហារ គឺបង្អែមនិងចង្ហាបជាដើមនេះ ហើយវេរប្រគេនដល់ព្រះសង្ឃបពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចង្ហាបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

វិធីវេរចតុប្បច្ច័យជាសង្ឃទាន

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធានេក្ខា សង្ឃស្ស ឧទ្ទិស្ស សាធុ ភន្តេ សង្ឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំព្រះករុណាទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ៤នេះ មកតម្កល់ទុកក្នុងទីនេះ ហើយវេរប្រគេនដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយកនូវបច្ច័យទាំងឡាយ៤នេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

... អស់វារៈពីដងផង ។ ... អស់វារៈបីដងផង ។

ទិធីវេរវោចចោសថគឺព្រះវិហារ

មយំ ភន្តេ ឥមំ ឧបោសថាគារំ ការេត្វា ឧបោសថបតិដ្ឋាបនិសជ្ឈកម្មករណត្ថាយ ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ទេម ។ សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ ឧបោសថាគារំ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ បានចាត់ចែងធ្វើនូវរោងសម្រាប់ធ្វើឧបោសថនេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃដែលមកអំពីទិសទាំង៤ ដើម្បីប្រយោជន៍ដល់ការិយាធ្វើនូវសង្ឃកម្ម មានឧបោសថកម្មនិងបវារណាកម្ម ជាដើម ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃមេត្តាទទួលយកនូវរោងសម្រាប់ធ្វើឧបោសថនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

... អស់វារៈពីដងផង ។ ... អស់វារៈបីដងផង ។

ទិដ្ឋខេរសាលា

មយំ ភន្តេ ឥមំ សាលំ ការេត្វា ចាតុទ្ទិសស្ស សង្ឃស្ស ឧទម ។ សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ សាលំ បដិគ្គណ្ហាតុ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ បានចាត់ចែងធ្វើនូវសាលានេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃដែលមកអំពីទិសទាំង៤។ សូមព្រះភិក្ខុសង្ឃទទួលយកនូវសាលានេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់យើងខ្ញុំព្រះករុណាទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

... អស់វារៈពីដងផង ។ ... អស់វារៈបីដងផង ។

ទីធីវេរកុដិ

មយំ ភន្តេ ឥមំ កុដឹ ការេត្វា ចាតុទ្ទិសស្ស ភិក្ខុសង្ឃស្ស ឧទម ។ សាធុ ភន្តេ ភិក្ខុសង្ឃោ ឥមំ កុដឹ បដិគ្គណ្ហាតុ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ទុតិយម្បិ ... ។ តតិយម្បិ ... ។

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ បានចាត់ចែងធ្វើនូវកុដិនេះ ហើយសូមវេរប្រគេនដល់ព្រះភិក្ខុសង្ឃដែល

មកអំពីទិសទាំង៤ ។ សូមព្រះភិក្ខុសង្ឃមេត្តាទទួលយកនូវកុដិនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

... អស់វារៈពីដងផង ។ ... អស់វារៈបីដងផង ។

ចិធីចេរកឋិនទាន

ឥមំ កន្តេ កឋិនចីវរំ សានិសង្សំ សង្ឃស្ស ទេម ទុតិយម្ឃិ ។ តតយម្ឃិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំព្រះករុណាទាំងឡាយ សូមវេរនូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភចំពោះព្រះសង្ឃ ។

អស់វារៈពីរដងផង ។ អស់វារៈបីដងផង ។

សាធុ នោ កន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសង្សំ កឋិនំ អត្ថរិតុំ ។

បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលយក នូវកឋិនចីវរនេះ ព្រមទាំងអានិសង្សលាភ របស់យើងខ្ញុំព្រះករុណាទាំង

ឡាយ ដើម្បីក្រាលកឋិន ។

មាតាបិតុអាទីណាញ្ច គុណវន្តានំ អម្ហាកញ្ច ទីឃរត្តំ អាត្ថាយ ហិតាយ សុខាយ ។

ដើម្បីបាននូវសេចក្តីចម្រើន ដើម្បីបាននូវប្រយោជន៍ ដើម្បីបាននូវសេចកីសុខ ដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាអង្វែងទៅហោង ។

ទឹកសមុទ្ររាប់ប៉ៅតតោនមិនអស់ ច្រើនម្ល៉ោះតែទាស់មានរសប្រៃ
ជនណាស្រែកឃ្លានដូចម្តេចក្តី មិនអាចអាស្រ័យទឹកនោះបាន ។
ឧបមាដូចជាចិត្តកំណាញ់ មានទ្រព្យពោរពេញគេហដ្ឋាន
វិជ្ជាយសសក្តិថ្នាក់ថ្កើនថ្កាន អ្នកផងមិនបានសុខដោយសា ។
ទឹកសាបសូម្បីមួយទូកដៃ គង់គួរគប្បីដល់ជនា
ពិសារក្រៃបផឹករសគង្គា កម្ចាត់វេទនាជាសុខសាន្ត ។
ឧបមាដូចជនមិនកំណាញ់ ទ្រព្យតិចម្តេចមិញគង់ចែកទាន
ទោះយសសក្តិទាបភាពស្មើប្រាណ អ្នកផងតែងបានសុខដោយសា ។